ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



# របាយការណ៍បូកសរុប
# ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០២៥
# និងទិសដៅឆ្នាំ២០២៦

រាជធានីភ្នំពេញ ខែមីនា ឆ្នាំ២០២៦

# មាតិកា


**១. សេចក្តីផ្តើម** ........ ១

**២. លទ្ធផលនៃការអនុវត្តថវិកាកម្មវិធី** ........ ២

**៣. កម្មវិធីគោលនយោបាយអាទិភាពទី៥ និងទី៦ ក្នុងវិស័យកសិកម្ម** ........ ៣

**៤. លទ្ធផលជារួម** ........ ៤

៤.១ ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ ........ ៤

៤.២ កំណើនវិស័យកសិកម្ម ........ ៥

៤.៣ ការចូលរួមចំណែករបស់អនុវិស័យនានាក្នុងវិស័យកសិកម្ម ........ ៦

**៥. លទ្ធផលតាមអនុវិស័យ និងផ្នែកផ្សេងៗ** ........ ៧

៥.១ ការងារបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិធុរកិច្ច ........ ៧

៥.២ ការបង្កើនផលិតភាពដំណាំកៅស៊ូ ........ ១៦

៥.៣ ការងារសុខភាពសត្វ និងផលិតកម្មសត្វ ........ ២០

៥.៤ ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម ........ ២៩

៥.៥ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានព្រៃឈើ និងសត្វព្រៃ ........ ៣៣

៥.៦ ការងារសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស ........ ៣៧

**៦. បញ្ហាប្រឈម** ........ ៤២

**៧. ទិសដៅអនុវត្ត** ........ ៤២

៧.១ ផែនការជំរុញផលិតកម្មដំណាំស្រូវ ដំណាំស្បៀងរួមផ្សំ និងដំណាំទ្រទ្រង់សេដ្ឋកិច្ច ........ ៤៣

៧.២ ផែនការបង្កើនផលិតកម្មដំណាំកៅស៊ូ ........ ៤៣

៧.៣ ផែនការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ ........ ៤៤

៧.៤ ផែនការពង្រឹងការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម ........ ៤៤

៧.៥ ផែនការពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃ ........ ៤៥

៧.៦ ផែនការពង្រឹងការគ្រប់គ្រងស្ថាប័ន និងអភិវឌ្ឍន៍ធនធានមនុស្ស ........ ៤៥

**៨. សេចក្តីសន្និដ្ឋាន** ........ ៤៦

**តារាងឧបសម្ព័ន្ធ**

# របាយការណ៍បូកសរុប
# ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០២៥
# និងទិសដៅឆ្នាំ២០២៦

## ១. សេចក្តីផ្តើម

រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយថាមវន្តរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងកម្មវិធីគោលនយោបាយអាទិភាព សំដៅធានាសុខសន្តិភាព ស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាពក្នុងការកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យឆ្នាំ២០៥០។ ជាមួយគ្នានេះ នៅក្នុងមុំទី៣ នៃបញ្ចកោណទី៤ វិស័យកសិកម្មនៅតែចាត់ទុកជាវិស័យអាទិភាព ដោយបន្តពង្រឹងតួនាទី និងការអភិវឌ្ឍវិស័យកសិកម្មឱ្យទំនើប សម្បូរបែប និងមានភាពធន់ ដែលគាំទ្រដល់ការអភិវឌ្ឍជនបទ សំដៅធានាសន្តិសុខ និងសុវត្ថិភាពស្បៀង បង្កើនតម្លៃបន្ថែមខ្ពស់ ជំរុញភាពប្រកួតប្រជែង និងលើកកម្ពស់គុណភាពជីវភាពនៅជនបទ។

យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ បានផ្តល់អាទិភាពខ្ពស់ក្នុងការជំរុញអនុវត្តកម្មវិធីគោលនយោបាយអាទិភាពចំនួន៦ ដែលក្នុងនោះមានកម្មវិធីទី៥ និងទី៦ ពាក់ព័ន្ធនឹងវិស័យកសិកម្មគឺ ការលើកស្ទួយផលិតកម្មកសិកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃ ការដាក់ពង្រាយមន្ត្រីកសិកម្មឃុំ និងការអភិវឌ្ឍសហគមន៍កសិកម្មទំនើប។ ជាមួយគ្នានេះ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា បានដាក់ចេញនូវផែនការអភិវឌ្ឍវិស័យកសិកម្មដោយផ្តោតសំខាន់៖ ១.ការបន្តកសាងក្របខ័ណ្ឌគតិយុត្ត គោលនយោបាយ និងពង្រឹងស្ថាប័ន ២.ការជំរុញផលិតកម្មកសិកម្ម ៣.ការពង្រឹងកិច្ចសហការក្នុងការវិនិយោគលើប្រព័ន្ធធារាសាស្ត្រសម្រាប់វិស័យកសិកម្ម ៤.ការកាត់បន្ថយថ្លៃដើមផលិតកម្ម ៥.ការធានាស្ថិរភាពថ្លៃផលិតផលកសិកម្ម ៦.ការលើកកម្ពស់ការកែច្នៃផលិតផលកសិកម្ម ៧.ការបន្តលើកកម្ពស់ការតភ្ជាប់ទីផ្សារក្នុងស្រុកនិងការជំរុញការនាំចេញ និង៨.ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍ជនបទ សម្រាប់គាំទ្រវិស័យកសិកម្ម។ ទន្ទឹមនឹងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់ទស្សនទាន **មានហូប មានប្រើ មានបាន និងមានរហូត** ក្នុងទិសដៅសម្រេចឱ្យបានគោលនយោបាយ និងផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា។

រយៈពេលពេញមួយឆ្នាំ២០២៥ កន្លងទៅនេះ ក្រសួងបានខិតខំជំរុញអនុវត្តវិធានការចាំបាច់នានាដូចជា ការអភិវឌ្ឍខ្សែច្រវាក់ផលិតកម្មកសិកម្ម តាមរយៈបង្កើតសហគមន៍កសិកម្មទំនើប កាត់បន្ថយថ្លៃដើមផលិតកម្ម ជួយរក្សាស្ថិរភាពតម្លៃទីផ្សារលើផលិតផលកសិកម្ម និងបន្តលើកកម្ពស់ការតភ្ជាប់ទីផ្សារក្នុងស្រុកនិងការជំរុញការនាំចេញ។ ទន្ទឹមនេះ ក្រសួងក៏បានយកចិត្តទុកដាក់លើការងារគ្រប់គ្រងធនធានធម្មជាតិកសិកម្ម រួមមាន ការកសាងនិងពង្រឹងសហគមន៍នេសាទ សហគមន៍ព្រៃឈើ ការគ្រប់គ្រងកន្លែងការពារនិងអភិរក្សធនធានជលផល ព្រៃឈើនិងសត្វព្រៃ ព្រមទាំងទប់ស្កាត់និងបង្ក្រាបបទល្មើសនានា។ ជាមួយគ្នានេះ ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ បានពង្រឹងសមត្ថភាពធនធានមនុស្ស ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្មឱ្យមានប្រសិទ្ធភាពខ្ពស់ ដោយមានការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា កិច្ចសហការល្អពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ វិស័យឯកជន អង្គការជាតិនិងអន្តរជាតិនានា រដ្ឋបាលថ្នាក់ក្រោមជាតិ និងការចូលរួមយ៉ាងសកម្មពីប្រជាកសិករ។

## ២. លទ្ធផលនៃការអនុវត្តថវិកាកម្មវិធី

### ២.១ កម្មវិធីទី១៖ ការអភិវឌ្ឍន៍ខ្សែច្រវាក់ផលិតកម្មកសិកម្ម

ក្នុងឆ្នាំ២០២៥ ការអនុវត្តថវិកាកម្មវិធីទី១ បានចំណាយប្រមាណ ៤៤ ១០១,៣លានរៀល ស្មើនឹង ៩២,១២% នៃច្បាប់ថវិកា ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

**ក. ផលិតកម្មដំណាំ** ផលិតកម្មដំណាំកសិកម្មសរុបចំនួន ៤០,៧៨លានតោន កើនឡើងប្រមាណ ៣,២៥% ធៀបឆ្នាំ២០២៤ ក្នុងនោះផលិតកម្មដំណាំស្រូវបានចំនួន ១៥,០៩លានតោន ផលិតកម្មដំណាំស្បៀងរួមផ្សំចំនួន ៤,៩៤លានតោន និងផលិតកម្មដំណាំទ្រទ្រង់សេដ្ឋកិច្ចចំនួន ២០,៣៣លានតោន និងផលិតកម្មដំណាំកៅស៊ូចំនួន ០,៤២លានតោន។ ជាមួយគ្នានេះ តម្លៃផលិតកម្មដំណាំកសិកម្មសរុបមានប្រមាណ ៨ ៨២៨លានដុល្លារអាម៉េរិក និងបាននាំចេញជាផ្លូវការសរុបប្រមាណ ១៥,២៥លានតោន ដែលមានទំហំទឹកប្រាក់ប្រមាណជាង ៥ ៦២៤លានដុល្លារអាម៉េរិក កើនលើសឆ្នាំ២០២៤ ចំនួន ៣២៧លានដុល្លារអាម៉េរិក ស្មើនឹង ៦,១៨%។ កម្ពុជាមានអតិរេកបរិមាណផលស្រូវនៅសល់ក្រោយពីតម្រូវការស្បៀងប្រើប្រាស់ក្នុងស្រុកប្រមាណ ៩,១៥លានតោន គិតជាអង្ករស្មើនឹង ៥,៨៦លានតោន កើន ១២,១៧% ធៀបឆ្នាំ២០២៤។

**ខ. ផលិតកម្មសត្វ** ផលិតកម្មសត្វសរុបចំនួន ៦៨,៩៤លានក្បាល ថយចុះក្នុងអត្រា ០,៣៨%ធៀបឆ្នាំ២០២៤ ក្នុងនោះគោ-ក្របី ចំនួន ៣,៤៣លានក្បាល ថយចុះ ២,២៦% ធៀបឆ្នាំ២០២៤ ជ្រូក ចំនួន ៤,៦៥លានក្បាល កើនឡើង ១៤,៥៥% ធៀបឆ្នាំ២០២៤ និងបក្សី ចំនួន ៦០,៧៦លានក្បាល ថយចុះ ១,២៩% ធៀបឆ្នាំ២០២៤។ ជារួមការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារថយចុះប្រមាណ ៣,៥០% និងការចិញ្ចឹមសត្វលក្ខណៈពាណិជ្ជកម្មមានការកើនឡើងប្រមាណ ៣,៤៨%។ ជាមួយគ្នានេះ តម្លៃផលិតកម្មសរុបមានចំនួន ១ ៨០៦លានដុល្លារអាម៉េរិក ខណៈការនាំចេញសត្វរស់ ផលិតផលមានដើមកំណើតពីសត្វ និងចំណីសត្វ បានចំនួន ២៤៣,៦១លានដុល្លារអាម៉េរិក។ ទន្ទឹមនេះ ក្រសួងបានយកចិត្តទុកដាក់លើការងារផលិតកម្មសត្វដែលមានគុណភាព អនាម័យ និងសុវត្ថិភាព ដើម្បីបំពេញតម្រូវការប្រើប្រាស់ក្នុងស្រុក ប្រមាណ ៩៨%។

**គ. ផល និងផលិតផលជលផល** ផលិតផលជលផលសម្រេចបានចំនួន ៩៦៥ ៧៥៨តោន កើនឡើងចំនួន ៣៨ ៨២៤តោន ស្មើនឹង៤,១៩% ធៀបនឹងឆ្នាំ២០២៤ ក្នុងនោះផលនេសាទទឹកសាបទទួលបានចំនួន ៥១៤ ៨៣០តោន ផលនេសាទសមុទ្រទទួលបានចំនួន ១៤០ ១៦៣តោន និងផលវារីវប្បកម្មសម្រេចបានចំនួន ៣១០ ៧៦៥តោន។ ជាមួយគ្នានេះ ផល ផលិតផលជលផលមានតម្លៃសរុបចំនួន ២ ១២៣លានដុលារអាម៉េរិក ក្នុងឆ្នាំ២០២៥ និងការនាំចេញផល ផលិតផលជលផលចំនួន ១ ៥៦៦,៤តោន គិតជាតម្លៃស្មើនឹង ៣,១៥លានដុល្លារអាម៉េរិក។

### ២.២ កម្មវិធីទី២៖ ការគ្រប់គ្រងធនធានធម្មជាតិកសិកម្ម

ក្នុងឆ្នាំ២០២៥ ការអនុវត្តថវិកាកម្មវិធីទី២ បានចំណាយប្រមាណ ១៨ ២៥៣លានរៀល ស្មើនឹង ៩៧,៤៤% នៃច្បាប់ថវិកា ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

**ក. ការគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃ៖** គិតត្រឹមឆ្នាំ២០២៥នេះ ក្រសួងបានកំណត់ ចុះបញ្ជី និងគ្រប់គ្រង ដីស្ថានីយ៍ ដីសហគមន៍ព្រៃឈើ និងសម្បទានដីសេដ្ឋកិច្ចសម្រេចបានផ្ទៃដីព្រៃចំនួន ២៨ ៧០៨ ហិកតាស្មើនឹង ១៤៣,៥៤% នៃផែនការ។ លើសពីនេះ នៅឧទ្យានសួនសត្វ ព្រៃការពារ និងសួនភូតគាម "ភ្នំតាម៉ៅ" ក្រសួងបាននិងកំពុងថែរក្សាសត្វព្រៃចំនួន ៣ ០៨៥ក្បាល ស្មើនឹង ១០២,៨៣% នៃផែនការ។

**ខ. ការគ្រប់គ្រងនិងអភិរក្សធនធានជលផល៖** ការការពារ និងការគ្រប់គ្រងផ្ទៃដីដែនគ្រប់គ្រងជលផលអនុវត្តបានចំនួន ១ ៧២៩ពាន់ហិកតា និងផលនេសាទពីធម្មជាតិ (ទឹកសាប និងសមុទ្រ) សម្រេចបាន៦៥៣ពាន់តោន។ លើសពីនេះ ក្រសួងបានកសាងនិងពង្រឹងសហគមន៍នេសាទ បង្កើនជីវភាពរស់នៅរបស់សមាជិកសហគមន៍នេសាទ គ្រប់គ្រងកន្លែងការពារ និងអភិរក្សធនធានជលផល គ្រប់គ្រងតំបន់គ្រប់គ្រងជលផលនិងកិច្ចការនេសាទ ទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ស្រាវជ្រាវជលផល សកម្មភាពគាំទ្រដំណើរការរដ្ឋបាល និងរៀបចំផែនការនិងការតាមដានអនុវត្ត។

គ. **ការគ្រប់គ្រងធនធានដីកសិកម្មប្រកបដោយនិរន្តរភាព** បានបញ្ចប់ការអង្កេត វាយតម្លៃ និងចាត់ថ្នាក់ក្រុមដីតាមប្រព័ន្ធ WRB2014 (World Reference Base 2014) រួមទាំងបានធ្វើផែនទីដីថ្នាក់ស្រុកសម្រាប់ខេត្តតាកែវ ស្វាយរៀង ត្បូងឃ្មុំ និងខេត្តបន្ទាយមានជ័យ។ លើសពីនេះ ក្រសួងបានរៀបចំស្រែបង្ហាញស្តីពីការអនុវត្តកសិកម្មវៃឆ្លាតនឹងអាកាសធាតុ ដើម្បីវាយតម្លៃពីប្រសិទ្ធភាពបច្ចេកទេសពន្លិច និងបង្ហោក (AWD) ក្នុងការសន្សំសំចៃទឹកលើដំណាំស្រូវ និងបានគាំទ្របច្ចេកទេសនិងការអនុវត្តចម្ការបង្ហាញអំពីប្រសិទ្ធភាពនៃការប្រើប្រាស់ជីលើដំណាំស្វាយចន្ទី បានចំនួន ៤៣លើក និងបានបណ្តុះបណ្តាលគ្រូពេទ្យដី (Soil Doctor Training) ដល់កសិករចំនួន ២៩លើក មានអ្នកចូលរួមសរុបចំនួន ៦៧៥នាក់ (ស្ត្រី ២៤៨នាក់)។

### ២.៣ កម្មវិធីទី៣៖ ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ

ក្នុងឆ្នាំ២០២៥ ការអនុវត្តថវិកាកម្មវិធីទី៣ បានចំណាយប្រមាណ ១៥២ ៨៧៣,៣លានរៀល ស្មើនឹង ៩៤,៣៨% នៃច្បាប់ថវិកា។ ក្រសួងបានអភិវឌ្ឍធនធានមនុស្ស ការកសាងឯកសារគតិយុត្ត កិច្ចសហប្រតិបត្តិការ និងចូលរួមចំណែកយ៉ាងសកម្មក្នុងការរៀបចំធាតុចូលសម្រាប់កំណត់សូចនាករវាស់វែងការងនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ព្រមទាំងបានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។ លើសពីនេះទៀត ក្រសួងបានប្រមូលចំណូលមិនមែនសារពើពន្ធរួមមានពីថ្លៃឈ្នួលដីសម្បទានសេដ្ឋកិច្ច សេវាសាធារណៈ ការផាកពិន័យ និងចំណូលផ្សេងៗ សរុបចំនួន ៦៥ ០៣៤លានរៀលគឺស្មើនឹង ១៣២,១០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៥ ចំនួន ៤៩ ២១៥លានរៀល។

សមិទ្ធផលទាំងនេះបានឆ្លុះបញ្ចាំងឱ្យឃើញថា វិស័យកសិកម្មមានការរីកចម្រើនគួរឱ្យកត់សម្គាល់ និងបានចូលរួមចំណែកយ៉ាងសកម្មក្នុងការធានាសន្តិសុខស្បៀង លើកកម្ពស់កម្រិតជីវភាពប្រជាជន បង្កើនប្រាក់ចំណូលក្នុងគ្រួសារ ជាមួយនឹងការបង្កើនការនាំចេញ និងទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ។

## ៣. កម្មវិធីគោលនយោបាយអាទិភាពទី៥ និងទី៦ ក្នុងវិស័យកសិកម្ម

ក្រសួងបាននិងកំពុងបន្តអនុវត្តយ៉ាងសកម្មភាពលើគោលនយោបាយអាទិភាពទី៥ និងទី៦ ដោយសម្រេចបានលទ្ធផលដូចខាងក្រោម៖

### ៣.១ កម្មវិធីគោលនយោបាយអាទិភាពទី៥

កម្មវិធីគោលនយោបាយអាទិភាពទី៥ ស្តីពី "យន្តការសម្របសម្រួល និងកម្មវិធីហិរញ្ញប្បទាន សំដៅលើកស្ទួយផលិតកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផលសំខាន់ៗ ក្នុងកម្រិតសមរម្យ" តាមរយៈការដាក់ចេញនូវកញ្ចប់ថវិកាជាក់លាក់ ដោយចាប់ផ្តើមពីចំនួន ១០០លានដុល្លារអាម៉េរិក និងអាចវិភាជថវិកាបន្ថែម ប្រសិនបើមានតម្រូវការចាំបាច់ គឺជាកម្មវិធីគោលនយោបាយជាតិសំខាន់មួយ។ គិតត្រឹមឆ្នាំ២០២៥នេះ ក្រសួងបានសម្របសម្រួលបញ្ចេញហិរញ្ញប្បទានពិសេសជួយដល់រោងម៉ាស៊ីនអាចប្រមូលទិញស្រូវពីកសិករបានទាន់ពេលវេលា និងរក្សាតម្លៃល្អ សម្រាប់កសិករ ព្រមទាំងបានធានាស្តុកអង្ករគ្រប់គ្រាន់សម្រាប់ការនាំចេញចំនួន៤ ដង ដែលមានទំហំទឹកប្រាក់ចំនួន ១០៨,៥៥ លានដុល្លារអាម៉េរិក និងបានប្រមូលត្រឡប់មកវិញបានចំនួន ៨៦,៨៥លានដុល្លារអាម៉េរិក។

ជារួម ការផ្តល់ហិរញ្ញប្បទានតាមរយៈកម្មវិធីគោលនយោបាយនេះ បានជួយជាធនធានបន្ទាន់ពិសេស និងជួយលើកទឹកចិត្ត និងជានយោបាយដ៏ល្អ ក្នុងការធ្វើការជាមួយអ្នកពាក់ព័ន្ធនានា។

### ៣.២ កម្មវិធីគោលនយោបាយអាទិភាពទី៦

ក. ការដាក់ពង្រាយមន្ត្រីកសិកម្មឃុំ-សង្កាត់

កម្មវិធីគោលនយោបាយដាក់ពង្រាយមន្ត្រីកសិកម្មឃុំ-សង្កាត់ គឺជាកិច្ចខិតខំប្រឹងប្រែងមួយទៀតរបស់រាជរដ្ឋាភិបាលក្នុងការបង្វិតសេវាឱ្យបានទៅជិតប្រជាពលរដ្ឋនៅមូលដ្ឋាន នៅគ្រប់ឃុំទាំងអស់នៅជនបទទូទាំងប្រទេស ដើម្បីជួយដល់គ្រួសារកសិករក្នុងការលើកស្ទួយផលិតភាពកសិកម្ម និងប្រាក់ចំណូល។

បច្ចុប្បន្ននេះ ក្រសួងបានដាក់ពង្រាយមន្ត្រីកសិកម្មឃុំចំនួន ១ ៦០០នាក់ទៅតាមឃុំ សង្កាត់ចំនួន ១ ៥០៨ ក្នុងនោះ មានឃុំ សង្កាត់ចំនួន ៩២ បានទទួលមន្ត្រីកសិកម្មឃុំចំនួន ២នាក់ (ឃុំមានប្រជាជន និងភូមិច្រើន) និងមន្ត្រីកសិកម្មឃុំ សង្កាត់ បានទទួលការបណ្តុះបណ្តាលពីរបៀបរបបនិងបែបបទរដ្ឋបាល ព្រមទាំងទទួលបាននូវ Tablet ម្នាក់មួយគ្រឿង ដើម្បីសម្រួលដល់ការប្រមូលព័ត៌មាន និងប្រមូលទិន្នន័យកសិកម្មនានា។ ជាលទ្ធផលមន្ត្រីកសិកម្មឃុំបានបន្តការងារ យ៉ាងខ្ជាប់ខ្ជួនក្នុងការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងគាំទ្រដល់កសិករក្នុងការស្វែងរកទីផ្សារផលិតផលកសិកម្ម។ ជាមួយគ្នានេះ មន្ត្រីកសិកម្មឃុំបានផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់កសិករចំនួន ៥៥៤ ១១៧នាក់ (ស្ត្រី ២០៦ ១១៧) មានកសិករសហការចំនួន ១៤៤ ២២៨គ្រួសារ បានសម្របសម្រួលទីផ្សារស្រូវកសិករចំនួន ៦៣ ២៥៩តោន ស្មើនឹង ចំនួន ១១២ ៥៣៨គ្រួសារ និងបានជួយដោះស្រាយបញ្ហាប្រឈមក្នុងមូលដ្ឋានចំនួន ៧ ៩៦៨ករណី ផងដែរ។

ខ. ការបង្កើតសហគមន៍កសិកម្មទំនើប

សហគមន៍កសិកម្មទំនើប គឺជាចក្ខុវិស័យនៃការអនុវត្តផលិតកម្មកសិកម្មរួមគ្នាក្នុងទ្រង់ទ្រាយធំនៅក្នុងវិស័យកសិកម្ម ក្នុងគោលបំណងប្រែក្លាយវិស័យកសិកម្មកម្ពុជាពីលក្ខណៈគ្រួសារឱ្យទៅជាសហគ្រាសសេដ្ឋកិច្ចកសិកម្មដ៏រឹងមាំ មានសមាហរណកម្មខ្ពស់ មានសេដ្ឋកិច្ចមាត្រដ្ឋាន និងមានសមត្ថភាពប្រកួតប្រជែងទាំងបរិមាណ និងគុណភាព។ គិតត្រឹមឆ្នាំ២០២៥ ក្រសួងបានបង្កើតសហគមន៍កសិកម្មទំនើបចំនួន ២៧ លើមុខដំណាំយុទ្ធសាស្ត្រចំនួន៤ គឺ ដំណាំស្រូវ បន្លែ ស្វាយចន្ទី និងដំណាំម្រេច ក្នុងខេត្តចំនួន ១២ (សៀមរាប កំពង់ធំ តាកែវ កំពង់ឆ្នាំង កណ្តាល ត្បូងឃ្មុំ ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ ព្រៃវែង និងកំពង់ចាម )។ បន្ថែមពីនេះ ក្រសួងបានសម្របសម្រួល ដល់សហគមន៍កសិកម្មទំនើបចំនួន ១០ បានទទួលបានប្រាក់កម្ចីពីធនាគាររីង ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម (ARDB) និងធនាគារ FTB សរុបជាទឹកប្រាក់ចំនួនប្រមាណ ៣ ៦៦២ ០០០ ដុល្លារអាម៉េរិកក្នុងអត្រាការប្រាក់រង្វង់៨% ក្នុងមួយឆ្នាំ និងសហគមន៍កសិកម្មទំនើប គ្រោងនឹងខ្ចីឥណទានពីធានាគារចំនួនប្រមាណ ៨ ៦៩៤ ៩៩៧ដុល្លារអាម៉េរិក ដើម្បីអនុវត្តផែនការអាជីវកម្មរបស់ខ្លួន។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានសម្រេចជាគោលការណ៍ផ្តល់ឥណទានពិសេស ចំនួន ៣៥លានដុល្លារអាម៉េរិក សម្រាប់រយៈពេល៣ឆ្នាំគឺ២០២៥-២០២៧ និងធនាគារ FTB ធនាគារជីបម៉ុង និង ធនាគាររីង បានរក្សាទំហំឥណទានប្រមាណ ២៥លានដុល្លារអាម៉េរិក ដើម្បីផ្តល់ឥណទានដល់សហគមន៍កសិកម្មទំនើប។

រហូតមកដល់ពេលនេះ ក្រុមការងារនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចុះពន្យល់ផ្សព្វផ្សាយដោយ ផ្ទាល់ពីទស្សនទាននៃសហគមន៍កសិកម្មទំនើប ជូនដល់ប្រជាកសិករជាច្រើនម៉ឺននាក់នៅទូទាំងប្រទេស។

## ៤. លទ្ធផលជារួម

ក្នុងឆ្នាំកន្លងទៅ ទឹកភ្លៀងបានចាប់ផ្តើមធ្លាក់តាំងពីដើមរដូវវស្សា នៅតាមបណ្តាខេត្តមួយចំនួនក្នុងប្រទេស និង បានបន្តធ្លាក់យ៉ាងច្រើនក្នុងអំឡុងខែមិថុនា និងតុលា ដែលបង្កឱ្យមានជំនន់ទឹកភ្លៀង និងបណ្តាលឱ្យប៉ះពាល់ និង ខូចខាតផលិតកម្មដំណាំ ជាពិសេសដំណាំស្រូវ និងដំណាំឧស្សាហកម្មមួយចំនួន។ ទោះបីជាជួបគ្រោះធម្មជាតិក្តី វិស័យកសិកម្មនៅតែឈររឹងមាំ និងបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សាបាននូវសន្តិសុខស្បៀង តាមរយៈការផ្គត់ផ្គង់ ស្បៀងអាហារ អង្ករ បន្លែ ត្រី និងសាច់ បានគ្រប់គ្រាន់នៅក្នុងប្រទេស និងនៅសល់សម្រាប់នាំចេញទៅកាន់ទីផ្សារ អន្តរជាតិទៀតផង។

### ៤.១ ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ

ឆ្នាំ២០២៥ វិស័យកសិកម្មបានចូលរួមចំណែកប្រមាណ ១៦,១% (គិតជាតម្លៃបច្ចុប្បន្ន) ក្នុងផលិតផលសរុប ក្នុងស្រុក ដោយមានការផ្លាស់ប្តូរឆ្នាំគោល២០០០ មកឆ្នាំ២០១៤។ គិតជាតម្លៃថេរ វិស័យកសិកម្មបានចូលរួម ចំណែកប្រមាណ ១៣,៦% នៃផលិតផលសរុបក្នុងស្រុកឆ្នាំ២០២៥។

**ក្រាហ្វិកទី១៖ ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិឆ្នាំ២០២១-២០២៥**




ប្រភព៖ ក្រសួងផែនការឆ្នាំ២០២៥ (ទិន្នន័យបឋម)

បើទោះជាការចូលរួមចំណែករបស់វិស័យកសិកម្ម មានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំយ៉ាងនេះក្តី តែតម្លៃបន្ថែមសរុបនៃវិស័យកសិកម្ម (Gross Value Added in Agriculture) មានការកើនឡើងជារៀងរាល់ឆ្នាំពី ២០ ៣៨០ ពាន់លានរៀល នៅឆ្នាំ២០១៦ ដល់ ដល់ ៣៣ ១៤៩ពាន់លានរៀល នៅឆ្នាំ២០២៥ (គិតជាតម្លៃបច្ចុប្បន្ន)។

**ក្រាហ្វិកទី២៖ កំណើនតម្លៃបន្ថែមសរុបនៃវិស័យកសិកម្ម ២០១៦-២០២៥**




ប្រភព៖ ក្រសួងផែនការឆ្នាំ២០២៥ (ទិន្នន័យបឋម)

## ៤.២ កំណើនវិស័យកសិកម្ម

កំណើនវិស័យកសិកម្មមានការប្រែប្រួលជាមធ្យម ក្នុងចន្លោះពី ១,៣% ទៅ ១,១% ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៨ (គិតជាតម្លៃថេរ) ដែលបញ្ជាក់ពីការចូលរួមចំណែកជាវិជ្ជមានរបស់វិស័យកសិកម្ម ក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ នៅចន្លោះឆ្នាំ២០២១-២០២៥ វិស័យកសិកម្មកម្ពុជានៅតែរក្សាបាននូវកំណើនវិជ្ជមានក្នុងចន្លោះ ១,៥% ទៅ ១,២%។

### ក្រាហ្វិកទី៣៖ កំណើនវិស័យកសិកម្ម (តម្លៃថេរ) ឆ្នាំ២០១៦-២០២៥




ប្រភព៖ ក្រសួងផែនការឆ្នាំ២០២៥ (ទិន្នន័យបឋម)

## ៤.៣ ការចូលរួមចំណែករបស់អនុវិស័យនានាក្នុងវិស័យកសិកម្ម

ការចូលរួមចំណែករបស់អនុវិស័យនានាក្នុងវិស័យកសិកម្មរួមមាន ផ្នែកដំណាំបានចូលរួមចំណែកប្រមាណ ៦១,២% ផ្នែកផលិតកម្មសត្វ ១៥,៥% ផ្នែកជលផល ២០,៣% និងផ្នែកព្រៃឈើ ៣,០%។ ផលិតកម្មកសិកម្មស្រូវ ដំណាំរួមផ្សំ ឈើហូបផ្លែ បន្លែ ត្រី សាច់សត្វ មានលទ្ធភាពគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងអាចធានាបាននូវសន្តិសុខស្បៀងសម្រាប់ប្រជាពលរដ្ឋ ព្រមទាំងបន្តការនាំចេញផលិតផលកសិកម្មទៅក្រៅប្រទេស។

### ក្រាហ្វិកទី៤៖ ការចូលរួមចំណែករបស់អនុវិស័យក្នុងនានាវិស័យកសិកម្មឆ្នាំ២០២១-២០២៥ (គិតជាតម្លៃបច្ចុប្បន្ន)




| | 2021 | 2022 | 2023 | 2024 | 2025 |
|---|---|---|---|---|---|
| ដំណាំ | 60.4% | 60.1% | 61.1% | 61.3% | 61.2% |
| បសុសត្វនិងបសុបក្សី | 15.6% | 15.6% | 15.5% | 15.4% | 15.5% |
| ជលផល | 19.9% | 20.2% | 19.8% | 20.0% | 20.3% |
| ព្រៃឈើ | 4.1% | 4.1% | 3.6% | 3.3% | 3.0% |

ប្រភព៖ ក្រសួងផែនការឆ្នាំ២០២៥ (ទិន្នន័យបឋម)

# ៥. លទ្ធផលតាមអនុវិស័យ និងផ្នែកផ្សេងៗ

## ៥.១ ការងារបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិធុរកិច្ច

### ក. ផលិតកម្មដំណាំស្រូវ

ក្នុងទិសដៅរួមចំណែកកាត់បន្ថយថ្លៃដើមផលិត និងបង្កើនប្រាក់ចំណូលជូនប្រជាកសិករ ក្រសួងបានរៀបចំឱ្យមានប្រព័ន្ធផលិតកម្មគ្រាប់ពូជស្រូវជាក់លាក់ដើម្បីធានាបរិមាណ និងគុណភាពស្រូវ-អង្ករសម្រាប់ការប្រើប្រាស់ក្នុងស្រុក និងការនាំចេញ បានរៀបចំឱ្យមានពិសោធន៍ ស្រាវជ្រាវ និងអភិវឌ្ឍពូជ ផ្សព្វផ្សាយបង្ហុំបច្ចេកទេសផលិតកម្មដំណាំស្រូវ និងជំរុញកសិករប្រើប្រាស់គ្រាប់ពូជស្រូវសុទ្ធ មានគុណភាពនិងតម្រូវការទីផ្សារ ដូចជា ពូជផ្ការំដួល និងសែនក្រអូប ជាដើម។

ជាក់ស្ដែងក្នុងឆ្នាំ២០២៥នេះ ផ្ទៃដីដាំស្រូវសរុបទូទាំងប្រទេសសម្រេចបានចំនួន ៤,០៨លានហិកតា (ស្រូវប្រាំងចំនួន ០,៩១លានហិកតា និងស្រូវវស្សាចំនួន ៣,១៨លានហិកតា) កើនឡើងចំនួន ២២៧ ៨៧៤ហិកតា ស្មើនឹង ៥,៩១% ធៀបឆ្នាំ២០២៤។ ផ្ទៃដីប្រមូលផលបានចំនួន ៤,០៤លានហិកតា កើនឡើងចំនួន ២២៦ ៩៥៥ហិកតា ស្មើនឹង ៥,៩៤% ធៀបឆ្នាំ២០២៤។ ផ្ទៃដីដាំដុះកើនឡើងដោយសារកសិករបង្កើនរដូវដាំដុះដោយប្រើប្រាស់ពូជស្រូវស្រាលអាយុកាលខ្លីមិនប្រកាន់រដូវ បានផលចំណេញច្រើនបំពេញតាមតម្រូវការទីផ្សារ និងភាពរីកចម្រើនប្រព័ន្ធស្រោចស្រព។ បរិមាណផលស្រូវសរុបទទួលបានចំនួន ១៥,០៩លានតោន (ស្រូវប្រាំងចំនួន ៤,២៥លានតោន និងស្រូវវស្សាចំនួន ១០,៨៤លានតោន) កើនឡើងចំនួន ១,២០លានតោន ស្មើនឹង ៨,៦៥% ធៀបឆ្នាំ២០២៤។

ទិន្នផលស្រូវជាមធ្យមប្រចាំឆ្នាំសម្រេចបាន ៣,៧៣៥តោនក្នុងមួយហិកតា កើនឡើង ៩៣គីឡូក្រាម/ហិកតា ធៀបនឹងឆ្នាំ២០២៤។ តាមការវាយតម្លៃតុល្យភាពស្បៀង កម្ពុជាមានអតិរេកស្រូវចំនួនជាង ៩,១៥លានតោន និងគិតជាអង្ករ ៥,៨៦លានតោន ដែលអាចសន្និដ្ឋានបានថា កម្ពុជាធានាបាននូវសន្តិសុខស្បៀង និងសល់សម្រាប់នាំចេញ។

ជាមួយគ្នានេះ ក្រសួងបានដោះស្រាយដោយជោគជ័យនូវបញ្ហាធ្លាក់ចុះតម្លៃស្រូវដែលបណ្ដាលមកពីការធ្លាក់ចុះតម្លៃអង្ករជាសកល តាមរយៈការចាត់វិធានការបន្ទាន់ឱ្យថ្នាក់ដឹកនាំនិងមន្ត្រីជំនាញ ថ្នាក់ជាតិនិងក្រោមជាតិ ព្រមទាំងមន្ត្រីកសិកម្មឃុំទាំងអស់ ចុះសម្របសម្រួលផ្ទាល់ជាមួយម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងអ្នកប្រមូលទិញពីប្រជាកសិករក្នុងតម្លៃសមរម្យ ដើម្បីធានាមានទីផ្សារជានិច្ច និងមិនបណ្ដោយឱ្យស្រូវទុកចោលខូចខាតនោះទេ។

ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ជាមធ្យមប្រចាំឆ្នាំ ផ្ទៃដីដាំស្រូវកើនឡើងចំនួន ៣,៥៥% ផ្ទៃដីប្រមូលផលកើនឡើងចំនួន ៣,៦៧% បរិមាណផលស្រូវកើនឡើងចំនួន ៥,៤៥% និងទិន្នផលស្រូវកើនឡើងចំនួន ១,៧១%។

**ក្រាហ្វិកទី៥៖ ផលិតកម្មដំណាំស្រូវឆ្នាំ២០២១-២០២៥**



ទន្ទឹមនឹងនេះ កម្ពុជាបានទទួលរងនូវគ្រោះរាំងស្ងួត ទឹកជំនន់ និងការបំផ្លាញពីសត្វល្អិតចង្រៃលើដំណាំដែលបណ្តាលឱ្យប៉ះពាល់ដាំណាំសរុបចំនួន ២៤០ ៤៧១ហិកតា ខូចខាតសរុបចំនួន ៥១ ៦១២ហិកតា (២១,៤៦% នៃផ្ទៃដីរងការប៉ះពាល់) ក្នុងនោះ ដំណាំស្រូវប៉ះពាល់ចំនួន ២១៥ ០៩៣ហិកតា ស្មើនឹង ៥,២៧% និងខូចខាតចំនួន ៤៣ ៣៧២ហិកតា ស្មើនឹង ១,០៦% នៃផ្ទៃដីដាំដុះទូទាំងប្រទេស។

### ខ. ផលិតកម្មដំណាំស្បៀងរួមផ្សំ

ផលិតកម្មដំណាំស្បៀងរួមផ្សំសរុបសម្រេចបាននៅលើផ្ទៃដីចំនួន ៣៣៩ ៦៩៦ហិកតា និងទទួលបានបរិមាណផលចំនួន ៤ ៩៣៩ ០៤៣តោន ក្នុងនោះមាន៖

- ផ្ទៃដីដាំដំណាំស្បៀងរួមផ្សំរយៈពេលខ្លី (បន្លែ ដំណាំហូបផ្លែរយៈពេលខ្លី និងរុក្ខជាតិលម្អ) មានចំនួន ៨២ ៨៧៨ ហិកតា ថយចុះចំនួន ១ ៥៧២ហិកតា ធៀបឆ្នាំ២០២៤ ដោយមានផ្ទៃដីប្រមូលផលចំនួន ៨២ ៦៤៩ហិកតា និងផ្តល់បរិមាណផលសរុបចំនួន ១ ៣២១ ៨៤១តោន តិចជាងឆ្នាំមុនចំនួន ៤៦ ៦៩៧តោន
- ផ្ទៃដីដាំដំណាំស្បៀងរួមផ្សំរយៈពេលវែង (ដំណាំហូបផ្លែរយៈពេលវែង) មានចំនួន ២៥៦ ៨១៨ហិកតា ក្នុងនោះ ដំណាំកំពុងផ្តល់ផលមានចំនួន ១៩៧ ៤២៨ហិកតា ផ្តល់បរិមាណផលសរុបចំនួន ៣ ៦១៧ ២០២តោន។ ដំណាំស្បៀងរួមផ្សំរយៈពេលវែងសំខាន់ៗ រួមមាន៖
  - ផ្ទៃដីដាំដុះដំណាំចេកមានចំនួន ៦៩ ៧៣៧ហិកតា ផ្តល់បរិមាណផលចំនួន ១ ០៦៨ ៥០៧តោន ក្នុងនោះ ចេកអំបូងលឿងចំនួន ៣៥ ៧៩៩ហិកតា ផ្តល់បរិមាណផលចំនួន ៤៨៤ ១៩៤តោន
  - ផ្ទៃដីដាំដុះដំណាំស្វាយមានចំនួន ១៤១ ៦២៧ហិកតា ផ្តល់បរិមាណផលចំនួន ២ ០៩៦ ៨២៣តោន
  - ផ្ទៃដីដាំដុះដំណាំមៀន/មៀនប៉ៃលិនមានចំនួន ១៤ ៨០៨ហិកតា ផ្តល់ផលចំនួន ១៤១ ៣១៧តោន
  - ផ្ទៃដីដាំដុះដំណាំទុរេនមានចំនួន ១៦ ១៩៣ហិកតា ផ្តល់ផលចំនួន ១៣៥ ៥៤៦តោន។

ទន្ទឹមនឹងការទទួលបានលទ្ធផលជាផ្លែផ្កានេះ ផ្ទៃដីដំណាំស្បៀងរួមផ្សំសរុបចំនួន ៤ ៩៥០ហិកតា បានរងការប៉ះពាល់ដោយគ្រោះធម្មជាតិ និងសត្វល្អិតចង្រៃ ដែលធ្វើឱ្យខូចខាតចំនួន ១ ៨៦៥ហិកតា។

ជារួម ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ផ្ទៃដីដំណាំស្បៀងរួមផ្សំ កើនជាមធ្យមប្រចាំឆ្នាំចំនួន ២,៤៥% ផ្ទៃដីប្រមូលផលកើន ២,៥២% និងបរិមាណផលកើន ៣,១៣%។

**ក្រាហ្វិកទី៦៖ ផលិតកម្មដំណាំស្បៀងរួមផ្សំឆ្នាំ២០២១-២០២៥**



គ. ផលិតកម្មដំណាំទ្រទ្រង់សេដ្ឋកិច្ច

ផលិតកម្មដំណាំទ្រទ្រង់សេដ្ឋកិច្ចសម្រេចបានលើផ្ទៃដីសរុបចំនួន ១ ៨៣០ ៤៩៩ហិកតា ដែលមានផ្ទៃដីប្រមូលផលចំនួន ១ ៧៦២ ១៩៨ហិកតា និងទទួលបានបរិមាណផលចំនួន ២០ ៣៣២ ៤២៥តោន កើនឡើងចំនួន ២៨០ ៤០៦តោន ស្មើនឹង ១,៤០% ធៀបឆ្នាំ២០២៤ ក្នុងនោះ៖

- ផ្ទៃដីផលិតកម្មដំណាំទ្រទ្រង់សេដ្ឋកិច្ចរយៈពេលខ្លីសម្រេចបានចំនួន ១ ០៩២ ៦១០ហិកតា ដែលមានផ្ទៃដីប្រមូលផលចំនួន ១ ០៨៦ ១៤៨ហិកតា និងបរិមាណផលចំនួន ១៧ ៥៥៦ ៦០៧តោន ក្នុងនោះ៖
  - ផ្ទៃដីដាំដុះដំឡូងមីមានចំនួន ៧៧៤ ៨៤៣ហិកតា ថយចុះ ៣៣ ១១៧ហិកតា ផ្តល់បរិមាណផលសរុបចំនួន ១៥ ៩៥៥ ៣៥៧តោន
  - ផ្ទៃដីដាំដុះពោតក្រហមចំនួន ២២៣ ៤២៧ហិកតា កើនឡើង ២៦ ០៦៦ហិកតា ផ្តល់បរិមាណផលចំនួន ១ ៣៦៣ ១២៣តោន។
- ផ្ទៃដីដាំដុះដំណាំទ្រទ្រង់សេដ្ឋកិច្ចរយៈពេលវែងសម្រេចបានចំនួន ៧៣៧ ៨៨៩ហិកតា និងផ្តល់បរិមាណផលចំនួន ២ ៧៧៥ ៨១៨តោន ក្នុងនោះ ដំណាំសំខាន់ៗ រួមមាន៖
  - ផ្ទៃដីដាំដុះស្វាយចន្ទីមានចំនួន ៦៥០ ០១៨ហិកតា ផ្តល់បរិមាណផលចំនួន ៨៦៨ ៤២០តោន
  - ផ្ទៃដីដាំដុះអំពៅមានចំនួន ៣៦ ៩៩៥ហិកតា ផ្តល់បរិមាណផលចំនួន ១ ១៣៩ ៧១៩តោន
  - ផ្ទៃដីដាំដុះម្រេចមានចំនួន ៧ ១០៦ហិកតា ផ្តល់បរិមាណផលចំនួន ១៥ ៧៥៧តោន
  - ផ្ទៃដីដាំដុះដូងប្រេងមានចំនួន ២២ ៥៩០ហិកតា ផ្តល់បរិមាណផលចំនួន ៣៩២ ៦៨៨តោន។

ក្នុងឆ្នាំ២០២៥ ផ្ទៃដីដំណាំទ្រទ្រង់សេដ្ឋកិច្ចចំនួន ២០ ៤២៨ហិកតា បានរងការប៉ះពាល់ដោយគ្រោះធម្មជាតិ និងសត្វល្អិតចង្រៃ ដែលធ្វើឱ្យខូចខាតចំនួន ៦ ៣៧៥ហិកតា។

ជារួម រយៈពេល៥ឆ្នាំចុងក្រោយនេះ ផ្ទៃដីដាំដុះដំណាំទ្រទ្រង់សេដ្ឋកិច្ច កើនជាមធ្យមប្រចាំឆ្នាំចំនួន ៥,៩៣% ផ្ទៃដីផ្តល់ផលបានកើន ៧,៨៩% និងបរិមាណផលបានកើន ១,៥០%។

**ក្រាហ្វិកទី៧៖ ផលិតកម្មដំណាំទ្រទ្រង់សេដ្ឋកិច្ចឆ្នាំ២០២១-២០២៥**




ឆ្នាំ២០២៥ នេះ ផ្ទៃដីដាំដុះដំណាំស្វាយចន្ទីសរុបប្រមាណជាង ៦៥០ ០១៨ហិកតា ស្ថិតនៅក្នុងខេត្តចំនួន ២៣ ទូទាំងប្រទេស និងទទួលបានបរិមាណផលសរុបចំនួន ៨៦៨ ៤២០តោន ក្នុងនោះបាននាំចេញសរុបចំនួន

៦៣៦ ៨៦៧តោន។ ទន្ទឹមនេះ ផលិតផលគ្រាប់ស្វាយចន្ទីបានកែច្នៃប្រមាណ១០% នៃបរិមាណផលសរុប និង៩០% ដែលនៅសល់ត្រូវបាននាំចេញជាផលិតផលស្រស់ទៅកាន់ប្រទេសផ្សេងទៀត ជាពិសេសទៅកាន់ប្រទេសវៀតណាម។ លើសពីនេះទៀត កម្ពុជាជាប់ចំណាត់ថ្នាក់ជាប្រទេសមួយក្នុងចំណោមប្រទេសទាំង ១០ ដែលផលិតគ្រាប់ស្វាយចន្ទីនៅលើពិភពលោក។

**ក្រាហ្វិកទី៨៖ ផលិតកម្មដំណាំស្វាយចន្ទីឆ្នាំ ២០២៥**




## ឃ. ផលិតកម្ម និងការគ្រប់គ្រងពូជដំណាំ

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- ក្របខ័ណ្ឌប្រព័ន្ធស្បៀងបម្រុងកម្ពុជា បានផលិតពូជស្រូវចំនួន ២ ០០០តោន សម្រាប់អន្តរាគមន៍ដាំដុះស្តារឡើងវិញក្រោយពេលគ្រោះធម្មជាតិ
- បានសិក្សាពីភាពចម្រុះពន្ធុឬគម្លាតសេណេទិចដំណាំចំនួន ៣២ មុខ ដែលរួមមានពូជស្រូវចំនួន ១១ ពូជ បន្លែចំនួន ១១ ពូជ និងដំណាំហូបផ្លែ ចំនួន ១០ មុខ។ បានប្រមូល និងវិភាគទិន្នន័យលើពូជដំណាំប្រពៃណីចំនួន ៣០ មុខ គឺស្រូវចំនួន ៩ ពូជ បន្លែចំនួន ១០ ពូជ ដំណាំហូបផ្លែ ចំនួន ៧ ពូជ និងដំណាំឧស្សាហកម្មចំនួន ៤ មុខ ដោយចងក្រងឯកសារសម្រាប់ការចុះបញ្ជីជាពូជដំណាំជាតិ។
- បានរៀបចំច្បារពូជដំណាំមនចំនួន ២,២ហិកតា និងកូនមនចំនួន ៦ ០០០កូន នៅឃុំលើកដែក ស្រុកកៀនស្វាយ និងបានជ្រើសរើសនិងរៀបចំច្បារពូជដំណាំហូបផ្លែដែលមានសក្តានុពលចំនួន ១០ពូជ ក្នុងនោះមានទុរេន ២ពូជ ប៉័រ ១ពូជ ស្វាយ ៣ពូជ មៀន ២ពូជ ក្រូចថ្លុង ១ពូជ និងខ្នុរ ១ពូជ ក្នុងខេត្តកណ្តាល
- បានដាំរក្សាពូជដំណាំឧស្សាហកម្មចំនួន ០៥ពូជ ដូចជា ដំណាំកប្បាស សណ្តែកសៀង សណ្តែកបាយ មន និងដំណាំម្រេច និងចិញ្ចឹមរក្សាពូជដង្កូវនាង និងបានធ្វើផលិតកម្មដំណាំដំឡូងមីគ្មានជំងឺចំនួន ១៥ហិកតា នៅស្រុកចម្ការលើ ខេត្តកំពង់ចាម
- បានដាំរក្សាពូជម្រេចចំនួន ៣០០ជន្លង់ និងស្វាយចន្ទីចំនួន ៥២០ដើម នៅខេត្តព្រះសីហនុ
- បានអភិរក្សពូជដំណាំហូបផ្លែនិងរុក្ខជាតិលម្អ ចំនួន ៦៥ពូជ ក្នុងនោះរួមមាន ស្វាយ ២ពូជ ចេកណាំវ៉ា ១ពូជ ចេកអំបូង ១ពូជ ចេកក្រមួន ១ពូជ អន្ស៊ែ ១ពូជ ផ្កាគ្រីហ្សង់តែម ១ពូជ ស្លាលម្អ ១ពូជ ដូងតាំង ១ពូជ ម្ទេសលម្អ ៥ពូជ ពោតបារាំង ៩ពូជ និងប៉េងប៉ោះ ៤២ពូជ

- បានធ្វើការវេចខ្ចប់និងប្រគល់គ្រាប់ពូជបន្លែនិងដំណាំរួមផ្សំសរុបចំនួន ៥២,៧៤តោន ជូនប្រព័ន្ធស្បៀងបម្រុងកម្ពុជា ដើម្បីចែកជូនគ្រួសារប្រជាជន អតីតយុទ្ធជន សាលារៀន និងនៅតាមទីវត្តអារាម ដែលមានតម្រូវការដាំដុះសរុបចំនួន ១៩២ ២២៣គ្រួសារ ក្នុងខេត្តចំនួន ១០ ព្រមទាំងបានចែកជូនគ្រាប់ពូជបន្លែចំនួន ១៩ ៥០០កញ្ចប់ ស្មើនឹង ១ ០៧៥គ.ក្រ ដល់តំបន់ជនភៀសសឹកនៅតាមព្រំដែនកម្ពុជា-ថៃ សម្រាប់ដាំដុះ
- បានបញ្ចេញប្រភេទពូជដំណាំចំនួន ៤ប្រភេទ រួមមាន ពូជស្រូវស្រងែក្រអូប ពូជដំឡូងមីស៊ី ស៊ី ០១ ពូជប៉េងប៉ោះធីរី ស៊ី ធី២៥ និងពូជកៅស៊ូស្លូក្លូន CRRI3
- បានផលិតគ្រាប់ពូជពោតអ៊ីប្រ៊ីដ CHM01 លើផ្ទៃដីចំនួន ៥ហិកតា ជាប្រភេទពូជផ្តល់ទិន្នផលខ្ពស់ និងធន់ទ្រាំជំងឺបួស (Downy Mildew)។ ជាលទ្ធផល មានការដុះលូតលាស់បានល្អ មានភាពធន់នឹងជំងឺ និងទទួលបានបរិមាណផលសរុបចំនួន ៦,៧តោនលើផ្ទៃដីចំនួន ៥ហិតកា (ទិន្នផល ១,៣៤តោន/ហិកតា)។ ជាមួយគ្នានេះ ក៏បានផលិតគ្រាប់ពូជពោតអ៊ីប្រ៊ីដ CHM-01 (3:1) លើផ្ទៃដីចំនួន ១,២ហិកតា ដែលជាលទ្ធផលទទួលបានបរិមាណផលសរុបចំនួន  ១,៨តោន លើផ្ទៃដីចំនួន ១,២ហិកតា (ទិន្នផល ១,៥តោន/ហិកតា)
- បានដាំពង្រីកគ្រាប់ពូជពោតក្រហមជាពូជមេបា  ដើម្បីពង្រីកនិងអភិរក្សពូជសុទ្ធលើផ្ទៃដីចំនួន  ០,៨ហិកតា ដោយទទួលបានដើមពោតសរុបចំនួន ១៣ ០៨០ដើម និងផ្លែចំនួន ១១ ៩៣០ផ្លែ
- បានដាំអភិរក្សប្រភេទពូជពោតក្រហម ពោតដំណើប និងពោតខ្មៅ ក្នុងបំណងដើម្បីតាមដានពីភាពធន់នឹងជំងឺបន្សុទ្ធ និងឯកសណ្ឋានភាព ដោយទទួលបានពូជពោតសរុបចំនួន ១ ៤៦៥ពូជ ក្នុងនោះ ពូជពោតក្រហមចំនួន ៥០៧ពូជ ពោតដំណើបចំនួន ៤៥៦ពូជ និងពោតខ្មៅចំនួន ៥០២ពូជ។

## ង. ការពិសោធន៍ស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជាសម្រេចបានលទ្ធផលសំខាន់ៗដូចខាងក្រោម៖

- ការងារអភិរក្សនិងសមូហកម្មពូជដំណាំ ដោយបានប្រមូលប្រភេទពូជដំណាំថ្មីៗចំនួន ២០ប្រភេទ ស្មើនឹង ២១៤សំណាក ដែលមានពពួកបន្លែ ១៧០សំណាក និងធញ្ញជាតិ ៤៤សំណាក បានធ្វើយុវកម្មលើដំណាំស្រូវចំនួន ១ ០៣០បញ្ជីក ប៉េងប៉ោះចំនួន ១៨បញ្ជីក និងពោតចំនួន ២៤បញ្ជីក និងបានដាំវាយតម្លៃនិងកំណត់លក្ខណៈពូជដំណាំ ៣មុខ រួមមានត្រសក់ស្រូវ ល្ពៅ និងត្រប់ ស្មើនឹង ៧២សំណាក។ បច្ចុប្បន្ន ពូជដំណាំចំនួន ៣៩មុខឬប្រភេទ ស្មើនឹង ៩ ៩៨៦បញ្ជីក/សំណាក បាននិងកំពុងអភិរក្សនៅក្នុងធនាគារពន្ធុរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា។
- ការងារបសិដ្ឋកម្មពូជ បានធ្វើពិសោធន៍ និងស្រែបង្ហាញលើស្រឡាយស្រូវ និងដំណាំផ្សេងៗដែលមានទិន្នផលខ្ពស់ គុណភាពល្អ ធន់នឹងប្រែប្រួលអាកាសធាតុចំនួន ៣០ប្រភេទ ស្មើនឹង ១៨១ពិសោធន៍ ដែលមាន ៨៥០ស្រឡាយ។ ចំពោះការងារអភិវឌ្ឍពូជដំណាំ ក្រសួងបានធ្វើវិយោគកម្មកូនបង្កាត់ ជំនាន់ ទី២ ទី៣ ទី៤ ទី៥ ទី៦ និងទី៧ សរុបមាន ២២ប្រជាករ ក្នុងនោះ ១៥ប្រជាករត្រូវបានច្រូតកាត់ ហាលសម្ងួត រោយសម្អាត វេចខ្ចប់ និងស្តុកទុកក្នុងទូរត្រជាក់ ដោយឡែក សម្រាប់ដំណាំបន្លែបានធ្វើវិយោគកម្មកូនបង្កាត់ ដំណាំប៉េងប៉ោះជំនាន់ទី១ និងទី២ សរុប ៤ប្រជាករ នៅក្នុងផ្ទះសំណាញ់
- បានពិសោធន៍ដូចជា ឥទ្ធិពលនៃការស្រោចស្រពលើស្រូវប្រាំងនៅតំបន់ទំនាបអាស្រ័យទឹកភ្លៀង ឥទ្ធិពលរយៈពេលវែងនៃការប្រើប្រាស់ជី NPKនិងលាមកគោទៅលើគុណភាពដីនិងទិន្នផលស្រូវ ព្រមទាំងប្រសិទ្ធភាពនៃការប្រើប្រាស់ជី NPK ទៅលើការដុះលូតលាស់និងទិន្នផលដំណាំដំឡូងមី វិធានការគ្រប់គ្រងសត្វល្អិតចង្រៃលើដំណាំពោត និងបង្ហុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវរដូវវស្សា។

### ច. ការបង្កើត និងចុះបញ្ជីសហគមន៍កសិកម្ម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំពុងប្រែក្លាយវិស័យកសិកម្មកម្ពុជាពីលក្ខណៈគ្រួសារទៅជាសហគ្រាសសេដ្ឋកិច្ចកសិកម្មដ៏រឹងមាំ ដោយបានបង្កើតសហគមន៍កសិកម្មទំនើប ដែលកំពុងតែផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ប្រជាកសិករ រួមមានការកាត់បន្ថយថ្លៃដើមផលិតកម្ម ការទទួលបានកម្ចីឥណទានការប្រាក់ទាប ការគាំទ្រខាងផ្នែកបច្ចេកទេស និងជាពិសេសការតភ្ជាប់ទីផ្សារទុកជាមុន តាមរយៈកិច្ចសន្យាផលិតកម្ម ដែលបានការពារបងប្អូនកសិករពីហានិភ័យនៃការប្រែប្រួលថ្លៃប្រកបដោយប្រសិទ្ធភាព។ គិតត្រឹមឆ្នាំ២០២៥ សហគមន៍កសិកម្មសរុបចំនួន ១ ៤៧៦ ត្រូវបានបង្កើតទូទាំងប្រទេស និងមានដើមទុនសរុបចំនួន ១៩៥ ៦៨០ ៣៤១ ៤២៨ រៀល។

**ក្រាហ្វិកទី៩៖ ចំនួនសហគមន៍កសិកម្មតាមបណ្តាខេត្តឆ្នាំ ២០២៥**




### ឆ. ការងារអភិវឌ្ឍសហគមន៍កសិកម្មទំនើប

ការកសាងសហគមន៍កសិកម្មទំនើប គឺដើម្បីប្រែក្លាយវិស័យកសិកម្មពីលក្ខណៈគ្រួសារទៅជាសហគ្រាសសេដ្ឋកិច្ចដ៏រឹងមាំ មានសមារណេកម្មខ្ពស់ មានសេដ្ឋកិច្ចមាត្រដ្ឋាន និងមានសមត្ថភាពប្រកួតប្រជែងទាំងបរិមាណនិងគុណភាព។

**១. ការបង្កើតសហគមន៍កសិកម្មទំនើប**

បច្ចុប្បន្នមានសហគមន៍កសិកម្មទំនើបចំនួន ២៧សហគមន៍ ក្នុងខេត្តចំនួន១២ ផ្តោតលើដំណាំសំខាន់ៗចំនួន ៤ប្រភេទគឺដំណាំស្រូវ ស្វាយចន្ទី បន្លែ និងដំណាំម្រេច ដែលគ្របដណ្តប់លើផ្ទៃដីដាំដុះសរុបប្រមាណ ២៣ ៤៦១ហិកតា និងមានកសិករចូលរួមចំនួន ៣ ៥៨៥គ្រួសារ។

**២. ការគាំទ្រសហគមន៍កសិកម្មទំនើប**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើតក្រុមការងារគាំទ្របច្ចេកទេសគាំទ្រសហគមន៍កសិកម្មទំនើបចំនួន ៤ក្រុម គឺក្រុមការងារគាំទ្របច្ចេកទេសសហគមន៍កសិកម្មទំនើបម្រេច ស្វាយចន្ទី ដំណាំស្រូវ និងដំណាំបន្លែផ្ទះកញ្ចក់ត្រាំកក់ ព្រមទាំងបានចុះគាំទ្រដល់បច្ចេកទេសជាបន្តបន្ទាប់ ដែលរួមមាន ការផ្តល់ប្រឹក្សាបច្ចេកទេសអំពីការប្រើប្រាស់ជីនិងថ្នាំកសិកម្មតាមដំណាក់កាលនៃដំណាំ ការគាំទ្រក្នុងការសិក្សាអំពីប្រភេទដី និងវិភាគសំណាកដី និងការណែនាំបច្ចេកទេសការពារនិងកម្ចាត់សមាសភាពចង្រៃ។

ជាងនេះទៀត ក្រសួងក៏បានធ្វើការសម្របសម្រួលជាមួយស្ថាប័នហិរញ្ញវត្ថុដៃគូ ដើម្បីស្វែងរកប្រាក់កម្ចីដើមទុនដែលមានអត្រាការប្រាក់ទាបនិងមិនតម្រូវឱ្យមានទ្រព្យបញ្ចាំ។ ជាលទ្ធផល សហគមន៍កសិកម្មទំនើបចំនួន១៧ ដែលមានផែនការពង្រីកអាជីវកម្មច្បាស់លាស់ បានទទួលការគាំទ្រហិរញ្ញប្បទានពីធនាគាររីវីង និងធនាគារអភិវឌ្ឍន៍ជនបទ

និងកសិកម្ម និងធនាគារ FTB សរុបជាទឹកប្រាក់ចំនួនប្រមាណ ១៥ ៩៧០ ៨២៣ ដុល្លារអាម៉េរិក ក្នុងអត្រាការប្រាក់ ៨% ក្នុងមួយឆ្នាំ។

ដើម្បីបង្កើនការគាំទ្រដល់ការអភិវឌ្ឍសហគមន៍កសិកម្មទំនើប ក្រសួងក៏បានពង្រីកកិច្ចសហការជាមួយដៃគូពាក់ព័ន្ធជាច្រើន ក្នុងនោះ បានចុះអនុស្សរណៈយោគយល់គ្នាជាមួយស្ថាប័នមួយចំនួន មានក្រុមហ៊ុនបៃតងកម្ពុជា ក្រុមហ៊ុនវ៉េត អេហ្គ្រីនខលឈ័រអ៊ីមផត អេន អិច ផត ឯ.ក ក្រុមហ៊ុនត្រូពិកខេម ក្រុមហ៊ុមហួយន់ ក្រុមហ៊ុនគីរីទេស និងផ្សារដីបម៉ុង បានធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាទិញកសិផលពីសហគមន៍កសិកម្មទំនើបនៅកម្ពុជាផងដែរ។

លើសពីនេះ ក្រសួងក៏បានគៀរគរធនធានពីប្រភពផ្សេងៗជួយដល់សហគមន៍កសិកម្មទំនើប ដោយបានសម្របសម្រួលស្វែងរកដៃគូពាក់ព័ន្ធនិងគម្រោងជាច្រើនដូចជា កម្មវិធី ASPIRE-AT គម្រោង CAPRED គម្រោង CASDP គម្រោង ACSEP គម្រោង PEARL-PCRL សហគ្រិនខ្មែរ(Khmer Enterprise) និងគម្រោង DGRV ជាដើម។

ជាពិសេស ទំហំឥណទានសរុបចំនួនប្រមាណ ៦០ ០០០ ០០០ដុល្លារអាម៉េរិក ដែលក្នុងនោះរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចជាគោលការណ៍ផ្តល់ឥណទានពិសេសចំនួន ៣៥លានដុល្លារអាម៉េរិកក្នុងការផ្តល់ឥណទានដល់សហគមន៍កសិកម្មទំនើប រយៈពេល៣ឆ្នាំគឺ២០២៥-២០២៧ និងទំហំឥណទានប្រមាណ ២៥ ០០០ ០០០ដុល្លារអាម៉េរិក បានមកពីធនាគារ FTB ធនាគារដីបម៉ុង និងធនាគារវីង សម្រាប់ផ្តល់ជូនសហគមន៍កសិកម្មទំនើបខ្ចី។

### ជ. ការលើកកម្ពស់គុណភាព សុវត្ថិភាព និងការនាំចេញផលិតផលដំណាំកសិកម្ម

ក្នុងការលើកកម្ពស់គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម ក្រសួងបានចុះបញ្ជីចម្ការដំណាំបន្លែ និងដំណាំហូបផ្លែស្តីពីស្តង់ដានៃការអនុវត្តកសិកម្មល្អកម្ពុជា (CamGAP) ចំនួន ៧៥៣ចម្ការ ដើម្បីធានាសុវត្ថិភាពនិងគុណភាពសម្រាប់ប្រើប្រាស់ក្នុងស្រុកនិងការនាំចេញ ដោយបង្កើតឱ្យមានប្រព័ន្ធ QR Code ដើម្បីបញ្ជាក់និងតាមដានគុណភាពផលិតផលបន្លែនិងផ្លែឈើស្រស់នៅលើទីផ្សារ។ ជារួម គិតត្រឹមឆ្នាំ២០២៥ ការចុះបញ្ជីចម្ការនៃការអនុវត្តកសិកម្មល្អកម្ពុជាសរុបបានចំនួន ២ ១១២ចម្ការ លើមុខដំណាំចំនួន ១៥ប្រភេទ។ លើសពីនេះ ក្នុងឆ្នាំ២០២៥ ក្រសួងបានអនុវត្តសកម្មភាពចុះបញ្ជីជាចម្ការកសិកម្មសរីរាង្គកម្ពុជា (CamORG) បានចំនួន ១៣ចម្ការ លើដំណាំបន្លែ។ គិតពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៥ ការចុះបញ្ជីចម្ការនៃការអនុវត្តកសិកម្មសរីរាង្គសរុបបានចំនួន ១៩ចម្ការ លើមុខដំណាំបន្លែ។

ការនាំចេញកសិផលផ្លូវការផ្អែកលើប្រព័ន្ធទិន្នន័យគ្រឹះភូតគាមអនាម័យជាតិ មានចំនួន ១១៧មុខ ទៅកាន់ ៩៤ប្រទេស ដែលមានបរិមាណកសិផលសរុបចំនួន ១៤ ៩១០ ៤៨០តោន ក្នុងនោះ អង្ករចំនួន ៩៤០ ៣២១តោន ស្រូវចំនួន ៦ ៨៥៩ ៩៣០តោន និងកសិផលក្រៅពីស្រូវ-អង្ករចំនួន ៧ ១១០ ២២៩តោន។ ជារួមការនាំចេញកសិផលកើនឡើងចំនួន ២៧,២៨% បើធៀបនឹងឆ្នាំ២០២៤។ ទឹកប្រាក់ដែលទទួលបានពីការនាំចេញកសិផលមានចំនួន ៥ ០១៤លានដុល្លារអាម៉េរិក ក្នុងនោះ តម្លៃបានពីការនាំចេញផលិតផលដំណាំក្រៅពីស្រូវ-អង្ករមានចំនួន ២ ៨៨៩ លានដុល្លារអាម៉េរិក តម្លៃពីការនាំចេញស្រូវមានចំនួន ១ ៣៧៦លានដុល្លារអាម៉េរិក និងតម្លៃពីការនាំចេញអង្ករមានចំនួន ៧៤៩លានដុល្លារអាម៉េរិក។

ជារួម ការនាំចេញផលិតផលដំណាំសរុបក្នុងឆ្នាំ២០២៥ បានល្អប្រសើរ ដោយមានការកើនឡើងលើសឆ្នាំ២០២៤ ចំនួន ៣,២៤លានតោន ឬស្មើនឹង ២៧,៨៣% ក្នុងនោះការនាំចេញស្រូវកើនឡើងចំនួន ២,២៥លានតោន ការនាំចេញផលិតផលដំណាំក្រៅពីស្រូវ-អង្ករកើនឡើងចំនួន ០,៧លានតោន និងការនាំចេញអង្ករកើនឡើងចំនួន ០,២៩លានតោន។

ទោះបីមានកំណើននៃការនាំចេញចំនួន ២៧,៨៣% ក៏ផលិតផលដំណាំមួយចំនួនមានការថយចុះមួយផ្នែកធំ ដូចជា ការនាំចេញដំឡូងមីស្រស់មានការថយចុះ ពីព្រោះប្រជាកសិករបំប្លែងពីដំឡូងមីស្រស់ទៅក្រៀម និងកែច្នៃជាម្សៅ ដើម្បីអាចរក្សាទុកបានយូរ និងមានតម្លៃខ្ពស់។ ជាក់ស្តែង ក្នុងឆ្នាំ២០២៥នេះ ការនាំចេញដំឡូងមីក្រៀមកើនឡើងចំនួន ៦២,២២% និងម្សៅដំឡូងមីកើនឡើងចំនួន ៧៥,២៣% បើធៀបនឹងឆ្នាំ២០២៤។

ក្រសួងបានសម្របសម្រួលឱ្យមានការចុះហត្ថលេខាលើពិធីសាររវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៃព្រះរាជាណាចក្រកម្ពុជា និងអគ្គរដ្ឋបាលគយនៃសាធារណរដ្ឋប្រជាមានិតចិនស្តីពី លក្ខខណ្ឌតម្រូវភូតគាមអនាម័យសម្រាប់នាំចេញផ្លែទុរេនស្រស់កម្ពុជាទៅកាន់ប្រទេសចិន ព្រមទាំងបាននិងកំពុងធ្វើបន្តចរចាបើកទីផ្សារនាំចេញ

ផលិតផលកសិកម្ម រួមមាន៖ ផ្លែទុរេនស្រស់ទៅប្រទេសវៀតណាម ផ្លែស្វាយស្រស់ទៅសហរដ្ឋអាម៉េរិក និងប្រទេសជប៉ុន មានផ្លែមៀនសម្ងួត អង្ករសម្រូប ទុរេនបង្អក ផ្លែម្នាស់ស្រស់ និងផ្លែខ្នុរស្រស់ទៅប្រទេសចិន និងផ្លែមៀនទៅប្រទេសថៃ។

គិតត្រឹមឆ្នាំ២០២៥នេះ សមិទ្ធផលនៃការចរចាលក្ខខណ្ឌតម្រូវភូតគាមអនាម័យសម្រាប់ការបើកទីផ្សារនាំចេញផលិតផលកសិកម្មកម្ពុជាទៅកាន់ ១) ប្រទេសចិន រួមមាន៖ អង្ករនិងកញ្ចុងអង្ករ ចំណិតដំឡូងមី គ្រាប់ពោត ផ្លែចេកស្រស់ ស្វាយស្រស់ មៀនស្រស់ ម្រេច ដូងស្រស់ និងផ្លែទុរេនស្រស់ ២) សាធារណរដ្ឋកូរ៉េ រួមមាន៖ ផ្លែស្វាយស្រស់ ៣) ប្រទេសវៀតណាមរួមមាន៖ ផ្លែស្វាយ ចេក ស្រកានាគ ខ្នុរ ត្រប់ែក ក្រូចថ្លុង និងផ្លែមៀន និង ៤) ប្រទេសថៃ គឺផ្លែស្វាយស្រស់។

**ក្រាហ្វិកទី១០៖ ការនាំចេញផលិតផលដំណាំកសិកម្មឆ្នាំ២០២១-២០២៥**




ឈ. ការគ្រប់គ្រងធាតុចូលកសិកម្ម

**១. ការគ្រប់គ្រងថ្នាំកសិកម្ម**

ក្រសួងបាន (១)បានទទួលសំណើសុំចុះបញ្ជិកាថ្នាំកសិកម្មពីក្រុមហ៊ុនលក់ថ្នាំកសិកម្ម និងចែកចាយសម្ភារៈកសិកម្ម បានចំនួន ១៣៩ ក្រុមហ៊ុន ដែលមាន ៦ប្រភេទថ្នាំកសិកម្ម ស្មើនឹង ២ ៣១៩យថាប្រភេទ (២)បានទទួលសំណើសុំនាំចូលថ្នាំកសិកម្ម ពីក្រុមហ៊ុនលក់ថ្នាំកសិកម្មចំនួន ១៥២ក្រុមហ៊ុន ដែលមានចំនួន ៦ប្រភេទថ្នាំកសិកម្ម ស្មើនឹង ៤ ៨៣១យថាប្រភេទ ដែលមានបរិមាណសរុបចំនួន ១៧០ ១៨៧,៣តោន និង(៣)ការយល់ដឹងអំពីបែបផែនសកម្មភាពនៃថ្នាំ ក្នុងវគ្គបណ្តុះបណ្តាលអប់រំសមត្ថភាពវិជ្ជាជីវៈដល់អាជីវករលក់ដុំ-លក់រាយសម្រាប់ធ្វើអាជីវកម្មថ្នាំកសិកម្ម និងជីកសិកម្ម និងអ្នកពាក់ព័ន្ធសរុបចំនួន ៨០២នាក់។

**២. ការគ្រប់គ្រងជីកសិកម្ម**

បរិមាណជីកសិកម្មដែលបាននាំចូលក្នុងព្រះរាជាណាចក្រកម្ពុជាមានបរិមាណសរុបចំនួន ៩២៧ ៣៦៥ តោន បើប្រៀបធៀបនឹងឆ្នាំ២០២៤ បរិមាណនាំចូលសរុបមានការថយចុះប្រមាណជា៣%។ ប្រភេទជីកសិកម្មដែលនាំចូលរួមមាន៖ ជីគីមីចំនួន ៧៣៤ ០២៣ តោន ជីសរីរាង្គចំនួន ១៦៧ ៣៦១ តោន ជីកែលម្អគុណភាពដីចំនួន ១៧ ០៧០ តោន វត្ថុធាតុដើមជីចំនួន ៦ ០៨៤ តោន និងជីជីវសាស្ត្រចំនួន ២ ៨២៧ តោន។ ការនាំចេញជីកសិកម្ម (ជីសរីរាង្គ) មានចំនួន ៦៨៦ តោន។

ក្នុងឆ្នាំ២០២៥នេះ តម្លៃជីកសិកម្មពុំសូវមានការប្រែប្រួលខ្លាំងគួរឱ្យកត់សម្គាល់ឡើយបើប្រៀបធៀបតម្លៃឆ្នាំ២០២៤ លើកលែងជី DAP(18-46-0) ដែលមានតម្លៃឡើងខ្ពស់ជាងឆ្នាំ២០២៤ ក្នុងរង្វង់ ៥ដុល្លារក្នុង១បាវ (៥០គ.ក្រ) ដោយសារប្រទេសចិនដែលជាប្រទេសផ្គត់ផ្គង់ជី DAP (18-46-0) ដ៏ធំមួយបានបិទការនាំចេញមួយរយៈក្នុងហេតុផលទុកបំពេញតម្រូវក្នុងស្រុក។ ជារួម តម្លៃជីអ៊ុយរ៉េ (46-0-0) បានធ្លាក់ចុះពី ២៩,៥៦ដុល្លារ/បាវ (៥០គ.ក្រ) មកត្រឹម ២៨,១៩ដុល្លារ/បាវ តម្លៃជី Kali/KCl (0-0-60) បានធ្លាក់ចុះពី ៣២,៣៦ដុល្លារ/បាវ មកត្រឹម ៣១,៤៣ដុល្លារ/បាវ

ជី NP(16-20-0) មានតម្លៃក្នុងរង្វង់ ៣១,៨៤ដុល្លារ/បាវ តម្លៃជី NPK (15-15-15) បានកើនឡើងពី ៣៥,៧៨ដុល្លារ/បាវ ទៅ ៣៦,៩១ដុល្លារ/បាវ និងតម្លៃជី DAP (18-46-0) បានឡើងពី ៣៦,៦០ដុល្លារ/បាវ ទៅ ៤១,៤០ដុល្លារ/បាវ។

ក្រៅពីនេះ ក្រសួងបាន (១) ចុះពិនិត្យ និងពង្រឹងការធ្វើអាជីវកម្មជីកសិកម្មចំនួន ១៥ខេត្តដែលមានអ្នកចូលរួមសរុបចំនួន ២ ០៧៦នាក់ និងមានមន្ត្រីកសិកម្មឃុំចំនួន ១៩៤នាក់ (២) បានប្រជុំជាមួយក្រុមហ៊ុនធ្វើពាណិជ្ជកម្មជីកសិកម្មដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងជីកសិកម្មចំនួន ២លើក ដែលមានប្រធាន ឬតំណាងក្រុមហ៊ុនចូលរួមសរុបចំនួន ២០០នាក់ (៣) ចុះវាយតម្លៃទីតាំងឃ្លាំងសន្និធិ និងលាយផ្សំខ្ចប់ជាថ្មីជីកសិកម្មចំនួន ២៣ក្រុមហ៊ុន (៤) ចុះធ្វើអធិការកិច្ចបានចុះអធិការកិច្ចបង្ក្រាបបទល្មើសការធ្វើអាជីវកម្មជីកសិកម្មខុសច្បាប់ និងដកហូតបានជីគីមីសញ្ញាក្បាលក្របី ២០-២០-១៥+TE បានចំនួន ៧០បាវ(៥) ចុះបណ្តុះបណ្តាលអប់រំសមត្ថភាពវិជ្ជាជីវៈស្តីពីបទដ្ឋានគតិយុត្តនីតិវិធី និងវិធានបច្ចេកទេសសម្រាប់ការធ្វើអាជីវកម្មថ្នាំកសិកម្មនិងជីកសិកម្ម នៅខេត្តចំនួន ៣ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ៥៩៦នាក់ (៨) ចុះដកហូតសំណាកជីកសិកម្មពីឃ្លាំងស្តុកជីកសិកម្មរបស់ក្រុមហ៊ុនចំនួន២៣ ក្នុងខេត្តចំនួន ៦ខេត្ត ដកហូតបានចំនួន ១០០សំណាក ក្នុងគោលបំណងពង្រឹងគុណភាព ប្រសិទ្ធភាព បមាណីយជីកសិកម្មដែលធ្វើអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា និង(៩)បានស្រាវជ្រាវឃើញផេកលក់ផលិតផលជីកសិកម្មខុសច្បាប់ (មិនបានចុះបញ្ជី និងមិនមានច្បាប់អនុញ្ញាត) បានចំនួន ៣៦ផេក ហើយបានរៀបចំឯកសារស្នើសុំអន្តរាគមន៍ពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ដើម្បីលុបផេកទាំងនេះចេញ។

## ញ. ការងារអភិវឌ្ឍន៍កសិ-ឧស្សាហកម្ម

### ១. ការរៀបចំវគ្គបណ្តុះបណ្តាលការអភិវឌ្ឍន៍កសិ-ឧស្សាហកម្ម

ក្រសួងបានបណ្តុះបណ្តាលដល់អ្នកស្រាវជ្រាវ សិស្ស-និស្សិត សហគ្រាស អ្នកកែច្នៃ អ្នកផលិត និងពាណិជ្ជករដែលមានអ្នកចូលរួមសរុប ២ ២០២នាក់ លើប្រធានបទ បច្ចេកវិទ្យានិងនវានុវត្តកសិផលិតផល បច្ចេកទេសក្រោយពេលប្រមូលផលនិងស្តុកទុក បច្ចេកទេសកែច្នៃកសិផលិតផល បច្ចេកទេសវេចខ្ចប់ ស្លាកសញ្ញា សំបកវេចខ្ចប់និងអាយុកាលផលិតផលកសិកម្មនិងចំណីអាហារ ការធ្វើផែនការអាជីវកម្មកសិផលិតផល វិធីសាស្រ្តអភិវឌ្ឍន៍ផលិតផលអាហារ ការប្រើប្រាស់សារធាតុការពារនិងវិធីសាស្រ្តថែរក្សាគុណភាពចំណីអាហារ ការធានាគុណភាពអាហារ ការគ្រប់គ្រងប្រព័ន្ធសុវត្ថិភាពអាហារ ការអនុវត្តសុវត្ថិភាពក្នុងមន្ទីរពិសោធន៍ ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពកសិផលិតផល និងចំណីអាហារ និងការបង្កើតកសិផលិតផលគំរូ។ លើសពីនេះទៀត នាយកដ្ឋានកសិ-ឧស្សាហកម្ម បានបណ្តុះបណ្តាលបានចំនួន ៣ ៥៧៣នាក់ ក្រោមការគាំទ្រពីគម្រោង និងដៃគូអភិវឌ្ឍន៍។

### ២. ការពិសោធន៍ ស្រាវជ្រាវ និងចងក្រងឯកសារបច្ចេកទេស

ក្រសួងបានពិសោធន៍ ស្រាវជ្រាវ និងចងក្រងឯកសារបច្ចេកទេសកសិ-ឧស្សាហកម្ម រួមមាន ១).សៀវភៅណែនាំស្តីពី ផែនការកសិពាណិជ្ជកម្ម ២).សៀវភៅស្តីពី ការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ៣).សៀវភៅស្តីពីខ្សែច្រវាក់ផលិតកម្មដំណាំស្វាយចន្ទី ៤).សៀវភៅស្តីពី ខ្សែច្រវាក់ផលិតកម្មដំណាំម្រេច ៥).នីតិវិធី និងបែបបទនៃការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាព សុវត្ថិភាព ផលិតផលកសិកម្ម និងចំណីអាហារ។ ជាមួយគ្នានេះ ក្រសួងបានផ្សព្វផ្សាយឯកសារបច្ចេកទេសរួមមាន៖ ១).បច្ចេកទេសកែច្នៃការ៉េមរសជាតិគ្រាប់ស្វាយចន្ទី ២).បច្ចេកទេសកែច្នៃទឹកដោះស្វាយចន្ទី និងទឹកសីរ៉ូស្វាយចន្ទី ៣).បច្ចេកទេសកែច្នៃគ្រាប់ស្វាយចន្ទីរសជាតិ BBQ, Wasabi, ម្រេច, ស្កត្នោត និងរសជាតិតុងយាំម និង ៤).បានធ្វើឧបករណ៍សម្រាប់ប្រលេះ និងបកគ្រាប់ស្វាយចន្ទីដោយដៃ។ បន្ថែមពីនេះទៀត ក្រសួងបានកំពុងសិក្សាស្រាវជ្រាវ និងចងក្រងឯកសារបច្ចេកទេសកែច្នៃបាយកំប៉ុង ត្រីខកំប៉ុង(ត្រីទឹកសាប) ស្តង់ដាស្រូវ-អង្ករ និងគោលការណ៍ណែនាំស្តីពីការរៀបចំយថាប្រភេទគ្រាប់ស្វាយចន្ទីM២៣។

### ៣. ផលិតកម្មកសិកម្មតាមកិច្ចសន្យា

ការអនុវត្តផលិតកម្មកសិកម្មកិច្ចសន្យាប្រចាំឆ្នាំ២០២៥ សរុបចំនួន ១៦៧កិច្ចសន្យា ដែលមាន ១០៤សហគមន៍ ក្រុមកសិករនិងបណ្តុំអាជីវកម្មចំនួន ៣៦ បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនចំនួន ៥៩ក្រុមហ៊ុន ដែលមានកសិករចូលរួមសរុបចំនួន ៩ ៤០៩គ្រួសារ លើទំហំផ្ទៃដីចំនួន ៣៤ ៨៤៧,៦៩ហិកតា ក្នុងបរិមាណសរុបចំនួន ១ ៣៩៤ ៤០៣,៨០តោន រួមមាន បន្លែ ស្រូវ ដំឡូងមី គ្រាប់ស្វាយចន្ទី ពោត និងម្រេច ជាដើម។

**ក្រាហ្វិកទី១១៖ ការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាតាមបណ្តារាជធានី/ខេត្តឆ្នាំ២០២៥**




### ៤. ការគ្រប់គ្រងគុណភាព និងសុវត្ថិភាពផលនិងផលិតផលកសិ-ឧស្សាហកម្ម

ក្រសួងបានវិភាគគុណភាព សុវត្ថិភាព និងអាហារូបត្ថម្ភ នៅក្នុងផលនិងផលិតផលកសិកម្មចំនួន ៨៤សំណាក លើផ្នែករូបនិងគីមីសាស្ត្រ ផ្នែកមីក្រូជីវសាស្ត្រ និងអាហារូបត្ថម្ភ។ ជាមួយគ្នានេះ ក្រសួងក៏បានជួបប្រជុំពិភាក្សាការងារ និងចុះកិច្ចព្រមព្រៀងជាមួយដៃគូអភិវឌ្ឍន៍ចំនួន ១២កិច្ចព្រមព្រៀង។

### ៥. ការប្រឡងប្រជែងអ្នកកែច្នៃប្រហុកឆ្នើម

ក្នុងឆ្នាំ២០២៥ ក្រសួងបានរៀបចំព្រឹត្តិការណ៍ប្រឡងប្រជែងអ្នកកែច្នៃប្រហុកឆ្នើមដែលមានសិប្បកម្មកែច្នៃនិងអ្នកកែច្នៃចូលរួមចំនួន ២៣នាក់ ដែលធ្វើឡើងជាបីដំណាក់កាល ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

ពានរង្វាន់អ្នកកែច្នៃប្រហុកឆ្នើមឆ្នាំ២០២៥ រួមមាន ជ័យលាភីលេខ១ បានទៅលើសិប្បកម្ម សំណាង សុធា ជ័យលាភីលេខ២ បានទៅលើសិប្បកម្មកែច្នៃផលិតផលជលផល ចាវ សួស្តី និងជ័យលាភីលេខ៣ បានទៅលើសិប្បកម្ម ស៊ីនួន ពិភពត្រីងៀត ពានរង្វាន់សិប្បកម្មឆ្នើម បានទៅលើសិប្បកម្មផលិត និងកែច្នៃប្រហុក ខនហ្វីរេល និងពានរង្វាន់កិត្តិយសសម្រាប់អ្នកកែច្នៃប្រហុកឆ្នើមឆ្នាំ២០២៥ រួមមាន ជ័យលាភីកិត្តិយសបានទៅលើសិប្បកម្មកែច្នៃ ហេងហ៊ាត់ និង សិប្បកម្ម ធឿន ស្រីនី។

## ៥.២ ការបង្កើនផលិតភាពដំណាំកៅស៊ូ

### ក. ផ្ទៃដីដាំដុះកៅស៊ូ

ផ្ទៃដីកៅស៊ូកម្ពុជាសរុបមានចំនួន ៤៤៨ ០៥១ហិកតា កើនឡើង ២២ ៦០៨ហិកតា ស្មើនឹង ៥,៣១% ធៀបឆ្នាំ២០២៤ ក្នុងនោះផ្ទៃដីកៅស៊ូកសិ-ឧស្សាហកម្មចំនួន ២២៣ ៣៤០ហិកតា និងផ្ទៃដីកៅស៊ូគ្រួសារចំនួន ២២៤ ៧១១ហិកតា ស្មើនឹងប្រមាណ ៥០% នៃផ្ទៃដីកៅស៊ូសរុប។

**ក្រាហ្វិកទី១២៖ ប្រភេទផ្ទៃដីចម្ការកៅស៊ូឆ្នាំ២០២១-២០២៥**




## ខ. ការងារផលិតកម្មកៅស៊ូ

ផ្ទៃដីកៅស៊ូយកផលមានចំនួន ៣៤៦ ៨៤២ហិកតា កើនឡើងចំនួន ១៦ ៤៨៣ហិកតា ស្មើនឹង៤,៩៩% ធៀបឆ្នាំ២០២៤ ដោយសារកៅស៊ូដល់អាយុផ្តល់ផល(បើកមុខចៀរថ្មី)។ ផលិតផលកៅស៊ូសម្រេចបានចំនួន ៤២២ ៨៤២តោន កើនឡើងចំនួន ១៥ ៦៣៣តោន ស្មើនឹង ៣,៨៤% ធៀបឆ្នាំ២០២៤។ ទិន្នផលមធ្យមចំនួន ១ ២១៩គ.ក្រ/ហ.ត/ឆ្នាំ បានថយចុះចំនួន ១៤គ.ក្រ ស្មើនឹង១,១០% ធៀបឆ្នាំ២០២៤ ដោយសារផ្ទៃដីកៅស៊ូយកផលបើកមុខចៀរដំបូងច្រើន។

**ក្រាហ្វិកទី១៣៖ ផ្ទៃដីចៀរជ័រ ថែទាំ និងផ្ទៃដីសរុបនៃដំណាំកៅស៊ូ ឆ្នាំ២០២១-២០២៥**




## គ. ការងារធុរកិច្ចកៅស៊ូ

ចំណូលសរុបទទួលបានពីការលក់ផលិតផលកៅស៊ូប្រមាណចំនួន ៨៣២,៩លានដុល្លារអាម៉េរិក កើនឡើងប្រមាណចំនួន ១៦១,២លានដុល្លារអាម៉េរិក ស្មើនឹង២៤% ធៀបឆ្នាំ២០២៤ ក្នុងនោះរួមមាន៖ (១)ការនាំចេញកៅស៊ូសម្រេចបានចំនួន ៣៤៣ ៧៦២តោន គិតជាទឹកប្រាក់ប្រមាណចំនួន ៦០៣,៦លានដុល្លារអាម៉េរិក ថយចុះចំនួន ៤៨ ៣៣៣តោន ស្មើនឹង ១២,៣% និងប្រាក់ចំណូលពីការនាំចេញកៅស៊ូថយចុះប្រមាណ៦០,១លានដុល្លារអាម៉េរិក

ស្មើនឹង ៩,១% ធៀបឆ្នាំ២០២៤ (២)ការនាំចេញឈើកៅស៊ូមានចំនួន ៣០ ២៣៨ម៉ែត្រគូប គិតជាទឹកប្រាក់ប្រមាណចំនួន ៦,២លានដុល្លារអាម៉េរិក បានកើនឡើង ៥ ០៨១ម៉ែត្រគូប និងទឹកប្រាក់កើនឡើងចំនួន ០,៨លានដុល្លារអាម៉េរិក ស្មើនឹង១២,៩% ធៀបនឹងឆ្នាំ២០២៤ និង(៣)ការប្រើប្រាស់ផលិតផលកៅស៊ូក្នុងស្រុកចំនួន ១២៤ ២៣១តោន គិតជាទឹកប្រាក់ប្រមាណចំនួន ២២៣,០លានដុល្លារអាម៉េរិក បានកើនឡើងចំនួន ៦៦ ២៣១តោន និងទឹកប្រាក់កើនឡើងចំនួន ១២៦,៦លានដុល្លារអាម៉េរិក ស្មើនឹង១៣១,៣% ធៀបនឹងឆ្នាំ២០២៤។

ថ្លៃលក់កៅស៊ូជាមធ្យម ១ ៧៥៦ដុល្លារអាម៉េរិក/តោន កើនឡើង ៦៣ដុល្លារអាម៉េរិក/តោន ស្មើនឹង ៣,៧% ធៀបឆ្នាំ២០២៤។ ថ្លៃលក់ឈើកៅស៊ូជាមធ្យម ១៧៧ដុល្លារអាម៉េរិក/ម៉ែត្រគូប បានថយចុះចំនួន ៣៩ដុល្លារអាម៉េរិកក្នុងមួយម៉ែត្រគូប ស្មើនឹង១៨,០% ធៀបឆ្នាំ២០២៤។

**ក្រាហ្វិកទី១៤៖ ផលិតកម្ម និងការនាំចេញកៅស៊ូ ឆ្នាំ២០២១-២០២៥**




មកដល់ឆ្នាំ២០២៥នេះ រោងចក្រ សិប្បកម្មកែច្នៃកៅស៊ូនិងឈើកៅស៊ូមានសរុបចំនួន ១៧៩កន្លែង ដូចគ្នានឹងចំនួនរោងចក្រ សិប្បកម្មកែច្នៃកៅស៊ូនិងឈើកៅស៊ូឆ្នាំ២០២៤។ ក្នុងនោះរោងចក្រកែច្នៃកៅស៊ូធម្មជាតិបញ្ជាក់តាមលក្ខណៈបច្ចេកទេស (TSR: Technically Specified Rubber) ចំនួន ៥៦កន្លែង រោងចក្រកែច្នៃទឹកជ័រខាប់ (CL: Concentrated Latex) ចំនួន ១កន្លែង សិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយមានផ្សែង (RSS: Ribbed Smoked Sheet) និងសិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយខ្យល់ក្តៅ (ADS: Air-Dried Sheet) មានចំនួន ១០១កន្លែង និងរោងចក្រកែច្នៃឈើកៅស៊ូ (RWF: Rubber Wood Factory) ចំនួន ២១កន្លែង។ បច្ចុប្បន្ននេះ រោងចក្រសិប្បកម្មកែច្នៃកៅស៊ូនិងឈើកៅស៊ូចំនួន ១១៧កន្លែងបានផ្អាកដំណើរការ ក្នុងនោះរោងចក្រកែច្នៃកៅស៊ូធម្មជាតិបញ្ជាក់តាមលក្ខណៈបច្ចេកទេស (TSR: Technically Specified Rubber) ចំនួន១៩កន្លែង រោងចក្រកែច្នៃទឹកជ័រខាប់ (CL: Concentrated Latex) ចំនួន១កន្លែង សិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយមានផ្សែង (RSS: Ribbed Smoked Sheet) និងសិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយខ្យល់ក្តៅ (ADS: Air-Dried Sheet) មានចំនួន៨៦កន្លែង និងរោងចក្រកែច្នៃឈើកៅស៊ូ (RWF: Rubber Wood Factory) ចំនួន ១១កន្លែង។ ការផ្អាកដំណើរការនេះ ដោយសារខ្វះវត្ថុធាតុដើម ខ្វះទុនបម្រុង ថ្លៃដើមផលិតខ្ពស់ ផលិតផលមិនបំពេញតម្រូវការទីផ្សារ និងប្រព័ន្ធផលិតកម្មកែច្នៃមិនទាន់ល្អប្រសើរ។

ក្រាហ្វិកទី១៥៖ រោងចក្រ សិប្បកម្មកែច្នៃកៅស៊ូ និងឈើកៅស៊ូឆ្នាំ២០២១-២០២៥




## ឃ. ការងារផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកៅស៊ូ

ក្រសួងបានបើកវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងប្រឹក្សាបច្ចេកទេសកៅស៊ូចំនួន ១១៧លើក មានអ្នកចូលរួមសរុបចំនួន ៣ ៥២០នាក់ ដោយផ្តោតទៅលើកការពង្រឹងសហគមន៍កសិកម្មកៅស៊ូគ្រួសារ ការប្រឹក្សាបច្ចេកទេសដំណាំកៅស៊ូនិងការអនុវត្តកសិកម្មល្អលើការយកផលទឹកជ័រ និងការបណ្តុះបណ្តាលមន្ត្រីកសិកម្មឃុំ។

## ង. ការងារពិសោធន៍ និងស្រាវជ្រាវកៅស៊ូ

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- បានអនុវត្តនិងបន្តការងារស្រាវជ្រាវ តាមដានទិន្នន័យចម្ការពិសោធន៍ទាំងនៅក្នុងស្ថានីយ ទាំងនៅតាមបណ្តាក្រុមហ៊ុនចម្ការកៅស៊ូ សរុបចំនួន ៦៤ចម្ការពិសោធន៍
- បានចូលរួមបណ្តុះបណ្តាលធនធានមនុស្សនៅតាមគ្រឹះស្ថានសិក្សា និងបានសម្របសម្រួលឱ្យនិស្សិតធ្វើទស្សនកិច្ចសិក្សាចម្ការពិសោធន៍
- បានបណ្តុះបណ្តាលស្តីពីការអនុវត្តកសិកម្មល្អលើប្រមូលផលទឹកជ័រដល់ជនបង្គោលនៅខេត្តកំពង់ចាម
- បានផ្ទេរបច្ចេកវិទ្យាកៅស៊ូដល់កសិករកៅស៊ូគ្រួសារនៅខេត្តត្បូងឃ្មុំ និងខេត្តស្ទឹងត្រែង
- បានចេញវិញ្ញាបនបត្រច្បារពូជកៅស៊ូចំនួន ៤ ដល់កសិករកៅស៊ូគ្រួសារ នៅក្នុងស្រុកចម្ការលើ ខេត្តកំពង់ចាម និងស្រុកសណ្តាន់ និងស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ
- បានដាំដុះកូនកៅស៊ូលើផ្ទៃដីចំនួន ១១ហិកតា នៃក្លូន CRRI 12, CRRI 19 និង PB 280
- បានផ្តល់មែកពូជចំនួន ៦ក្លូន (CRRI 12, CRRI 19, RRII 417, RRII 422, RRIT 251 និង RRIT 226) ដល់ក្រុមហ៊ុនចម្ការកៅស៊ូទំរីងកំពង់ធំ និង៣ក្លូន (CRRI 12, CRRI 19 និង RRIC 121) ដល់ក្រុមហ៊ុនចម្ការកៅស៊ូ COVIPHAMA ខេត្តមណ្ឌលគិរី និង២ក្លូន (CRRI 12 និង CRRI 19) ដល់កសិករកៅស៊ូគ្រួសារក្នុងខេត្តត្បូងឃ្មុំ រតនគិរី និងខេត្តកំពង់ធំ
- បានយកសំណាក និងវិភាគសរីរៈទឹកជ័រពីចម្ការពិសោធន៍នានាក្នុង និងក្រៅស្ថានីយបានចំនួន ១ ៥៩៦ សំណាក និងបានបញ្ចេញក្លូនកៅស៊ូកម្ពុជា CRRI 3 ឱ្យប្រើប្រាស់ជាផ្លូវការ
- បានធ្វើតេស្តកៅស៊ូសន្លឹក (RSS) ចំនួន ២៨៥សំណាក និងកៅស៊ូដុំ (CSR) ចំនួន ៤០០សំណាក ដើម្បីពិនិត្យគុណភាព នៃការកែច្នៃតាមស្តង់ដា CSR
- បានចូលរួមធ្វើតេស្តប្រៀបធៀបអន្តរមន្ទីរពិសោធន៍អន្តរជាតិក្នុងក្របខ័ណ្ឌសមាគមកៅស៊ូអន្តរជាតិ (IRA) ចំនួន ២លើក (ទី១៣២និងទី១៣៣) លើយថាប្រភេទកៅស៊ូ TSR (Technical Specified Rubber)

- បានធ្វើតេស្តប្រៀបធៀបក្នុងស្រុកជាមួយមន្ទីរពិសោធន៍មូលដ្ឋានលើកទី៦៨ និង៦៩ មានចំនួន ១៤ បានចូលរួម
- បានធ្វើតេស្តនិងចុះបញ្ជិកាទទួលស្គាល់ និងសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជាចំនួន ៦ រោងចក្រកែច្នៃកៅស៊ូ CSR និងមន្ទីរពិសោធន៍ចំនួន ៥។

### ច. កម្លាំងពលកម្មក្នុងអនុវិស័យកៅស៊ូ

ឆ្នាំ២០២៥ អនុវិស័យកៅស៊ូបានប្រើប្រាស់កម្លាំងពលកម្មផ្នែកសំខាន់ៗសរុបចំនួនប្រមាណ១៥៨ ១៩៤នាក់ ដែលក្នុងនោះមាន៖ កម្លាំងពលកម្មក្នុងផ្នែកយកផលមានចំនួនប្រមាណ១២៣ ៣២២នាក់ កម្លាំងពលកម្មក្នុងផ្នែកថែទាំមានចំនួនប្រមាណ២០ ០៤២នាក់ កម្លាំងពលកម្មក្នុងផ្នែកកែច្នៃមានចំនួនប្រមាណ៧ ០៩៧នាក់ និងកម្លាំងពលកម្មក្នុងផ្នែកការងាររដ្ឋបាលមានចំនួនប្រមាណ៧ ៥៣៣នាក់។

### ឆ. ការងារប្រលងចៀរជ័រនិងប្រារព្ធខួប១០០ឆ្នាំចម្ការកៅស៊ូចាស់ជាងគេនៅកម្ពុជា

ឆ្នាំ២០២៥នេះ ក្រសួងបានរៀបចំកម្មវិធីប្រលងចៀរជ័រកៅស៊ូ ដែលជាព្រឹត្តិការណ៍ប្រលងចៀរជ័រកៅស៊ូថ្នាក់ជាតិនៅកម្ពុជា ដែលជាគំនិតផ្តួចផ្តើមដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីទាក់ទាញចំណាប់អារម្មណ៍ពីប្រជាពលរដ្ឋក្នុងការងារជាកម្មករចៀរជ័រកៅស៊ូ ដែលរក្សាបាននិរន្តរភាពកម្លាំងពលកម្មតាមចម្ការកៅស៊ូ រក្សាសុខភាពដើមកៅស៊ូ រយៈពេលចៀរយកផលបានយូរ ត្រឹមត្រូវ ទទួលបានទិន្នផលខ្ពស់ និងផ្តល់ក្តីសង្ឃឹមដល់កម្មករចៀរជ័រឱ្យខិតខំប្រឹងប្រែងបំពេញការងារកាន់តែល្អ និងមានប្រសិទ្ធភាពសេដ្ឋកិច្ចកាន់តែប្រសើរឡើង។ កម្មវិធីនេះមានការចូលរួមពីកម្មករចៀរជ័រឆ្នើមពីបណ្តាក្រុមហ៊ុនកសិ-ឧស្សាហកម្ម និងសហគមន៍ កៅស៊ូគ្រួសារ សរុបចំនួន ៦០នាក់។

## ៥.៣ ការងារសុខភាពសត្វ និងផលិតកម្មសត្វ

### ក. ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ

ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារក្នុងឆ្នាំ២០២៥ មានសត្វសរុបចំនួន ៣៨,៤០លានក្បាល ក្នុងនោះមានគោចំនួន ២,៨៩លានក្បាល ក្របីចំនួន ៤៣៦ ២៩០ក្បាល ជ្រូកចំនួន ១,៣២លានក្បាល បក្សីចំនួន ៣៣,៦៦លានក្បាល សេះចំនួន ១ ៤៦៤ក្បាល ចៀមចំនួន ១២ ៩៣០ក្បាល និងពពែចំនួន ៧១ ៨៦៧ក្បាល។

បើប្រៀបធៀបឆ្នាំ២០២៤ ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារសរុបមានអត្រាថយចុះ ៣,៥០% ក្នុងនោះគោថយចុះ ៣,៦៤% ក្របីថយ ៣,២១% សេះថយ ៥២,៩៩% បក្សីថយ ៣,៨៦% ជ្រូកកើន ៥,១៧% ចៀមកើន ៧២,៦៣% និងពពែកើន ២៦,៣៩%។

**ក្រាហ្វិកទី១៦៖ ផលិតកម្មសត្វលក្ខណៈគ្រួសារឆ្នាំ២០២១-២០២៥**



**ក្រាហ្វិកទី១៧៖ ផលិតកម្មសត្វបក្សីលក្ខណៈគ្រួសារឆ្នាំ២០២១-២០២៥**




## ខ. ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម

ក្នុងឆ្នាំ២០២៥ ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម មានចំនួនសរុប ៣០,៥៣លានក្បាល ក្នុងនោះគោមានចំនួន ៩៨ ៨៦៦ក្បាល ក្របីចំនួន ២១៥ក្បាល ជ្រូកចំនួន ៣,៣៣លានក្បាល បក្សីចំនួន ២៧,១០លានក្បាល សេះចំនួន ២១ក្បាល ចៀមចំនួន ១ ០៧០ក្បាល ពពែចំនួន ២ ៥៥០ក្បាល ។

បើប្រៀបធៀបឆ្នាំ២០២៤ ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មសរុបមានអត្រាកំណើន៣,៤៨% ក្នុងនោះគោកើន៨២,១១% ក្របីថយ ១៤% ជ្រូកកើន ១៨,៧៦% បក្សីកើន ២,១១% សេះកើន ៥% និងពពែថយ ២៦,២៦% ។

**ក្រាហ្វិកទី១៨៖ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មឆ្នាំ២០២១-២០២៥**



**ក្រាហ្វិកទី១៩៖ ផលិតកម្មសត្វបក្សីលក្ខណៈពាណិជ្ជកម្មឆ្នាំ២០២១-២០២៥**




គ. ផលិតកម្មសត្វសរុបទូទាំងប្រទេស (លក្ខណៈគ្រួសារ និងពាណិជ្ជកម្ម)

ជារួម ផលិតកម្មសត្វគ្រប់ប្រភេទក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ មានការកើនឡើងគួរឱ្យកត់សម្គាល់ គឺចាប់ពីចំនួន ៥៩,៩៦លានក្បាល ក្នុងឆ្នាំ២០២១ កើនដល់ចំនួន ៦៨,៩៤លានក្បាលនៅឆ្នាំ២០២៥។ ដោយឡែកក្នុងឆ្នាំ២០២៥ នេះ ស្ថិតិសត្វគោមានចំនួន ២,៩៩លានក្បាល ក្របីចំនួន ៤៣៦ ៥០៥ក្បាល ជ្រូកចំនួន ៤,៦៦លានក្បាល បក្សីចំនួន ៦០,៧៦លានក្បាល សេះចំនួន ១ ៤៨៥ក្បាល ចៀមចំនួន ១៤ ០០០ក្បាល និងពពែចំនួន ៧៤ ៤១៧ក្បាល។

បើប្រៀបធៀបទៅនឹងឆ្នាំ២០២៤ ផលិតកម្មសត្វសរុបមានអត្រាថយចុះចំនួន ០,៥៣% ក្នុងនោះ គោក្របីថយ ២,២៦% ជ្រូកកើន ១៤,៥៥% បក្សីថយ ១,២៩% សេះថយ ៥២,៦២% ចៀមកើន ៦៣,៥៥% និងពពែកើន ២៣,៣៧% ។

**ក្រាហ្វិកទី២០៖ ផលិតកម្មសត្វសរុប (លក្ខណៈគ្រួសារនិងពាណិជ្ជកម្ម) ឆ្នាំ២០២១-២០២៥**



**ក្រាហ្វិកទី២១៖ ផលិតកម្មសត្វបក្សីសរុប (លក្ខណៈគ្រួសារនិងពាណិជ្ជកម្ម) ឆ្នាំ២០២១-២០២៥**




## ឃ. ការប្រៀបធៀបបែបផែនផលិតកម្មសត្វ

ការជំរុញផលិតកម្មសត្វ និងបង្កើនផលិតភាពសត្វ គឺជាគោលដៅអាទិភាពសម្រាប់ការធ្វើពាណិជ្ជកម្មសត្វ។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្ម មានអត្រាកើនឡើងគួរឱ្យកត់សម្គាល់ គឺចាប់ពីចំនួន ២៣,៣៨លានក្បាល ក្នុងឆ្នាំ២០២១ កើនដល់ចំនួន ៣០,៥៣លានក្បាល នៅឆ្នាំ២០២៥។ ដោយឡែកផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មនៅក្នុងឆ្នាំ២០២៥ ធៀបនឹងឆ្នាំ២០២៤ មានអត្រាកំណើន ៣,៤៨% ក្នុងនោះ ផលិតកម្មគោ-ក្របីកើន ៨១,៦៧% ផលិតកម្មជ្រូកកើន ១៨,៧៦% និងផលិតកម្មបក្សីកើនចំនួន ២,១១%។ ជាមួយគ្នានេះ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មមានអត្រានៃកំណើន ដែលបានឆ្លុះបញ្ចាំងឱ្យឃើញពីការផ្លាស់ប្តូរការចិញ្ចឹមជាលក្ខណៈគ្រួសារទៅជាលក្ខណៈពាណិជ្ជកម្ម ដើម្បីឈានទៅកែលម្អផលិតភាពសត្វ និងប្រសិទ្ធភាពសេដ្ឋកិច្ចកាន់តែល្អប្រសើរឡើង។

- **ការប្រៀបធៀបបែបផែនផលិតកម្មសត្វ៖** អត្រានៃការចិញ្ចឹមសត្វលក្ខណៈពាណិជ្ជកម្មបានកើនពី ៣៩% ក្នុងឆ្នាំ២០២១ ដល់ ៤៤,៦០% នៅឆ្នាំ២០២៥។ ដោយឡែកអត្រានៃការចិញ្ចឹមសត្វលក្ខណៈគ្រួសារបានថយចុះពី ៦១% ក្នុងឆ្នាំ២០២១ មកត្រឹម ៥៥,៤០% នៅឆ្នាំ២០២៥។

**ក្រាហ្វិកទី២២៖ ប្រៀបធៀបបែបផែនផលិតកម្មសត្វសរុបឆ្នាំ២០២១-២០២៥**



### ក្រាហ្វិកទី២៣៖ ប្រៀបធៀបអត្រាបែបផែនផលិតកម្មសត្វសរុបឆ្នាំ២០២១-២០២៥




- **ការប្រៀបធៀបបែបផែនផលិតកម្មជ្រូក៖** អត្រានៃការចិញ្ចឹមជ្រូកជាលក្ខណៈពាណិជ្ជកម្មបានកើនពី ៥៨,៥៩% ក្នុងឆ្នាំ២០២១ ដល់ ៧១,៥៥% នៅក្នុងឆ្នាំ២០២៥។ ដោយឡែកអត្រានៃការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារបានថយចុះពី៤១,៤១% ក្នុងឆ្នាំ២០២១ មកត្រឹម២៨,៤៥% នៅឆ្នាំ២០២៥។

### ក្រាហ្វិកទី២៤៖ ប្រៀបធៀបបែបផែនផលិតកម្មជ្រូក ឆ្នាំ២០២១-២០២៥




- **ការប្រៀបធៀបបែបផែនផលិតកម្មបក្សី៖** អត្រានៃការចិញ្ចឹមបក្សីជាលក្ខណៈពាណិជ្ជកម្មបានកើនពី ៤០,៣០% ក្នុងឆ្នាំ២០២១ ដល់ចំនួន ៤៤,៦០% នៅឆ្នាំ២០២៥។ ដោយឡែក អត្រានៃការចិញ្ចឹមបក្សីជាលក្ខណៈគ្រួសារបានថយចុះពីចំនួន ៥៩,៧០% ក្នុងឆ្នាំ២០២១ មកត្រឹមចំនួន ៥៥,៤០% នៅឆ្នាំ២០២៥។

**ក្រាហ្វិកទី២៥៖ ប្រៀបធៀបបែបផែនផលិតកម្មបក្សី ឆ្នាំ២០២១-២០២៥**




**ក្រាហ្វិកទី២៦៖ ប្រៀបធៀបអត្រាបែបផែនផលិតកម្មបក្សីឆ្នាំ ២០២១-២០២៥**




## ង. តម្រូវការសត្វ និងសាច់

ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ តម្រូវការសាច់សត្វសម្រាប់បរិភោគ មានការកើនឡើងគួរឱ្យកត់សម្គាល់ គឺកើនពីចំនួន ៣១០ពាន់តោន ក្នុងឆ្នាំ២០២១ ឡើងដល់ចំនួន ៣៣៨ពាន់តោន នៅឆ្នាំ២០២៥។ ដោយឡែកក្នុងឆ្នាំ២០២៥ នេះ តម្រូវការសាច់សរុបចំនួន ៣៣៨,២៦ពាន់តោន ក្នុងនោះសាច់គោ-ក្របីចំនួន ៩៣,៧១ពាន់តោន សាច់ជ្រូកចំនួន ១៦៩,៦៨ពាន់តោន សាច់បក្សីចំនួន ៧៣,៣៦ពាន់តោន និងសាច់ចៀម-ពពែចំនួន ១ ៥០៩តោន។

ផលិតកម្មសត្វក្នុងស្រុកអាចផ្គត់ផ្គង់សាច់បានប្រមាណ ៣៣១,៥ពាន់តោន ស្មើនឹង ៩៨% នៃតម្រូវការសរុប ក្នុងនោះសាច់គោ-ក្របីចំនួន ៩២,៧ពាន់តោន (៨៤៣ពាន់ក្បាល) សាច់ជ្រូកចំនួន ១៦៩,៧ពាន់តោន (៣,៣៩៤ លានក្បាល) សាច់បក្សីចំនួន ៦៨,១១ពាន់តោន (៥៦,៧៦ពាន់ក្បាល)។

បរិមាណសាច់ដែលខ្វះខាតត្រូវបាននាំចូលពីបរទេសមកបំពេញតម្រូវការបន្ថែមសម្រាប់ម្ហូបអាហារ និងធ្វើជាវត្ថុធាតុដើមផលិតចំណីសត្វលម្អ (ផ្លែ ឆ្នា)។ ជាក់ស្តែងនៅក្នុងឆ្នាំ២០២៥ កម្ពុជាបាននាំចូលសាច់ និងផលិតសត្វសរុបចំនួន ២៩ពាន់តោន។

ការវាយតម្លៃស្ថានភាពប្រចាំឆ្នាំ២០២៥ ការបរិភោគសាច់សត្វនៅកម្ពុជាសម្រាប់មនុស្សម្នាក់ក្នុងមួយឆ្នាំ ហូបសាច់ជាមធ្យមប្រមាណ ១៨,៥គ.ក ក្នុងនោះមានសាច់គោ-ក្របីចំនួន ៥,១៥គ.ក សាច់ជ្រូកចំនួន ៩,៣៥គ.ក សាច់បក្សីចំនួន ៣,៩៥គ.ក និងសាច់ចៀម ពពែចំនួន ០,០៥គ.ក។

**ក្រាហ្វិកទី២៧៖ តម្រូវការសាច់ ការផ្គត់ផ្គង់ និងកង្វះខាត**




### ច. ការនាំចេញសត្វ និងផលិតផលសត្វ

កម្ពុជាមានលទ្ធភាពធ្វើការនាំចេញគោ-ក្របី ជ្រូក មាន់ ស្វាក្តាម សាច់ ផលិតផលសត្វ ចំណីសត្វ និងទឹកដោះគោទៅបរទេសផងដែរ។ ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ កម្ពុជាបាននាំចេញគោ-ក្របីចំនួន ១០,០៧ពាន់ក្បាល ជ្រូកសាច់ចំនួន ១៥,២៥ពាន់ក្បាល ជ្រូកពូជ(មេ បា) ចំនួន ៣,២៣ពាន់ក្បាល ទឹកដោះគោចំនួន ២,៨៦ពាន់តោន ចំណីឆ្កែចំនួន ៥៩,៤៩ពាន់តោន រោមសត្វចំនួន ២០៥តោន ស្បែកគោ-ក្របី ជ្រូកចំនួន ២៨,៦៧ពាន់តោន Gelatine ចំនួន ៨៤៨តោន និងកាកសំណល់ប្រេងឆាចំនួន ២៣១តោន។ ដោយឡែកនៅឆ្នាំ២០២៥ កម្ពុជាបាននាំចេញគោ-ក្របីចំនួន ១៩,៨៣ពាន់ក្បាល ជ្រូកពូជ(មេ បា) ចំនួន ១,១២ពាន់ក្បាល ចំណីឆ្កែចំនួន ២១,៧៣ពាន់តោន រោមសត្វចំនួន ៣៦,១៨តោន ស្បែកគោ-ក្របី ជ្រូកចំនួន ២,៥៦ពាន់តោន និងកាកសំណល់ប្រេងឆាចំនួន ១០៥តោន។

### ឆ. កម្មវិធីកែលម្អពូជ

ក្រសួងបានផ្សព្វផ្សាយបច្ចេកទេស និងផលប្រយោជន៍នៃការបង្កាត់គោ និងជ្រូកដោយសិប្បនិម្មិតដល់មន្ត្រីជំនាញផលិតកម្ម និងបសុពេទ្យាបាលទាំង២៥រាជធានី ខេត្ត។

នៅឆ្នាំ២០២៥ នេះ ការបង្កាត់គោដោយសិប្បនិម្មិតសម្រេចបានចំនួន ២១ ៥៩៦ក្បាល និងមេកើតកូនបានចំនួន ៦ ៦៨៧ក្បាល (ញី ៤ ១៩៨ក្បាល) ស្មើនឹង ៣៧% នៃមេដែលបានបង្កាត់សិប្បនិម្មិត។

### ជ. ចំណីសត្វ និងបសុឱសថ

កម្មវិធីកែលម្អចំណីសត្វ និងផ្សព្វផ្សាយពូជស្មៅដែលសំបូរទៅដោយសារធាតុចិញ្ចឹម និងផ្តល់ទិន្នផលខ្ពស់គឺជាសកម្មភាពដ៏អាទិភាពមួយដើម្បីជំរុញផលិតកម្មសត្វ។ បច្ចុប្បន្នការដាំដុះដំណាំចំណីសត្វ បានរីកសាយភាយយ៉ាងទូលំទូលាយនៅទូទាំង២៥រាជធានី ខេត្ត។ ជាក់ស្តែងក្នុងឆ្នាំ២០២៥ នេះ កន្លែងដាំដុះ និងធ្វើបង្ហាញដំណាំចំណីសត្វ សរុបចំនួន ៣ ២០៤កន្លែង លើផ្ទៃដីចំនួន ៣ ៥៥៣,១ហិកតា។

ក្នុងឆ្នាំ២០២៥នេះ ក្រុមហ៊ុនដែលបានវិនិយោគសាងសង់រោងចក្រផលិតចំណីសត្វ នៅក្នុងប្រទេសកម្ពុជាសរុបចំនួន ២៣ក្រុមហ៊ុន មានរោងចក្រផលិតចំណីចំនួន ២៥កន្លែង បាននិងកំពុងដំណើរការផលិតចំណីសត្វយ៉ាងសកម្ម

ដោយផលិតចំណីសត្វបានប្រមាណជាង២,០៧ លានតោន ស្មើនឹង៦១% នៃសមត្ថភាពផលិតរបស់រោងចក្រជាង ៣,៣៨លានតោន។

### ឈ. ការគ្រប់គ្រងកាកសំណល់សត្វ

ចាប់ពីឆ្នាំ២០០៦ ឡជីវឧស្ម័នគ្រួសារសម្រេចបានចំនួន ៣០ ៨៩៩ឡ (ឆ្នាំ២០២៥ ចំនួន ៤០១ឡ) ក្នុងខេត្តចំនួន ១៥ គឺខេត្តបាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពត កណ្ដាល ព្រៃវែង ពោធិ៍សាត់ សៀមរាប ស្វាយរៀង តាកែវ ត្បូងឃ្មុំ បន្ទាយមានជ័យ និងខេត្តព្រះវិហារ ដែលបានចូលរួមកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់។

ក្រោមហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាលចិន គម្រោងសាងសង់ឡជីវឧស្ម័នកម្ពុជា-ចិន សម្រេចបានចំនួន ២១៦ឡ ចាប់ពីចុងឆ្នាំ២០១៩ មកដល់បច្ចុប្បន្ន នៅក្នុងខេត្តចំនួន ៧ គឺ ខេត្តកំពង់ចាម កំពង់ឆ្នាំង ព្រះវិហារ ព្រៃវែង ពោធិ៍សាត់ ស្វាយរៀង និងខេត្តត្បូងឃ្មុំ។ ក្នុងឆ្នាំ២០២៥ ការសាងសង់ឡជីវឧស្ម័នជាលក្ខណៈគ្រួសារបានចំនួន ៣២ឡ ក្នុងនោះខេត្តព្រៃវែងចំនួន ២០ឡ និងខេត្តស្វាយរៀងចំនួន ១២ឡ។

ក្រោមហិរញ្ញប្បទានសម្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី គម្រោងខ្សែច្រវាក់ផលិតកម្មដោយភាតរបរិស្ថានបានសាងសង់ឡជីវឧស្ម័ននិងរោងជីកំប៉ុស្តគ្រួសារបានចំនួន ៧៣៤ រួមមាននៅខេត្តកំពង់ចាមចំនួន១១៥ កំពតចំនួន ២២៨ តាកែវចំនួន ២៣០ និងខេត្តត្បូងឃ្មុំចំនួន១៦១ ព្រមទាំងបានធ្វើបង្ហាញចំនួន ១៧៩ឡ។

**ក្រាហ្វិកទី២៨៖ ការសាងសង់ឡជីវឧស្ម័នតាមបណ្ដាខេត្ត**




### ញ. ការលើកកម្ពស់សុខុមាលភាពសត្វ

ក្រសួងបានធ្វើការត្រួតពិនិត្យចរាចរណ៍សត្វ និងផលិតផលសត្វសរុបចំនួន ៥០២ករណី ក្នុងនោះ ចរាចរណ៍សត្វ និងផលិតផលសត្វមានលិខិតអនុញ្ញាតត្រឹមត្រូវចំនួន ៤៦៥ករណី និងបង្ក្រាបបទល្មើសបានចំនួន ៣៧ករណី។

ចាក់វ៉ាក់សាំងការពារជំងឺឆ្លងសំខាន់ៗគ្រប់ប្រភេទលើគោ ក្របី ពពែ ចៀម ដូចជាជំងឺអុតក្តាម បូសខ្យល់ សារទឹក និងជំងឺដុំពកស្បែកគោ ក្របីសរុបចំនួន ១ ១៧២ ២០៨ក្បាល លើសត្វជ្រូកចំនួន ៣ ០១៧ ៨១៨ក្បាល លើបក្សីចំនួន ៣៤ ៦៦៣ ០៥៣ក្បាល ជម្ងឺឆ្កែឆ្កួតលើសត្វឆ្កែ និងឆ្មាចំនួន ២៤៦ ៨២១ក្បាល។ លើសពីនេះ ក្រសួងបានចាត់វិធានការជីវសុវត្ថិភាព ផ្សព្វផ្សាយ និងអនុវត្តផ្ទាល់នៅសត្តឃាតដ្ឋាន ទីផ្សារលក់សត្វ កសិដ្ឋានចិញ្ចឹមសត្វ កន្លែងចិញ្ចឹមសត្វ មធ្យោបាយដឹកជញ្ជូនសត្វនិងផលិតផលសត្វ និងកន្លែងផ្ទុះជំងឺសត្វសរុបចំនួន ២៨០ ៥៣០លើក។ បច្ចុប្បន្ននេះ ក្រសួងមានភ្នាក់ងារសុខភាពសត្វភូមិ ចំនួន ៨ ២២៣នាក់ (ស្ត្រី ៥៥៤នាក់) នៅទូទាំងប្រទេស ក្នុងការផ្តល់ប្រឹក្សាបច្ចេកទេស និងការចាក់វ៉ាក់សាំង។

## ង. ការលើកកម្ពស់សុខនាពសាធារណៈបសុព្យាបាល

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- បានបណ្តុះបណ្តាល និងចុះណែនាំបច្ចេកទេសធ្វើអាជីវកម្មសត្វ និងការពិឃាតសត្វចំនួន ៣៤លើក ដោយមានការចូលរួមពីម្ចាស់សត្តឃាតដ្ឋាន អាជីវករពិឃាតសត្វ និងអ្នកពាក់ព័ន្ធចំនួន ១៨៩នាក់ (ស្ត្រី ៣៥នាក់)
- បានចុះត្រួតពិនិត្យ បច្ចេកទេសបង្កើតសត្តឃាតដ្ឋានចំនួន ១០កន្លែង បន្តសុពលភាពសត្តឃាតដ្ឋានចំនួន ២២ និងបច្ចេកទេសលើការស្នើសុំធ្វើអាជីវកម្មពិឃាតសត្វជ្រូក គោក្របីប្រភេទ"ក" បានចំនួន ៦កន្លែង (នៅរាជធានីភ្នំពេញ៣កន្លែង បន្ទាយមានជ័យ២កន្លែង និងខេត្តកណ្តាល១កន្លែង)
- សត្តឃាតដ្ឋាននៅទូទាំងប្រទេសមានចំនួន ២៤១កន្លែង ក្នុងនោះមានសត្តឃាតដ្ឋានអនុលោមតាមអនុក្រឹត្យ ១០៨ ចំនួន ១៣០កន្លែង សត្តឃាតដ្ឋានអនុលោមតាមអនុក្រឹត្យ១០៨ និងវិនិយោគចំនួន ៦០កន្លែង និងសត្តឃាតដ្ឋានវិនិយោគចំនួន ៥១កន្លែង ព្រមទាំងសត្តឃាតដ្ឋានទំនើបចំនួន ៧កន្លែង ក្នុងនោះ បក្សីចំនួន ៤កន្លែង (កណ្តាល២ រាជធានីភ្នំពេញ១ កំពត១) និងជ្រូកចំនួន ៣កន្លែង (ត្បូងឃ្មុំ១ កំពត១ កណ្តាល១) និងបានកែលម្អការដឹកជញ្ជូនសាច់ និងផលិតផលសត្វចេញពីសត្តឃាតដ្ឋានទៅកាន់ទីផ្សារបានចំនួន ២០ សត្តឃាតដ្ឋាន
- មន្ទីរព្យាបាលសត្វ និងគ្លីនិកព្យាបាលសត្វនៅតាមបណ្តារាជធានី-ខេត្តសរុបចំនួន ៦៥កន្លែង ក្នុងនោះរាជធានីភ្នំពេញ ៤៤កន្លែង ខេត្តបាត់ដំបង ៧កន្លែង សៀមរាប ៤កន្លែង បន្ទាយមានជ័យ ៣កន្លែង ព្រះសីហនុ ៣កន្លែង កំពត ២កន្លែង កណ្តាល១ កន្លែង និងខេត្តកំពង់ស្ពឺ ១កន្លែង។

## ច. ការងារផ្សព្វផ្សាយបច្ចេកទេស

ក្រសួងបានផ្សព្វផ្សាយ តាមរយៈការសម្ភាសន៍ វេទិកាសាធារណៈ ប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលអំពីច្បាប់ លិខិតបទដ្ឋានគតិយុត្ត បច្ចេកទេសចិញ្ចឹមសត្វ ដាំដំណាំចំណីសត្វ និងជំងឺឆ្លងសត្វ ជាពិសេសជំងឺប៉េស្តជ្រូកអាហ្វ្រិក ជំងឺផ្តាសាយបក្សី និងជំងឺដុំពកលើស្បែកគោក្របី ដល់កសិករចិញ្ចឹមសត្វ និងអ្នកពាក់ព័ន្ធសរុបចំនួន ៦ ២២៧នាក់ (ស្ត្រី ១ ៩៥៨នាក់)។ ទន្ទឹមនេះ ក្រសួងក៏បានធ្វើការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ គេហទំព័រ និងហ្វេសប៊ុកជូនសាធារណៈជនផងដែរ។

## ឆ. ការងារចេញលិខិតអនុញ្ញាត និងចុះបញ្ជីកា

ក្រុមហ៊ុនចំណីសត្វចំនួន ១៣ បានចុះបញ្ជីកាចំណីសត្វ សារធាតុបន្ថែម និងវត្ថុធាតុដើមសរុបចំនួន ២៨៣មុខ ក្នុងនោះមានចំណីសត្វចំនួន ១៨៧មុខ វត្ថុធាតុដើមចំនួន ៦មុខ និងសារធាតុបន្ថែមចំនួន ៩០មុខ។ បន្ថែមពីនេះ ក្រុមហ៊ុនចំណីសត្វចំនួន ១ បានការអនុញ្ញាតឱ្យផលិត លាយផ្សំ ឬវេចខ្ចប់ជាថ្មីនូវចំណីសត្វ ព្រមទាំងក្រុមហ៊ុនបសុឱសថចំនួន១០ក្រុមហ៊ុន បានចុះបញ្ជីកាបសុឱសថ និងវ៉ាក់សាំងសរុបចំនួន ៥២៨មុខ។

ក្រុមហ៊ុនចំណីសត្វបានអនុញ្ញាតចុះបញ្ជីឃ្លាំងសន្និធិចំណីសត្វ និងបសុឱសថចំនួន ១៦ក្រុមហ៊ុន ក្នុងនោះក្រុមហ៊ុនចំណីសត្វចំនួន ១៥ និងក្រុមហ៊ុនបសុឱសថចំនួន ១។ ជាមួយគ្នានេះ ក្រសួងបានចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយចំណីសត្វចំនួន ១៦ក្រុមហ៊ុន ដែលមានយថាប្រភេទចំនួន ៩២៨មុខ និងលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយបសុឱសថចំនួន ៦ក្រុមហ៊ុន ដែលមានយថាប្រភេទចំនួន ៥៨០មុខ។

## ឈ. ការងារអធិការកិច្ច

ក្រសួងបានផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ និងបានបើកវគ្គបណ្តុះបណ្តាលស្តីពីការអប់រំសមត្ថភាពវិជ្ជាជីវៈ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតពាក់ព័ន្ធនឹងចំណីសត្វ និងបសុឱសថ ដល់អ្នកលក់ដុំនិងរាយចំណីសត្វ និងបសុឱសថចំនួនសរុប ១ ០៣១នាក់ (ស្ត្រីចំនួន ៣៧៩នាក់) ព្រមទាំងបានចាត់មន្ត្រីចុះធ្វើអធិការកិច្ចដេប៉ូលក់ដុំនិងរាយចំនួន ២៦៧ដេប៉ូ។

ឍ. ការងារស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- ធ្វើរោគវិនិច្ឆ័យលើសំណាកចំនួន ១៩ ១៤២ និងរកឃើញចំនួន ៣៧ករណី បង្កដោយវីរុស H5N1 សរុបចំនួន ១៦ រាជធានីខេត្ត(ភ្នំពេញ ១ករណី)
- អង្កេតឃ្លាំមើលវត្តមានជំងឺផ្តាសាយបក្សីនៅទីផ្សារបក្សីរស់ក្នុងខេត្តចំនួន ៨ រួមមាន៖ ខេត្តបាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ កំពត មណ្ឌលគីរី សៀមរាប និងខេត្តស្វាយរៀង និងជំងឺផ្តាសាយជ្រូក ប៉េស្តជ្រូកអាហ្វ្រិក អុតក្តាម រលូតកូនជ្រូក រលូតកូនគោ គ្រុន Q និងមេលីអូអ៊ីដូស៊ីសនៅតាមសត្តឃាតដ្ឋានក្នុងខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ធំ កំពត ក្រចេះ ភ្នំពេញ ព្រៃវែង សៀមរាប ស្វាយរៀង និងខេត្តតាកែវ
- ចុះយកវត្ថុវិភាគបានចំនួន ៤០៩វត្ថុវិភាគ ក្នុងនោះ មានសាច់បង្កកគ្រប់មុខចំនួន ៩៩វត្ថុវិភាគដែលនាំចូលពីបណ្តាប្រទេសនានា ដើម្បីរកវត្តមានសារធាតុរក្សាទុក បសុឱសថ សារធាតុជំរុញការលូតលាស់ បូរ៉ាក់ និងហ្វរម៉ាលីន ជាលទ្ធផលអវិជ្ជមាន។ ចំណែកប្រេងឆាចំនួន ១០វត្ថុវិភាគ សាច់ជ្រូកចំនួន ១០០វត្ថុវិភាគ សាច់គោចំនួន ១០០វត្ថុវិភាគ និងសាច់មាន់ចំនួន ១០០វត្ថុវិភាគ ដែលលក់នៅក្នុងតូបតាមដងផ្លូវជាតិ និងតាមទីផ្សារតាមបណ្តាខេត្តមួយចំនួន ដើម្បីធ្វើតេស្តរកវត្តមានកាកសំណល់អង់ទីប៊ីយ៉ូទិក សារធាតុគីមីហ្វ័រម៉ាលីន និងបូរ៉ាកនៅក្នុងផលិតផលសត្វដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ
- បានចុះសិក្សាស្រាវជ្រាវពូជសត្វ និងការកែលម្អពូជគោរបស់កសិករចំនួន ៤១៨គ្រួសារ មានគោចំនួន ៨៣៦ក្បាល ដោយមួយគ្រួសារយកគោចំនួន ២ក្បាល មកសិក្សា និងផ្តល់បច្ចេកទេសបង្កាត់សប្បនិម្មិតនិងកែលម្អពូជគោ ដែលមានកសិករចូលរួមចំនួន ៥៨នាក់ ស្រ្តីចំនួន ១៤នាក់
- បានធ្វើការស្រាវជ្រាវពិសោធន៍ការកែច្នៃដើមស្រូវផ្កាប់ជាចំណីគោជាលទ្ធផលសារធាតុចិញ្ចឹមនៃដើមស្រូវមិនទាន់ផ្កាប់ និងក្រោយពេលផ្កាប់ រយៈពេល៤៥ថ្ងៃ បានរកឃើញថា ដើមស្រូវមុនផ្កាប់មានប្រូតេអ៊ីន (CP) ត្រឹមតែ ៦,៨២% ប៉ុណ្ណោះ ប៉ុន្តែក្រោយផ្កាប់ប្រូតេអ៊ីនមានការកើនឡើងទ្វេដងរហូតដល់ទៅ ១២,២៤% ចំណែកផេះ (Ash) មានការថយចុះពី ២៨,៩០% មកត្រឹម ៥,៩២%
- ប្រមូលវត្ថុវិភាគចំណីសត្វតាមក្រុមហ៊ុន និងដេប៉ូលក់ចំណីសត្វបានចំនួន ៨៣៨ សំណាក (ចំណីសម្រេច ៨៣៧ និងវត្ថុធាតុដើម១)។

## ៥.៤ ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម

ក. ការងារអភិរក្ស និងគ្រប់គ្រងដែនជលផល

- បានចុះបញ្ជីកម្មសិទ្ធិទ្រព្យសម្បត្តិរដ្ឋតំបន់គ្រប់គ្រងជលផលចំនួន ៤ទីតាំង មានទំហំ២២ ១៥៥,១១ហិកតា (កន្លែងអភិរក្សជលផលទឹកសាប៣ទីតាំង និងតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គ១ទីតាំង)
- បានទម្លាក់ប្រអប់ជម្រកត្រីសិប្បនិម្មិតចំនួន ៧៩៧ នៅតាមតំបន់ឆ្នេរចំនួន ៤៣ទីតាំង (ផ្ទៃដី ១ ២១០,៦ហិកតា) នៅខេត្តកែប៧ទីតាំង កំពត១៥ ព្រះសីហនុ១២ និងខេត្តកោះកុង៩ទីតាំង
- បានដាំកូនឈើលើផ្ទៃដីទំហំ៤១៧ហិកតា ស្មើនឹងកូនឈើចំនួន ៣៥៦ ១៧៩ដើម (កូនឈើព្រៃលិចទឹកចំនួន ១៧៨ ៣៣៥ដើម និងកូនកោងកាងចំនួន ១៧៧ ៨៤៧ដើម) នៅតំបន់បឹងទន្លេសាប និងតាមតំបន់ឆ្នេរ
- បានសាងសង់ស្នាក់ការបណ្តែតទឹក១ខ្នង និងបោះពោងចំនួន១៨ ក្នុងតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គ ក្នុងខេត្តក្រចេះ និងខេត្តស្ទឹងត្រែង និងបានជួសជុលស្នាក់ការបណ្តែតទឹកចំនួន ៦ខ្នង ក្នុងបឹងទន្លេសាប និងបោះបង្គោលឈើចំនួន ៥០០បង្គោល ក្នុងខេត្តពោធិ៍សាត់ សម្រាប់ក្រុមល្បាតការពារកន្លែងអភិរក្សជលផល និងបង្កើនជម្រកត្រី

- មានកូនផ្សោតកើតថ្មីចំនួន ៨ក្បាល បានស្លាប់ ១ក្បាល ដូច្នេះសត្វផ្សោតសរុបចំនួន ១១១ក្បាល
- ជ្រូកទឹក ផ្សោតសមុទ្រ និងអណ្តើកសមុទ្រមានចំនួនកើនឡើងគួរឱ្យកត់សម្គាល់
- បានសាងសង់ធនាគារក្តាម១កន្លែង ក្នុងខេត្តកំពត ដែលមានរោងធ្វើពីឈើ១ខ្នង បែចំនួន៤ ស្តុកក្តាមមេ ២ ៦៦៥ក្បាល និងលែងកូនក្តាមទើបនឹងញាស់ប្រមាណជាង៤៨៥លានកូន
- បានរកឃើញសំបុកអណ្តើកសមុទ្រ១២ទីតាំង មានពងចំនួន ៦០០គ្រាប់ នៅឆ្នេរកោះព្រីងនិងកោះពូឡូវ៉ៃ ខេត្តព្រះសីហនុ និងសំបុកកន្ធាយក្បាលកង្កែបចំនួន ១២កន្លែង មានពងចំនួន ៤៩៤គ្រាប់ និងបានថៃបំប៉នអណ្តើកហ្លួងចំនួន ៣៤១ក្បាល និងបង្កាត់ភ្ញាស់អណ្តើកហ្លួងចំនួន ៥៩ក្បាល ទទួលបានពងចំនួន ៣៦៦គ្រាប់ញាស់បានចំនួន ៩៩ក្បាល នៅមជ្ឈមណ្ឌលអភិរក្សសត្វល្មូន ខេត្តកោះកុង
- បានលែងអណ្តើកសមុទ្រចំនួន ២៣ក្បាល កូនកន្ធាយក្បាលកង្កែបចំនួន ៩២ក្បាល លែងត្រីរាជចំនួន ១១ក្បាល ត្រីគល់រាំងចំនួន ៩ក្បាល ត្រីត្រសក់ចំនួន ១១ក្បាល និងអណ្តើកហ្លួងចំនួន ២ ចូលក្នុងដែនទឹកធម្មជាតិវិញ
- មានកសិដ្ឋានចិញ្ចឹមក្រពើសរុបចំនួន ២០៩ ក្នុងនោះបានចុះបញ្ជីចំនួន ៣៤កសិដ្ឋាន ដែលមានក្រពើសរុបចំនួន ៣០០ ៩៥១ក្បាល (កសិដ្ឋានចុះបញ្ជីមាន៥៥ ៩២៥ក្បាល) និងនាំចេញក្រពើទៅប្រទេសចិននិងប្រទេសវៀតណាមបានចំនួន ៣ ១០០ក្បាល
- បានចុះស្រាវជ្រាវនិងទប់ស្កាត់បទល្មើសជួញដូរប្រភេទវារីសត្វកម្រនិងជិតផុតពូជចំនួន ២៩ករណី ដោយរឹបអូសបានអណ្តើក កន្ធាយអាស៊ី និងប្រឡាំងកាសចំនួន ២៤៩ក្បាល
- បានពង្រឹងការងារល្បាតដោយប្រើយន្តការ ២៤/២៤ម៉ោង គួបផ្សំនឹងការប្រើជ្រូនតាមដានសកម្មភាពនេសាទល្មើសច្បាប់ក្នុងតំបន់គ្រប់គ្រង និងការពារសត្វផ្សោតទន្លេមេគង្គ ដោយរឹបអូសឧបករណ៍ឆក់បានចំនួន ១៨ករណី មងក្រឡាធំចំនួន ៣ ៧៣៤,៤ម៉ែត្រ និងសន្ទូចរនងចំនួន ២៦ ៨០១ម៉ែត្រ
- បានចុះអប់រំនិងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋមូលដ្ឋាន សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធស្តីពីសារៈសំខាន់នៃកន្លែងអភិរក្សជលផល ទីជម្រកវារីសត្វ និងប្រភេទធនធានជលផលកំពុងរងគ្រោះថ្នាក់បានចំនួន ៣០ដង អ្នកចូលរួមចំនួន ១ ៥០០នាក់ (ស្រី៥១៩ នាក់)។

## ខ. ការអភិវឌ្ឍសហគមន៍នេសាទ

- សហគមន៍នេសាទចំនួន ៥១៦ (ទឹកសាប៤៧៥ និងសមុទ្រ៤១) មានសមាជិកសរុបចំនួន ៣៣២ ១៦៨នាក់ (ស្ត្រី៣៥%) ត្រូវជា១៤៧ ៥១៨គ្រួសារ
- សហគមន៍នេសាទបន្ថែមចំនួន ៩ ដែលបូកយោងមានចំនួន ៤៦៧ បានចុះបញ្ជីទទួលស្គាល់ជាផ្លូវការ
- បានបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទដែលផុតអណត្តិចំនួន ១១សហគមន៍ និងជួយរៀបចំផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទចំនួន ៧១សហគមន៍
- មានសហគមន៍នេសាទចំនួន ១០ ក្នុងចំណោមសហគមន៍នេសាទចំនួន ៥២ ដែលបានស្នើសុំទៅក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានចុះបញ្ជីជាដីសាធារណៈរបស់រដ្ឋ
- បានរៀបចំវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយច្បាប់ស្តីពីជលនិងលិខិតបទដ្ឋានពាក់ព័ន្ធសហគមន៍នេសាទសរុបចំនួន ១៨៤វគ្គ ដល់សមាជិកសហគមន៍នេសាទនិងអ្នកពាក់ព័ន្ធចំនួន ៥ ៤៦១នាក់ (ស្ត្រី១ ៤១៤នាក់)
- បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការគាំទ្របច្ចេកទេសកែច្នៃនិងការជួយរកទីផ្សារ ដល់ក្រុមស្ត្រីកែច្នៃចំនួន ២៨ក្រុម ចំនួន ៣២០នាក់ មកពីសហគមន៍នេសាទចំនួន ១៥ នៅខេត្តកំពង់ធំ និងខេត្តពោធិ៍សាត់
- បានបង្កើតកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទចំនួន ៩កន្លែង បូកយោងដល់ដំណាច់ឆ្នាំ២០២៥ មានសរុបចំនួន ៥៨៦កន្លែង

- បានដាក់ស្លាកសញ្ញាចំនួន ១ ០១៤ស្លាក បោះបង្គោលក្នុងកន្លែងអភិរក្សជលផលបានចំនួន ៨១បង្គោល សម្រាប់ការពារត្រីមេពូជ និងបោះបង្គោលព្រំប្រទល់កន្លែងសហគមន៍នេសាទចំនួន ៦៣បង្គោល នៅសហគមន៍នេសាទក្នុងខេត្តកោះកុង និងខេត្តរតនគិរី
- សហគមន៍នេសាទតំបន់ទឹកសាប និងតំបន់សមុទ្រសរុបចំនួន ៧៧ ក្នុងនោះមានក្រុមសន្សំប្រាក់ចំនួន ១៣១ក្រុម ដែលមានទឹកប្រាក់បូកយោងដល់ឆ្នាំ២០២៥ ចំនួន ២៨៤ ០០០ ០០០រៀល
- បានផ្តល់ថវិកាចំនួន ៤៥៩ ៩០០ ០០០រៀល សម្រាប់ប្រេងល្បាត និងអាហារ ព្រមទាំងបានផ្តល់សម្ភារល្បាតមួយចំនួនរួមមាន ទូកល្បាត១១ ជ្រូន៦ អាវពោង១៦៨ អាវភ្លៀង១៩៣ អាវយឺត១១៩ GPS ១២ អាយកូម២៤ ទូរស័ព្ទដៃ២៧ កែវយិត៨ ពិល៥២ អង្រឹង៦៣ ម៉ាយក្រូហ្វូន១១ និងស្បែកជើងកវែង១២៧។

## គ. ការងារបង្ក្រាបបទល្មើសជលផល

ក្រសួងបានចងក្រងសំណុំរឿងបទល្មើសជលផលចំនួន ៣ ១៤៥ករណី (សមុទ្រ ៩២ករណី) ដោយបានបំផ្លាញវត្ថុតាងចំនួន ២ ៨៨២ករណី ពិន័យអន្តរការណ៍ចំនួន ៩៣ករណី (ប្រមូលបានថវិកាចំនួន ២៦៤ ២២១ ០០០រៀល ពីប្រាក់ពិន័យនិងការលក់វត្ថុតាង) និងបញ្ជូនសំណុំរឿងចំនួន ១៧០ករណី និងជនសង្ស័យចំនួន ២១១នាក់ ទៅតុលាការ។

ទន្ទឹមនេះ ក្រសួងក៏បានរឹបអូស និងបំផ្លាញចោល ដូចជា របាំងស្បៃមុង សាច់អួន លប លូស្បៃមុង លូសាច់អួន អួនអូសទឹកសាបរួមផ្សំឆក់ត្រជាក់ ឈិបយន្ត អួនហ៊ុម ឧបករណ៍ឆក់ត្រី សម្រាស់ លបកៃច្នៃឬលបកន្ទុយកណ្តុរ និងបានលែងត្រីចម្រុះចូលក្នុងធម្មជាតិវិញ ៣២ ១៧៥គីឡូក្រាម។

## ឃ. ការអភិវឌ្ឍវារីវប្បកម្ម

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- ការចិញ្ចឹមត្រីទទួលបានបរិមាណផលចំនួន ៣២៣ ៥៧០តោន កើនឡើង៣ ២៩០តោន ស្មើនឹង១,០៣% ការចិញ្ចឹមក្រពើសម្រេចបានចំនួន ២៨២ ៥៥០ក្បាល ថយចុះ២៧៥ក្បាល ស្មើនឹង០,១០% និងការផលិតកូនត្រីពូជសម្រេចបានចំនួន ២៧១ ៥០០ ០០០ក្បាល ថយចុះ៤ ០០០ ០០០ក្បាល ស្មើនឹង១,៤៥% ធៀបនឹងឆ្នាំ២០២៤
- បានស្រាវជ្រាវផលិតកូនពូជវារីសត្វប្រភេទថ្មីបាន៥ប្រភេទ មានត្រីខ្យា ត្រីគ្រំ ត្រីខ្ទឹង ត្រីត្រចៀកដំរី ត្រីក្រាយ ត្រីសណ្តាយ ត្រីអណ្តែងទន់ ត្រីពោ ត្រីព្រួល ត្រីអាំងកឹយ ត្រីឆ្តង់ ក្តាមសេះ និងក្តាមថ្មបានសរុបចំនួន ៩,៦៨ លានកូន និងបានស្រាវជ្រាវផលិតពូជត្រីប្រាជំនាន់ទី១ចំនួន ២០ ០០០កូន តាមកម្មវិធីជម្រើសពូជ
- បានកំណត់អត្តសញ្ញាណត្រីមេពូជដោយដាក់លេខកូដបាន៣ប្រភេទ មានត្រីប្រា ត្រីពោ និងត្រីសណ្តាយ
- បានផ្គត់ផ្គង់និងចែកចាយកូនត្រីពូជសម្រាប់ទិវាមច្ឆជាតិនិងកសិករចិញ្ចឹមចំនួន ១២ ១៧២ ០០០កូន
- បានបង្កើតបណ្តុំវារីវប្បករចំនួន ៥កន្លែង មានសមាជិកចំនួន១៥៨នាក់ (ស្រី១៤នាក់)
- បានផ្តល់វិញ្ញាបនបត្របញ្ជាក់ការអនុវត្តវារីវប្បកម្មល្អជូនកសិដ្ឋានចំនួន ១២កន្លែង និងចេញលិខិតអនុញ្ញាតឱ្យធ្វើវារីវប្បកម្មកសិដ្ឋានធំៗចំនួន ៣១ច្បាប់
- បានរៀបចំបណ្តុះបណ្តាល សិក្ខាសាលា និងផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្មអ្នកពាក់ព័ន្ធចំនួន ៨៥វគ្គ អ្នកចូលរួមចំនួន ៣ ២០១នាក់ (ស្រី៩២៦នាក់)
- បានបញ្ជូនមន្ត្រីចូលរួមបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សានៅក្រៅប្រទេសចំនួន ១៧វគ្គ អ្នកចូលរួមចំនួន ៣៦នាក់ (ស្រី១៣នាក់) និងបានទទួលនិស្សិតចំនួន ៣៣នាក់ មកពីគ្រឹះស្ថានសាធារណៈទាំងបី ចុះបំពេញកម្មសិក្សានៅតាមវិទ្យាស្ថាន និងមជ្ឈមណ្ឌល
- បានជំរុញការធ្វើកសិ-វារីវប្បកម្មចំនួន ៤០គ្រួសារ នៅខេត្តតាកែវ និងខេត្តកំពង់ធំ
- បានបោះពុម្ពសៀវភៅណែនាំស្តីពីការគ្រប់គ្រងជំងឺនិងសុខភាពត្រីទឹកសាប ជាភាសាខ្មែរចំនួន ២ ០០០ក្បាល។

### ង. ការងារបច្ចេកវិទ្យាកែច្នៃ និងគុណភាព

ក្រសួងបានពង្រឹងប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យគុណភាព សុវត្ថិភាពម្ហូបអាហារសម្រាប់ផល ផលិតផលជលផល ដើម្បីអនុលោមតាមស្តង់ដារសុវត្ថិភាពម្ហូបអាហារអន្តរជាតិរួមមាន៖

- ធ្វើសវនកម្ម និងវាយតម្លៃគុណភាព សុវត្ថិភាព លើសហគ្រាសកែច្នៃផលជលផលចំនួន ២០ សម្រាប់ផ្តល់វិញ្ញាបនបត្របញ្ជាក់និមិត្តសញ្ញាគុណភាព ដែលក្នុងនោះមានតែសហគ្រាសចំនួន ១០ ទទួលបានវិញ្ញាបនបត្រ
- បានគាំទ្របច្ចេកទេសដល់ទីតាំងកែច្នៃផលជលផលចំនួន ៦៨កន្លែង និងបានប្រមូលសំណាកចំនួន ៣១៤ (សំណាកចំនួន ១៤៥ ត្រូវបានវិភាគនៅមន្ទីរពិសោធន៍)
- កំពុងរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យសំណល់ឱសថវារីសត្វ និងសារធាតុគីមីក្នុងផលវារីវប្បកម្ម ដោយបានចុះពិនិត្យកសិដ្ឋានវារីវប្បកម្មចំនួន ១៩៨ ក្នុងខេត្តគោលដៅចំនួន ១០ ដោយប្រមូលសំណាកចំនួន ៣៣៨ ធ្វើវិភាគនៅមន្ទីរពិសោធន៍ និងកំពុងដំណើរការរៀបចំសហគ្រាសផ្សេងទៀតក្នុងការត្រៀមឯកសារតម្រូវ ដើម្បីបញ្ជូនទៅ DG Sante ក្នុងត្រីមាសទី១ឆ្នាំ២០២៦
- បានសហការជាមួយអង្គការ UNIDO ធ្វើអធិការកិច្ចត្រួតពិនិត្យផ្លូវការលើការអនុវត្តប្រព័ន្ធ HACCP នៅសិប្បកម្មផលិតទឹកត្រី លាង ឡេង និងក្រុមហ៊ុនផលិតផលម្សៅប្រហុក Conferel ព្រមទាំងបានផ្តល់បច្ចេកទេសដល់សហគ្រាសកែច្នៃជលផលផ្សេងទៀត ដែលមានសក្តានុពលសម្រាប់នាំចេញទៅកាន់ទីផ្សារអន្តរជាតិ និងបានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលពីបច្ចេកវិទ្យាក្រោយប្រមូលផលជលផល និងប្រព័ន្ធត្រួតពិនិត្យសុវត្ថិភាពម្ហូបអាហារ និងលក្ខខណ្ឌតម្រូវទីផ្សារសរុបបានចំនួន ៤៧លើក ដែលមានអ្នកចូលរួម ៨១៣ នាក់(ស្រី១៩០នាក់)
- បានជំរុញការអនុវត្តសេវាសាធារណៈតាមប្រព័ន្ធបញ្ជរតែមួយជាតិ ដោយបានចេញវិញ្ញាបនបត្រសុខភាពបានចំនួន ៣០ ជូនដល់ក្រុមហ៊ុនចំនួន ៧ ដើម្បីនាំចេញផល ផលិតផលជលផលសរុបចំនួន ៣១២ តោន ទៅកាន់ទីផ្សារនៃប្រទេសចិន វៀតណាម នូវែលហ្សេឡង់ និងប្រទេសអូស្ត្រាលី។

### ច. ការងារសិក្សាស្រាវជ្រាវធនធានជលផល

- បានស្រាវជ្រាវតាមដានការនេសាទដាយត្រី និងប្រភេទកូនត្រីទឹកសាបនៅក្នុងទន្លេមេគង្គនិងទន្លេសាប និងតាមដានការនេសាទប្រចាំថ្ងៃរបស់អ្នកនេសាទ និងសុខភាពអេកូឡូស៊ីទន្លេនៅខេត្តក្រចេះនិងខេត្តស្ទឹងត្រែង
- បានសិក្សាវាយតម្លៃសេដ្ឋកិច្ចត្រីទឹកសាប ប្រាក់ចំណូលរបស់អ្នកនេសាទ និងប្រសិទ្ធភាពឧបករណ៍នេសាទទឹកសាបនៅខេត្តពោធិ៍សាត់និងខេត្តបាត់ដំបង
- បានកំណត់អត្តសញ្ញាណប្រភេទត្រីសមុទ្រ និងសិក្សាលក្ខណៈជីវសាស្ត្រនិងប្រព័ន្ធអេកូឡូស៊ីគ្រែងឈាមនិងគ្រំចំពុះទានៅខេត្តកែប កំពត និងខេត្តកោះកុង
- របាយការណ៍ស្តីពីលទ្ធផលនៃការសិក្សាស្រាវជ្រាវខាងលើត្រូវបានបោះពុម្ពចំនួន ៨ច្បាប់។

### ឆ. ផល ផលិតផលជលផល

ក្នុងឆ្នាំ២០២៥នេះ ផល ផលិតផលជលផលអនុវត្តបាន ៩៧៨ ៥៦០តោន កើនលើសឆ្នាំមុន៥១ ៦២៦តោន ស្មើនឹង៥,៦% ធៀបនឹងឆ្នាំ២០២៤ រួមមាន៖

- ផលនេសាទទឹកសាប ៥១៤ ៨៣០តោន កើនឡើង៤៧ ៤៨៦តោន ស្មើនឹង១០,១៦% ធៀបនឹងឆ្នាំ២០២៤
- ផលនេសាទសមុទ្រ ១៤០ ១៦០តោន កើនឡើង ៨៥០តោន ស្មើនឹង០,៦១% ធៀបនឹងឆ្នាំ២០២៤
- ផលវារីវប្បកម្ម ៣២៣ ៥៧០តោន កើនឡើង៣ ២៩០តោន ស្មើនឹង១,០៣% ធៀបនឹងឆ្នាំ២០២៤។

**ក្រាហ្វិកទី២៩៖ ផលនេសាទទឹកសាប ផលនេសាទសមុទ្រ និងវារីវប្បកម្ម ឆ្នាំ ២០២១-២០២៥**




## ៥.៥ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានព្រៃឈើ និងសត្វព្រៃ

### ក. សហគមន៍ព្រៃឈើ

គិតត្រឹមឆ្នាំ២០២៥ សហគមន៍ព្រៃឈើមានចំនួន ៦៥៦ គ្របដណ្តប់លើផ្ទៃដីសរុប ៥៣០ ៦៦៣ហិកតា និងមានសមាជិកចំនួន ១៧២ ៨១១គ្រួសារ ក្នុងនោះ ក្រសួងបានប្រកាសទទួលស្គាល់ចំនួន ៥៤៤សហគមន៍ (ផ្ទៃដី ៤៥៥ ៨៣០ហិកតា) បានចុះកិច្ចព្រមព្រៀងបង្កើតព្រៃសហគមន៍ចំនួន ៤៧៣ (ផ្ទៃដី ៣៨៦ ៨១០ហិកតា) និងបានរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន ១៣០ ដែលមានផ្ទៃដីចំនួន ៩០ ៧៦៧ហិកតា។

**ក្រាហ្វិកទី៣០៖ ចំនួនសហគមន៍ព្រៃឈើពីឆ្នាំ២០២១-២០២៥**




### ខ. ការងារបកស្រាយគម្របព្រៃឈើ

ក្រសួងបានបញ្ចប់ការរៀបចំរបាយការណ៍បច្ចេកទេស បន្ទាប់ពីការពិនិត្យផ្ទៀងផ្ទាត់ និងកែសម្រួលការបកស្រាយគម្របព្រៃឈើឆ្នាំ២០២៤ រួចរាល់ ព្រមទាំងបានទាញយករូបភាពផ្កាយរណប L8L9 តាមកម្មវិធី eCognition និងទិន្នន័យ DEM (Digital Elevation Model) និង Esri Lancover ទូទាំងប្រទេស សម្រាប់ចាត់ថ្នាក់ ផ្ទៀងផ្ទាត់ និងបកស្រាយគម្របព្រៃឈើឆ្នាំ២០២៥។

### គ. ការគ្រប់គ្រងផល អនុផលព្រៃឈើ

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- ផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តសរុបចំនួន ២៥០គ្រឿង និងយានយន្តសរុបចំនួន ២៥៥គ្រឿង
- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ ជូនក្រុមហ៊ុនចំនួន ១៨ និងប្រជាជនចំនួន ១៣នាក់ ក្នុងនោះ ឈើហ៊ុបមូលសរុបចំនួន ១៧ ០២៥ម៉ែត្រគ្រីគុណ កូនឈើសរុបចំនួន ២៥៨ ៩១០ដើម អុសចម្រុះសរុបចំនួន ២៣៥ ០០២ស្ទែរ ឫស្សីចំនួន ១ ៣០០តោន និងជ័រទឹកចំនួន ៣៩១តោន។

### ឃ. ការគ្រប់គ្រងដីស្ថានីយដាំឈើ និងដីព្រៃសហគមន៍

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- ស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើ ក្រុមហ៊ុនដាំឈើដៃគូ និងដាំឈើដៃគូលក្ខណៈគ្រួសារ ចម្ការពូជ និងចម្ការរុក្ខទិវា ចំនួន ៩៩ទីតាំង ដែលមានផ្ទៃដីចំនួន ៥២២ ០២៨ហិកតា ស្ថិតក្នុងខេត្តចំនួន ២១ ក្នុងនោះ ២២ទីតាំងមានប័ណ្ណកម្មសិទ្ធិលើផ្ទៃដីចំនួន ១០៧ ៨៩៩ហិកតា។ បច្ចុប្បន្នការដាំឈើជាលក្ខណៈក្រុមហ៊ុនដៃគូសហការ និងលក្ខណៈគ្រួសារមានចំនួន ២០ទីតាំង លើផ្ទៃដីចំនួន ៩០ ០៤៦ហិកតា
- បានចូលរួមដាំឈើជាចម្ការថ្មីសរុបចំនួន ៦១ ៧៥៩ហិកតា ក្នុងនោះចម្ការរដ្ឋចំនួន ១៤៥ហិកតា វិស័យឯកជនទំហំ ២ ៧៦០ហិកតា និងដាំឈើក្នុងសម្បទានដីសេដ្ឋកិច្ច ដាំតាមទីសាធារណៈ ដងផ្លូវ វត្តអារាម សួនលំហែកម្សាន្តនានាចំនួន ៥៨ ៨៥៤ហិកតា
- បាន និងកំពុងថែទាំចម្ការឈើចាស់សរុបចំនួន ៧៤០ហិកតា នៅក្នុងខេត្តចំនួន ៥រួមមាន ខេត្តកំពង់ធំ កំពង់ឆ្នាំង តាកែវ ពោធិ៍សាត់ និងខេត្តបាត់ដំបង និងបានបណ្តុះកូនឈើចំនួន ១ ៩០២ ៦៩២ដើម (រដ្ឋ ២១៧ ០០០ដើម និងឯកជន ១ ៦៨៥ ៦៩២ដើម) ដោយបានចែកកូនឈើជូនប្រជាពលរដ្ឋដាំសរុបចំនួន ២១៧ ០០០ដើម។ ជាពិសេស បានរៀបចំព្រះរាជពិធីរុក្ខទិវា ៩ កក្កដា ឆ្នាំ២០២៥ នៅភូមិកសិដ្ឋាន ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** មានការចូលរួមពីថ្នាក់ដឹកនាំ ព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងប្រជាពលរដ្ឋនៅមូលដ្ឋាន
- បានទទួលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនទ្រព្យចំនួន ២ទីតាំង ស្មើផ្ទៃដីចំនួន ១៣,៩៩ហិកតា ក្នុងនោះ សួនបណ្តុះកូនឈើ **សម្តេច ហ៊ុន សែន** អ្នកលឿងចំនួន ០,៩០ហិកតា ស្ថិតនៅក្នុងភូមិព្រែកខ្សាយ ឃុំព្រែកខ្សាយ "ក" ស្រុកពាមរក៍ និងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើទួលព្រេជចំនួន ១៣,០៩ហិកតា ស្ថិតនៅភូមិអង្គតាសិត សង្កាត់ទួលព្រេជ ស្រុកអង្គស្នួល ខេត្តកណ្តាល
- បានចុះពិនិត្យ និងស្វែងរកទីតាំងដីដើម្បីបង្កើតជាស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ ក្នុងខេត្តកំពង់ធំ ចំនួន ៣ទីតាំង មានផ្ទៃដីសរុបចំនួន ៦៤១,៦៨ហិកតា ក្នុងនោះទីតាំងចម្ការឈើដាំមានផ្ទៃដីចំនួន ៥៦១,៩៥ហិកតា នៅអូរបឹងរូង-តាម៉ៅ ទីតាំងតំបន់ព្រៃទំនេររបស់រដ្ឋ ស្ថិតនៅក្នុងគម្រោងរេដបូក មានផ្ទៃដីចំនួន ៤៩,៩៧ហិកតា និងនៅក្នុងឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ មានផ្ទៃដីទំហំ ២៩,៧៧ហិកតា(ផ្ទៃដីវត្តចំនួន ២,៨១ហិកតា)
- បានចុះពិនិត្យដីព្រៃចំនួន ៦ ៨៦៨ហិកតា ស្ថិតនៅក្នុងឃុំស្ពៅ ស្រុកសេសាន ខេត្តស្ទឹងត្រែង និងបានចុះពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ លើទិន្នន័យដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើក្បាលរមាស១ និងក្បាលរមាស២ មានផ្ទៃដីសរុបចំនួន ១៤ ២០០ហិកតា ដើម្បីជំរុញការចុះបញ្ជី

- បានចុះបញ្ជីដីរដ្ឋតាមនីតិវិធីពិសេសចំនួន ៣ទីតាំង មានផ្ទៃដីសរុបទំហំ ២៤ ០០០,៨១ហិកតា
- បានចុះផ្ទៀងផ្ទាត់ទីតាំងចម្ការឈើដាំរបស់រដ្ឋចំនួន ៨៨៩,៦១ហិកតា (ដាំអាកាស្យា ៣៦៤,៥៧ហិកតា និងដាំប្រេងខ្យល់ចំនួន ៣៧៩,៨៧ហិកតា និងផ្សេងៗ ១៤៥,១៧ហិកតា) ដែលផ្ទៃដីទាំងនោះបានចុះបញ្ជីដីរដ្ឋចំនួន ៣៧ប័ណ្ណ ក្នុងនោះរដ្ឋបាលព្រៃឈើទទួលបានប័ណ្ណកម្មសិទ្ធិចំនួន ៣៦ប័ណ្ណ
- ចូលរួមចុះពិនិត្យ និងផ្ទៀងផ្ទាត់ទីតាំងដីចំនួន ៤១៥,៩១ហិកតា ដែលបានស្នើសុំកាត់ឆ្វៀលចេញពីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអូរជុំ សម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហេងប្រាឌ័រ និងក្រុមហ៊ុនវាសនា អិនវេសមេន ស្ថិតនៅស្រុកអណ្តូងមាស ខេត្តមណ្ឌលគិរី ដើម្បីធ្វើអនុប្បយោគដីឯកជនរបស់រដ្ឋសម្រាប់ប្រទានកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលកំពុងប្រើប្រាស់អាស្រ័យផល
- បានចុះពិនិត្យសំណើសុំអនុញ្ញាតរក្សាទុកផ្ទៃដីដែលមិនអាចធ្វើការដាំដុះបានចំនួន ១ ៣៥៦ហិកតា ក្នុងគម្រោងសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ភូ ម៉ាឌី អិនវេសមេនគ្រុប នៅខេត្តស្ទឹងត្រែង
- បានចុះពិនិត្យផ្ទៀងផ្ទាត់លើសំណើរបស់ឈ្មោះ មៀច ឃួន សុំធ្វើអនុប្បយោគកាត់ឆ្វៀលចេញពីចម្ការឈើស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើតាសួស ស្រុកកំចាយមារ ខេត្តព្រៃវែង ចំនួន ២ទីតាំង (ទី១ មាន ១,៧២ហិកតា និងទី២មាន ៣,៤៦ហិកតា)។ លើសពីនេះ បានចុះកំណត់អត្តសញ្ញាណប្រជាពលរដ្ឋចំនួន ១០០គ្រួសារ ដែលបានស្នើសុំកាត់ឆ្វៀលដីធ្វើប័ណ្ណកម្មសិទ្ធិចំនួន ៤៣២,០៦ហិកតា ចេញពីស្ថានីយ និងស្តារព្រៃឈើនេះផងដែរ។

## ង. ការងារឧស្សាហកម្ម ពាណិជ្ជកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- ការនាំចេញផលអនុផលព្រៃឈើមានចំនួនសរុប ៥៩៥,៥២លានដុល្លារអាម៉េរិកមានដូចជា៖ (១)ផលិតផលឈើ និងវត្ថុធ្វើពីឈើចំនួន ៤៧៣លានដុល្លារអាម៉េរិក និង(២)សត្វស្វាក្តាមចំនួន ១២២,៥២លានដុល្លារអាម៉េរិក
- ចុះពិនិត្យសំណើសុំបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើចំនួន ១៦កន្លែង និងពន្យារចំនួន ១៣កន្លែង
- បានចុះពិនិត្យសំណើសុំបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ (ច្រកចេញចូលតែមួយ) ចំនួន ១កន្លែង និងពន្យារចំនួន ៦កន្លែង
- បានចុះសិក្សាអត្រាកែច្នៃកូនឈើទៅជាឈើអារនៅខេត្តមណ្ឌលគិរី និងខេត្តឧត្តរមានជ័យ និងសិក្សាអំពីតម្រូវការប្រើប្រាស់និងការផ្គត់ផ្គង់ឈើ នៅខេត្តបាត់ដំបង ក្រចេះ តាកែវ ព្រៃវែង និងខេត្តមណ្ឌលគិរី
- រដ្ឋបាលព្រៃឈើ មានគម្រោងសហប្រតិបត្តិការអន្តរជាតិ និងសហការជាមួយដៃគូចំនួន ១៦គម្រោង។

## ច. ការងារសិក្សាស្រាវជ្រាវ និងអតិវឌ្ឍន៍ព្រៃឈើ និងសត្វព្រៃ

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- បានចុះទប់ស្កាត់និងបង្ក្រាបការជួញដូរសត្វព្រៃ ការដោះអន្ទាក់និងសិក្សាស្រាវជ្រាវវត្តមានសត្វព្រៃ និងបានចេញលិខិតអនុញ្ញាតនាំចេញសត្វព្រៃមានដោយបង្ករ និងលិខិតដឹកជញ្ជូនចេញក្រៅប្រទេសចំនួន ៥២សន្លឹក (សត្វស្វាក្តាម ៥១សន្លឹក ស្មើនឹង២២ ២៧៦ក្បាល និងទឹកឃ្មុំ ១សន្លឹកស្មើនឹង៣៧៨លីត្រ)។ ជាមួយគ្នានេះ បានចេញលិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃចំនួន ១១សន្លឹក (សត្វស្វាក្តាមចំនួន ១០សន្លឹកនិងសត្វដំរីស្រុកចំនួន ១សន្លឹក ជាពិសេសបានចេញលិខិតអនុញ្ញាតចិញ្ចឹមថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ១៤៥ច្បាប់ (សត្វក្រចៀកកាំ ១៣២ច្បាប់ និងសត្វព្រៃប្រភេទផ្សេងៗ ១៣ច្បាប់)

- បានចុះប្រមូលសំណាកចំនួន ២ ៨៥៣សំណាក (ឈាម ទឹកមាត់ លាមក ទឹកនោម និងចោះស្បែក) ពីសត្វប្រចៀវចំនួន ១ ២០៧ក្បាល (១៣ប្រភេទ) សំណាកទាំងនោះ បានយកទៅរក្សាទុកនៅវិទ្យាស្ថានជាតិអាឡែកហ្ស៊ី និងជំងឺឆ្លងរបស់សហរដ្ឋអាម៉េរិក សម្រាប់ធ្វើការសិក្សាស្រាវជ្រាវ
- បានចុះប្រមូលធនធានគ្រាប់ពូជនៃប្រភេទឈើសំខាន់ៗចំនួន ១៥ប្រភេទ និងបណ្តុះកូនឈើចំនួន ២០ ០០០កូន និងបានដាំប្រភេទឈើមានតម្លៃចំនួន ១២ ៥០០ដើម ត្រូវជា ១៣ប្រភេទ លើផ្ទៃដីទំហំ ១២ហិកតា ព្រមទាំងបានដាំបញ្ចូលឈើមានតម្លៃទៅក្នុងព្រៃធម្មជាតិចំនួន ៥ប្រភេទ និងឈើហូបផ្លែចំនួន ៤ប្រភេទ លើផ្ទៃដីទំហំ ២,៧៥ហិកតា និងថែទាំចម្ការឈើប្រភេទមានតម្លៃនិងឈើហូបផ្លែទំហំ ៤១ហិកតា និងឡូត៍ពិសោធន៍ ២កន្លែង (៣០ហិកតា) ដែលមានឈើ គ្រញូង ធ្នង់ និងក្រាច ស្ថិតនៅឃុំឃុនរាម ស្រុកបន្ទាយស្រី និងឃុំចាន់ស ស្រុកសូទ្រនិគម ខេត្តសៀមរាប ព្រមទាំងចុះអនុវត្តបច្ចេកទេសរុក្ខវប្បកម្មនៅតំបន់ស្តារព្រៃគ្រញូងឡើងវិញ និងឡូត៍ពិសោធន៍សរុបចំនួន ១៨០ហិកតា។

### ឆ. ការគ្រប់គ្រងឧទ្យានសួនសត្វ ព្រៃការពារ និងសួនរុក្ខជាតិ "ភ្នំតាម៉ៅ"

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- ឧទ្យានសួនសត្វ ព្រៃការពារ និងសួនរុក្ខជាតិ "ភ្នំតាម៉ៅ" បានកំពុងថែរក្សាសត្វព្រៃចំនួន ៣ ០៨៥ក្បាល ដោយឡែកសត្វព្រៃមានក្នុងស្តុកក្នុងខែធ្នូ ឆ្នាំ២០២៥ មានចំនួន ២ ១៧៦ក្បាល (បក្សី ៥៨ប្រភេទ ថនិកសត្វ ៤៨ប្រភេទ និងល្មូន ១៨ប្រភេទ)
- បានសង្គ្រោះសត្វថ្មីចំនួន ៦៣២ក្បាល ព្យាបាលសត្វព្រៃចំនួន ៤៥០ក្បាល និងបានដោះលែងទៅព្រៃធម្មជាតិវិញចំនួន ៥១០ក្បាល។ ជាងនេះទៀត បានធ្វើផ្លូវភ្លើងប្រវែង ១១គីឡូម៉ែត្រ សម្អាតអនាម័យជើងព្រៃចំនួន ៣៩ហិកតា ជួសជុលទ្រុងសត្វទំហំ ៣ ០៨៦ម៉ែត្រការ៉េ ជួសជុលផ្លូវប្រវែង ៤៥គីឡូម៉ែត្រ ធ្វើស្លាកសញ្ញាផ្សេងៗបានចំនួន ១៦៤ផ្ទាំង ដាំកូនឈើចំនួន ១ ០៧១ដើម និងបណ្តុះកូនឈើចំនួន ២ ៨០០ដើម ជាពិសេសបានធ្វើការអប់រំផ្សព្វផ្សាយដល់សិស្សសាលាចំនួន ១៥ ៨៤៧នាក់។

### ជ. ការងារអនុវត្តច្បាប់ស្តីពីព្រៃឈើ

ក្នុងឆ្នាំ២០២៥ សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងការកាប់រានដីព្រៃទទួលបានពីរដ្ឋបាលព្រៃឈើគ្រប់លំដាប់ថ្នាក់សរុបចំនួន ៤២៧ករណី (សំណុំរឿងបទល្មើសព្រៃឈើត្រូវពិន័យអន្តរការណ៍ចំនួន ១២៨ករណី និងសំណុំរឿងបទល្មើសព្រៃឈើបញ្ជូនទៅតុលាការចំនួន ២៩៩ករណី)។ ជាមួយគ្នានេះ វត្ថុតាងនៃបទល្មើសព្រៃឈើដែលបានចាប់ឃាត់ និងដកហូតរួមមាន៖ ឈើអារចម្រុះប្រភេទ ៣៨២ម៉ែត្រគ្រីគុណ ឈើមូល ១១៣ម៉ែត្រគ្រីគុណ កូនឈើ ៥០០ដើម ផ្លែសំរ៉ង ១០០គីឡូក្រាម បង្គោលក្រាក់ ៩១២ដើម ឈើជន្លង់ម្រេច ៤ ៨១១ដើម ធ្យូងចម្រុះ ៨ ៩៤៧គីឡូក្រាម អុស ៥០៩ស្ទែរ និង៦០០បាច់ ឫស្សី ២ ២៥០ដើម ជំនៀរពុះ ៣០ដុំ សត្វព្រៃចម្រុះប្រភេទ ២ ៦៩៣ក្បាលនិង២៦០គីឡូក្រាម ភ្លុកដំរី ២៥,០៧គីឡូក្រាម ឆ្អឹងដំរី ២២គីឡូក្រាម កុយរមាស ៨,៨៨គីឡូក្រាម ឆ្អឹងខ្លាធំ ៣,៥០គីឡូក្រាម ចង្កូមខ្លាធំ ១៥ចង្កូម ធ្មេញខ្លាធំ ៤២ធ្មេញ និងក្រចកខ្លាធំ ១០ក្រចក និងផ្ទៃដីព្រៃឈើដែលបានកាប់រានចំនួន ១ ៦៥១ហិកតា ឃាត់ខ្លួនជនល្មើសចំនួន ៧៨នាក់ និងអនុផលព្រៃឈើព្រមទាំងឧបករណ៍សម្ភារផ្សេងៗមួយចំនួនទៀត។

**ក្រាហ្វិកទី៣១៖ បទល្មើសព្រៃឈើពិន័យអន្តរការណ៍ និងទៅតុលាការពីឆ្នាំ២០២១-២០២៥**




# ៥.៦ ការងារសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស

## ៥.៦.១ អភិវឌ្ឍន៍ធនធានមនុស្ស

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានមន្ត្រីរាជការសរុបចំនួន ៦ ៩៩១នាក់ ស្រី ២ ៥៥៦នាក់ ស្មើនឹង ៣៦,៥៦% ក្នុងនោះអង្គភាពថ្នាក់កណ្តាលមានចំនួន ៤ ៣៥០នាក់ ស្រី ១ ៩៧៩នាក់ ស្មើនឹង៤៥,៤៩% និងថ្នាក់រាជធានី ខេត្តមានចំនួន ២ ៦៤១នាក់ ស្រី ៥៧៧នាក់ ស្មើនឹង២១,៨៤%។

ក្រសួងបានផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីរាជការចំនួន ៣ ៤៤៤នាក់ (ស្រ្តី ៩០៤នាក់) រួមមាន៖ ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លីបានចំនួន ៣ ០១៧នាក់ (ស្រ្តី ៨០៦នាក់) និងវគ្គបណ្តុះបណ្តាលក្រៅប្រទេសបានចំនួន ៤៣៥នាក់ (ស្រ្តី ១០៤) ដែលមានរយៈពេលខ្លីចំនួន ៤២៥នាក់ រយៈពេលមធ្យមចំនួន ២នាក់ និងរយៈពេលវែងចំនួន ៨នាក់ (បរិញ្ញាបត្រជាន់ខ្ពស់ចំនួន ៦នាក់ និងថ្នាក់បណ្ឌិតចំនួន ២នាក់)។

ដោយឡែក តាមគ្រឹះស្ថានអប់រំកសិកម្មទាំងបី មាននិស្សិតកំពុងសិក្សាសរុបចំនួន ៦ ០៣៣នាក់ (ស្រ្តី ២ ៣៥៦នាក់) និងនិស្សិតបញ្ចប់ថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ បសុវេជ្ជបណ្ឌិត អនុបណ្ឌិត និងថ្នាក់បណ្ឌិតសរុបចំនួន ១ ៣០៥នាក់ (ស្រ្តី ៥១១នាក់)។

**ក្រាហ្វិកទី៣២៖ ស្ថានភាពមន្ត្រីរាជការក្របខ័ណ្ឌ ឆ្នាំ២០២១-២០២៥**



### ៥.៦.២ ការងាររៀបចំផែនការយុទ្ធសាស្រ្ត

ក្រសួងបានចូលរួមចំណែកយ៉ាងសកម្មក្នុងការរៀបចំធាតុចូលសម្រាប់សូចនាករក្នុងយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្មសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា។ ទន្ទឹមនេះ ក្រសួងបានរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០២៦-២០២៨ គម្រោងថវិកាកម្មវិធីឆ្នាំ២០២៦ កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០២៦-២០២៨ និងបានបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសដល់មន្ត្រីនៅថ្នាក់កណ្តាល និងរាជធានី ខេត្តសរុបចំនួន ១ ០៧៧នាក់ ពាក់ព័ន្ធនឹងការអនុវត្តថវិកាសមិទ្ធកម្ម ប្រព័ន្ធតាមដាននិងវាយតម្លៃថវិកាកម្មវិធី ប្រព័ន្ធព័ត៌មានស្ថិតិ និងតម្លៃទីផ្សារកសិកម្ម ព្រមទាំងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម។ លើសពីនេះ ក្រសួងបានរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្រ្ត គោលនយោបាយ និងផែនការអភិវឌ្ឍន៍យុទ្ធសាស្រ្តនានាពាក់ព័ន្ធនឹងវិស័យកសិកម្ម និងរបាយការណ៍ប្រចាំសប្តាហ៍ជូនប្រមុខរាជរដ្ឋាភិបាលកម្ពុជា។

### ៥.៦.៣ ការងារគ្រប់គ្រងហិរញ្ញវត្ថុ

ការងារគ្រប់គ្រងហិរញ្ញវត្ថុ ក្រសួងបានទទួលកញ្ចប់ឥណទានថវិកាសម្រាប់ចំណាយក្នុងឆ្នាំ២០២៥ សរុបចំនួន ៣២២ ៦៦២លានរៀល ក្នុងនោះ ថវិកាសម្រាប់អង្គភាពថ្នាក់កណ្តាលចំនួន ២១៥ ៣៤៤លានរៀល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តចំនួន ១០៧ ៣១៨លានរៀល និងអនុវត្តសម្រេចបានចំនួន ៣១៥ ២៥៦លានរៀល ស្មើនឹង៩៦,១២% ធៀបនឹងឥណទានថ្មីឆ្នាំ២០២៥។ ការអនុវត្តចំណាយថវិកាឆ្នាំ២០២៥ សម្រេចបានទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន ៣,៩៨% ដោយសារមន្ត្រីកសិកម្មឃុំចំនួន ៣៧២នាក់ទើបតែជ្រើសរើសចុងឆ្នាំ ហេតុដូច្នេះថវិកាដែលបានគ្រោងក្នុងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៥ មិនអាចអនុវត្តបានពេញលេញ។ ទន្ទឹមនេះ ការប្រមូលចំណូលមិនមែនសារពើពន្ធសម្រេចបានចំនួន ៦៥ ០៣៤លានរៀលស្មើនឹង ១៣២,១០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៥។

### ៥.៦.៤ ការងារសវនកម្មផ្ទៃក្នុង

ក្រសួងបានចុះធ្វើសវនកម្មសម្រេចបាន ៤៤សវនដ្ឋាន ស្មើនឹង ១០០% នៃផែនការ ដោយរកឃើញលទ្ធផលសវនកម្ម និងផ្តល់អនុសាសន៍សម្រាប់សវនដ្ឋានកែលម្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងចំនួន ១៧២អនុសាសន៍ និងការអនុវត្តអនុសាសន៍គ្រាមុនរបស់សវនដ្ឋានសម្រេចបានចំនួន ៦១,៧៨% នៃផែនការចំនួន ៦០%។ បានចុះធ្វើសវនកម្មតាមអង្គភាពអនុវត្តគម្រោងដៃគូអភិវឌ្ឍន៍នានាក្រោមឱវាទក្រសួង និងចុះពិនិត្យការអនុវត្តថវិកានៅតាមអង្គភាពជំនាញមួយចំនួន។ ទន្ទឹមនេះ ក្រសួងបានណែនាំឱ្យខិតខំពង្រឹងសមត្ថភាពចំណេះដឹងបច្ចេកទេសសវនកម្ម និងការសិក្សាស្រាវជ្រាវបន្ថែមជាបន្តបន្ទាប់ ដើម្បីរុករកលទ្ធផលសវនកម្ម និងការសរសេររបាយការណ៍សវនកម្មឱ្យកាន់តែល្អថែមទៀត។

### ៥.៦.៥ ការងារសហប្រតិបត្តិការអន្តរជាតិ

ក្រសួងបាននិងកំពុងពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិទាំងក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី ក្នុងក្របខណ្ឌអាស៊ាន ព្រមទាំងសហការល្អប្រសើរ និងស្អិតរមួតជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ស្ថានទូត អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជននានា ដើម្បីគៀរគរទាំងជំនួយបច្ចេកទេស ជំនួយហិរញ្ញវត្ថុ និងបង្កើនការចរចាជាមួយបណ្តាលប្រទេសដែលមានសក្តានុពលដើម្បីដោះស្រាយលក្ខខ័ណ្ឌតម្រូវនានាដែលពាក់ព័ន្ធនឹងការនាំចេញផលិតផលនិងកសិផលរបស់កម្ពុជាទៅលើទីផ្សារអន្តរជាតិ។ ក្នុងឆ្នាំ២០២៥ ក្រសួងបន្តពង្រឹងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីអភិវឌ្ឍវិស័យកសិកម្មឲ្យមានលក្ខណៈទំនើប និងសមស្របនឹងស្ថានភាពជាក់ស្តែង និងការវិវឌ្ឍនាពេលអនាគត។ ទន្ទឹមនេះ ក្រសួងបានចុះកិច្ចព្រមព្រៀង ពិធីសារ គម្រោង និងអនុស្សរណៈយោគយល់គ្នាសរុបចំនួន ២៤ ដែលមានទឹកប្រាក់សរុប ១៩ ៤៨៥ ៥៨៩ ដុល្លារអាម៉េរិក រួមមានគម្រោងក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី និងអង្គការអន្តរជាតិ។ ក្រសួងក៏បាននិងកំពុងសម្របសម្រួលចុះកិច្ចព្រមព្រៀង គម្រោង និងអនុស្សរណៈយោគយល់គ្នាចំនួន ១៤ ដែលមានទឹកប្រាក់សរុបចំនួន ១២ ៧៧៩ ២២៧ ដុល្លារអាម៉េរិក។

### ៥.៦.៦ ការងារនីតិកម្មកសិកម្ម

ក្នុងឆ្នាំ២០២៥នេះ ច្បាប់ស្តីពីជលផល បានប្រកាសដោយព្រះរាជក្រមលេខនស/រកម/០៦២៥/០២៨ ចុះថ្ងៃសៅរ៍ ៣កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ និង សេចក្តីព្រាងច្បាប់ចំនួន ២ ពាក់ព័ន្ធនឹងអនុវិស័យព្រៃឈើ និងសេចក្តីព្រាងច្បាប់ស្តីពី ផលិតកម្មតាមកិច្ចសន្យា បាននិងកំពុងរៀបចំដើម្បីស្នើសុំការពិនិត្យ សម្រេច។ ទន្ទឹមនេះ ក្រសួងក៏បាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ចំនួន ៣ ព្រះរាជក្រឹត្យចំនួន ២ សេចក្តីព្រាងអនុក្រឹត្យចំនួន ៥ និង សេចក្តីព្រាងប្រកាសចំនួន ៨ ដែលទាក់ទងនឹងការងារគ្រប់គ្រងជីថ្នាំនិងជីកសិកម្ម ការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ សត្វឃាតដ្ឋាន តំបន់គ្រប់គ្រងព្រៃឈើ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមូលនិធិអភិវឌ្ឍន៍សហគមន៍កសិកម្ម។ លើសពីនេះ ក្រសួងបានពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ សេចក្តីព្រាងព្រះរាជក្រឹត្យ សេចក្តីព្រាងអនុក្រឹត្យ ប្រកាស និងឯកសារគតិយុត្តផ្សេងៗដែលពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ៣៧ករណី។ ជាពិសេសបានចុះពង្រឹងការអនុវត្តច្បាប់ក្នុងវិស័យកសិកម្មតាមមន្ទីរចំនួន ១៨ខេត្ត មានអ្នកចូលរួមសរុប ៤៩៤នាក់(ស្រី៨៤)។

### ៥.៦.៧ ការងារអធិការកិច្ច

ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពការងារ ក្រសួងបានចុះធ្វើអធិការកិច្ចលើការងារដឹកនាំ គ្រប់គ្រង និងពិនិត្យតាមបណ្តាអង្គភាពក្រោមឱវាទក្រសួងបានចំនួន ៩អង្គភាព និងទទួលពាក្យបណ្តឹងចំនួន ៦ករណី ហើយបានចុះអង្កេតស្រាវជ្រាវចំនួន ៥ករណី។ ទន្ទឹមនេះ ក្រសួងបានចេញលិខិតកែលម្អចំនុចខ្វះខាត ចំនួន៦លិខិតស្មើនឹង ៦អង្គភាព និងដាក់ទណ្ឌកម្មខាងវិន័យផ្អែកតាមច្បាប់ស្តីពីលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ចំពោះមន្ត្រីដែលមានកំហុសឆ្គងចំនួន ៦នាក់ (ថ្នាក់កណ្តាល ១នាក់ ថ្នាក់ក្រោមជាតិ ៥នាក់)។

### ៥.៦.៨ ការងារគ្រប់គ្រងឯកសារ និងប្រព័ន្ធព័ត៌មាន

ក្រសួងបានរៀបចំយុទ្ធសាស្ត្រឌីជីថលូបនីយកម្ម ឆ្នាំ២០២៥-២០២៨ សម្រាប់អនុវត្តក្នុងរយៈពេល៥ឆ្នាំ ក្នុងគោលបំណងពង្រឹងសមត្ថភាពអង្គភាព រៀបចំហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងពង្រឹងសមត្ថភាពធនធានមនុស្សក្នុងការគ្រប់គ្រង និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលយ៉ាងពេញលេញក្នុងវិស័យកសិកម្ម។ ទន្ទឹមនេះ ក្រសួងបានបង្កើតមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យរួមមួយក្នុងការគ្រប់គ្រងប្រតិបត្តិការ និងរក្សាសុវត្ថិភាពព័ត៌មាន ទិន្នន័យ សម្រាប់គាំទ្រដល់អភិបាលកិច្ចល្អ បង្កើនប្រសិទ្ធភាព និងផលិតភាពការងារ និងបានសិក្សាបង្កើតកម្មវិធីទូរស័ព្ទ (Mobile App) ដែលជាថ្នាលឌីជីថលនៃទិន្នន័យកសិកម្ម សម្រាប់ប្រើប្រាស់រួមគ្នា ដើម្បីផ្តល់ភាពងាយស្រួលដល់កសិករ និងអ្នកពាក់ព័ន្ធក្នុងវិស័យកសិកម្មទំនាក់ទំនងគ្នា និងបង្កើនទីផ្សារសម្រាប់កសិករ ព្រមទាំងជួយគាំទ្រ និងដោះស្រាយបញ្ហានានារបស់កសិករបានឆាប់រហ័ស។ លើសពីនេះ ក្រសួងបានចូលរួមអនុវត្តគោលនយោបាយរដ្ឋាភិបាលឌីជីថល និងក្របខ័ណ្ឌសេដ្ឋកិច្ច និងសង្គមឌីជីថល ដោយបាននិងកំពុងប្រើប្រាស់ថ្នាល Verify.gov.kh នៅលើសញ្ញាបត្រនិស្សិតរបស់គ្រឹះស្ថានឧត្តមសិក្សាទាំង៣ និងការដាក់ qr.gov.kh លើឯកសារផ្លូវការព្រមទាំងការភ្ជាប់ QR Verify ក្នុងថ្នាល CamDX លើប្រព័ន្ធផ្តល់សេវាសាធារណៈតាមអនឡាញ។

ក្រសួងបានផ្សព្វផ្សាយព័ត៌មានចំនួន ៣ ២៤១ព័ត៌មានដូចខាងក្រោម៖

- ផ្សព្វផ្សាយតាមទំព័រហ្វេសបុក (Facebook) សរុបចំនួន ១ ៤៨៩ព័ត៌មាន ក្នុងនោះមានវីដេអូ ២២០វីដេអូ
- គេហទំព័រ (Website) សរុបចំនួន ១ ៣២៦ព័ត៌មាន ក្នុងនោះមានវីដេអូ ២០០វីដេអូ
- តេឡេក្រាម (Channel Telegram) សរុបចំនួន ១ ៤០៧ព័ត៌មាន ក្នុងនោះមានវីដេអូ ២០៩វីដេអូ
- យូធូបឆែណែល (Channel You tube) ចំនួន ២០០វីដេអូ និងផ្សាយតាមស្ថានីយ៍ទូរទស្សន៍ (ទទក BTV អប្សរា) សរុបចំនួន ១២៤វីដេអូ។

### ៥.៦.៩ ការងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ក្រសួងផ្តល់ព័ត៌មានបច្ចេកទេសកសិកម្មដល់កសិករ និងអតិថិជន (CallCenter) បានជួយដោះស្រាយបញ្ហា និងផ្តល់ព័ត៌មានបច្ចេកទេសកសិកម្មដល់កសិករ និងអតិថិជនមកពីរាជធានី ខេត្ត រួមមាន ការផ្តល់បច្ចេកទេសកសិកម្ម (ដំណាំស្រូវ បន្លែ ការចិញ្ចឹមសត្វ ការប្រើប្រាស់ជី ថ្នាំសម្លាប់សត្វល្អិត ស្មៅ...) ព័ត៌មានតម្លៃស្រូវ ការណែនាំវិធីសាស្រ្តសម្រាប់ទប់ស្កាត់ និងកម្ចាត់កត្តាចង្រៃ ការធ្លាក់ចុះតម្លៃកសិផល (ស្វាយកែវរមៀត ដំឡូងមី បន្លែ...) នីតិវិធីក្នុងការបើកអាជីវកម្មជីនិងថ្នាំកសិកម្ម នីតិវិធីស្នើសុំបើកគ្លីនិកព្យាបាលសត្វ នីតិវិធីនៃការចុះបញ្ជិការជីនិងថ្នាំកសិកម្ម នីតិវិធីនៃការនាំចេញ នាំចូលផលិតផលកសិកម្ម និងព័ត៌មានផ្សេងៗជាច្រើនទៀត។ ជាមួយគ្នានេះបានផលិតវីដេអូបច្ចេកទេស ករណីសិក្សាដែលជោគជ័យ ចំណាប់អារម្មណ៍របស់ប្រជាកសិករ បានចំនួន ១ ១៦៥វីដេអូ និងបានផ្សព្វផ្សាយបានចំនួន ១៦១ដង។ ក្រសួងបានដាក់ពង្រាយមន្រ្តីកសិកម្មឃុំចំនួន ១ ៦០០នាក់ ទូទាំងប្រទេស ដើម្បីជួយដោះស្រាយទាន់ពេលវេលា និងបានផ្តល់សេវាបច្ចេកទេសកសិកម្មដល់កសិករចំនួន ៥៥៤ ១១៧គ្រួសារ ពាក់ព័ន្ធនឹង ការដាំដុះដំណាំស្រូវ ការផលិតស្រូវសរីរាង្គ ការប្រើប្រាស់ជីនិងថ្នាំកសិកម្ម ការដាំដំណាំគម្របដី ការដាំបន្លែ ការចិញ្ចឹមសត្វ និងបច្ចេកទេសផ្សេងៗទៀតពាក់ព័ន្ធនឹងវិស័យកសិកម្ម។ លើសពីនេះ មន្រ្តីបច្ចេកទេសកសិកម្មឃុំបានរៀបចំវគ្គបណ្តុះបណ្តាលដល់កសិករចំនួន ៩ ១៤០វគ្គ ចូលរួមដោះស្រាយបញ្ហារបស់កសិករពាក់ព័ន្ធនឹងបច្ចេកទេសដាំដុះ ការគ្រប់គ្រងកត្តាចង្រៃនិងជំងឺលើដំណាំស្រូវ បន្លែ និងទីផ្សារ បានចំនួន ៧ ៩៦៨បញ្ហា និងបានជួយវិភាគថ្លៃដើមកសិផលរបស់កសិករបានចំនួន ៣០ ៧១២គ្រួសារ និងបានចុះជួបប្រជាកសិករនៅតាមទីវាលបានចំនួន ៣៣៩ ៨៩៨ នាក់(ស្រ្តី១៣៤ ៩៥៩នាក់)។

### ៥.៦.១០ ការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ក្រសួងបានចុះគាំទ្របច្ចេកទេស តាមដាន ត្រួតពិនិត្យលើមុខងារដែលបានផ្ទេរទៅឱ្យថ្នាក់ក្រោមជាតិ ស្របតាមផែនការប្រចាំឆ្នាំនៅរដ្ឋបាលខេត្តមួយចំនួនមាន៖ ខេត្តប៉ៃលិន កំពត កោះកុង ពោធិ៍សាត់ ព្រៃវែង ស្ទឹងត្រែង បាត់ដំបង សៀមរាប កណ្តាល និងខេត្តមណ្ឌលគិរី។ ក្រសួងក៏បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាព និងដោះស្រាយបញ្ហាប្រឈមនានានៃការអនុវត្តការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជាបន្តបន្ទាប់ផងដែរ។ ទន្ទឹមនេះ ក្រុមការងារបានប្រជុំពិភាក្សាលើការរៀបចំសេចក្តីព្រាងសេចក្តីណែនាំបច្ចេកទេសសម្រាប់គ្រប់គ្រងអនុវត្តបែបបទ និងនីតិវិធីលើមុខងារសេវាសុខភាពសត្វ និងផលិតកម្មសត្វ ដែលប្រតិភូកម្មទៅឱ្យរដ្ឋបាលរាជធានី ខេត្តចំនួន ៤លើក និងបានចូលរួមប្រជុំ សិក្ខាសាលា វេទិកា ពាក់ព័ន្ធ សំដៅផ្លុះបញ្ចាំងការងារ ដោះស្រាយបញ្ហាប្រឈមផ្សេងៗ ជាពិសេសវេទិការាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិក្រោមប្រធានបទ "**កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០**" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្រ្តី នៃព្រះរាជាណាចក្រកម្ពុជា**។ ជាមួយគ្នានេះ អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត បានផ្តល់សេវាក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សរុបប្រមាណ១៦៦ ២៥៣សេវា ដែលទទួលបានចំណូលសរុបចំនួន ៥ ៥៧៨ ៤៧៧ ៦០០រៀល។

### ៥.៦.១១ ការងារសម្បទានដីសេដ្ឋកិច្ច

គម្រោងសម្បទានដីសេដ្ឋកិច្ចវិនិយោគលើដំណាំកសិ-ឧស្សាហកម្ម មានសរុបចំនួន ២២៩គម្រោង ស្ថិតក្នុងខេត្តចំនួន១៩ នៅទូទាំងប្រទេសរួមមាន ខេត្តក្រចេះ ៤៨គម្រោង កំពង់ធំ ២៦គម្រោង ព្រះវិហារ ២៦គម្រោង មណ្ឌលគិរី ២៥គម្រោង រតនគិរី ២៥គម្រោង កំពង់ស្ពឺ ១៧គម្រោង ស្ទឹងត្រែង ១៣គម្រោង ឧត្តរមានជ័យ ១២គម្រោង ត្បូងឃ្មុំ ៨គម្រោង កោះកុង ៧គម្រោង សៀមរាប ៥គម្រោង កំពត ៤គម្រោង ព្រះសីហនុ ៤គម្រោង ពោធិ៍សាត់ ២គម្រោង

បន្ទាយមានជ័យ ២គម្រោង បាត់ដំបង ២គម្រោង កំពង់ចាម ១គម្រោង តាកែវ ១គម្រោង និងខេត្តស្វាយរៀង ១គម្រោង ដែលមានផ្ទៃដីតាម "សជណ" សរុបទំហំ ១ ៣៩១ ៦៧៥ហិកតា។ គិតត្រឹមឆ្នាំ២០២៥នេះ ក្រសួងបាន៖

- ការចុះកិច្ចសន្យាវិនិយោគសរុបចំនួន ២០៦គម្រោង (ក្នុងនោះផងដែរគម្រោងវិនិយោគដែលបានចុះកិច្ចសន្យាថ្មី (៥០ឆ្នាំ) មានចំនួន ៨គម្រោង និងកិច្ចសន្យាកែសម្រួលមានចំនួន ៨៣គម្រោង) និងមិនទាន់ចុះកិច្ចសន្យាចំនួន ២៣គម្រោង
- ការចុះបញ្ជីដីរដ្ឋក្នុងគោលដៅសម្បទានដីសេដ្ឋកិច្ចសរុបចំនួន ១៨៦គម្រោង លើផ្ទៃដីទំហំ ៧៦៥ ៨១៨,៦៧ ហិកតា និងមិនទាន់បានចុះបញ្ជីដីរដ្ឋរួចរាល់ចំនួន ៤៤គម្រោង (បូករួមទាំងផ្ទៃដីចុះបញ្ជីដីរដ្ឋរបស់ក្រុមហ៊ុនភាពីម៉ិច គ្រុប ដែលរាជរដ្ឋាភិបាលបានសម្រេចដកហូត)
- ការធ្វើអនុប្បយោគមានចំនួន ១៥៩គម្រោង លើផ្ទៃដីទំហំ ១ ០៥៨ ៨៥៨ហិកតា និងមិនទាន់បានធ្វើអនុប្បយោគចំនួន ៧១គម្រោង (បូករួមទាំងផ្ទៃដីចុះបញ្ជីដីរដ្ឋរបស់ក្រុមហ៊ុន ភាពីម៉ិច គ្រុប ដែលរាជរដ្ឋាភិបាលសម្រេចដកហូត)
- ដំណាំកសិ-ឧស្សាហកម្មជាដំណាំចម្បង ត្រូវបានយកមកអនុវត្តក្នុងគម្រោងសម្បទានដីសេដ្ឋកិច្ចរួមមាន ដំណាំកៅស៊ូ ដូងប្រេង ចេកអំបូងលឿង ដំឡូងមី ស្វាយចន្ទី ប្រេងខ្យល់ ម៉ៃសាក់ ស្រល់ អាកាស្យា អំពៅ និងចិញ្ចឹមសត្វ។ ក្រៅពីដំណាំចម្បងទាំងនេះ គម្រោងសម្បទានដីសេដ្ឋកិច្ចក៏មានដាំបញ្ចូលផងដែរនូវដំណាំសាកវប្បកម្ម និងដំណាំគួបផ្សំ ដែលសមស្របលក្ខណៈជីវសាស្ត្រសណ្ឋានដី តាមតម្រូវការប្រើប្រាស់ និងទីផ្សារព្រមទាំងមានតម្លៃសេដ្ឋកិច្ច
- បានឈូសឆាយលើផ្ទៃដីទំហំ ៥៣៥ ៥៨២ហិកតា និងដាំដុះលើផ្ទៃដីទំហំ ៣៨១ ១៦២ហិកតា
- ការប្រើប្រាស់កម្លាំងពលកម្មសរុបចំនួន ៤៧ ៦១៨នាក់ (ក្នុងនោះ បុគ្គលិកជនជាតិខ្មែរមានចំនួន ៥ ៩៨១នាក់ បុគ្គលិកបរទេសមានចំនួន ១ ៨៣៩នាក់ កម្មករអចិន្ត្រៃយ៍មានចំនួន ៣០ ១១០នាក់ និងកម្មករអណ្តែតមានចំនួន ៩ ៦៨៨នាក់)
- ការប្រមូលចំណូលថ្លៃសម្បទានដីសេដ្ឋកិច្ចមានចំនួន ៣ ១៣៩ ០៤៣,២៤ដុល្លារអាម៉េរិក ក្នុងនោះ ថ្លៃសម្បទានដីសេដ្ឋកិច្ចប្រចាំឆ្នាំ២០២៥ មានចំនួន ២ ៥៧២ ៧២០,៣៦ដុល្លារអាម៉េរិក និងបំណុលឆ្នាំចាស់មានចំនួន ៥២៦ ២៣២,៣៩ដុល្លារអាម៉េរិក និងចំណូលពីការពិន័យ២% មានចំនួន ៤០ ០៩០,៤៩ដុល្លារអាម៉េរិក។

### ៥.៦.១២ ការងារគម្រោងដៃគូអភិវឌ្ឍន៍

ក្រសួងបាននិងកំពុងអនុវត្តគម្រោងអភិវឌ្ឍន៍សរុបចំនួន ៣៦គម្រោង ដែលមានការគាំទ្រពីដៃគូអភិវឌ្ឍន៍រួមមាន៖ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB), ធនាគារពិភពលោក (WB), ទីភ្នាក់ងារបារាំងសំរាប់អភិវឌ្ឍន៍ (AFD), អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO), មូលនិធិអាកាសធាតុបៃតង (GCF), មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (IFAD), សហគមន៍អឺរ៉ុប (EU), ធនាគារវិនិយោគអឺរ៉ុប (EIB), រាជរដ្ឋាភិបាលកម្ពុជា (RGC), ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន (JICA), អង្គការសហប្រតិបត្តិការត្រីកោណត្បូង-ត្បូង (SSTC), មូលនិធិបរិស្ថានសាកល (GEF), អង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី (AfoCo), មូលនិធិកិច្ចសហប្រតិបត្តិការមេគង្គ-សាធារណរដ្ឋកូរ៉េ (MKCF), គំនិតផ្តួចផ្តើមសហប្រតិបត្តិការស្បៀង និងកសិកម្មអាស៊ី (AFACI), ទីភ្នាក់ងារថាមពលបរិមាណូអន្តរជាតិ (IAEA), ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB), Australian Centre for International Agricultural Research, Japan Fund for Prosperous and Resilient Asia and the Pacific, ASEAN Infrastructure Fund, Climate change Fund, ASEAN Infrastucture Fund, Asian Development Fund, APFNet & Yunnan Academy of Forestry and Grassland China, Cambodia Conservation Agriculture and Sustainable Intensification Consortium, AMCK, KFS, និង ACIAR/Australia គិតជាទឹកប្រាក់សរុបចំនួនប្រមាណ ១ ១១៨លានដុល្លារអាម៉េរិក ដែលក្នុងនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានគ្រប់គ្រងនិង

ដឹកនាំអនុវត្តគម្រោងផ្ទាល់គិតជាថវិកាប្រមាណ ៤១៤លានដុល្លារអាមេរិក។ គម្រោងទាំងនេះ ផ្តោតសំខាន់ទៅលើសកម្មភាពមានដូចជា ១).ការកែលម្អគោលនយោបាយរបស់វិស័យកសិកម្ម ២).ការអភិវឌ្ឍបច្ចេកទេសអនុវត្តបង្ហាញបច្ចេកទេស និងការជំរុញផលិតកម្មកសិកម្មប្រកបដោយគុណភាព និងសុវត្ថិភាព ៣).ការចងក្រងពង្រឹងសមត្ថភាព និងការគាំទ្រជាឥណទាន/ប្រាក់កម្ចី និងជំនួយឥតសំណងក្នុងការអនុវត្តផែនការអាជីវកម្មរបស់សហគមន៍កសិកម្ម (AC) និងសហគមន៍កសិកម្មទំនើប (MAC) ៤).ការផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីៗ ធន់នឹងការប្រែប្រួលអាកាសធាតុ ៥).ការជំរុញការប្រើប្រាស់វត្ថុធាតុដើម និងថាមពលកកើតឡើងវិញ ៦).អនុវត្តសកម្មភាពកសិអេកូឡូស៊ីយ៉ាងសកម្ម និងទូលំទូលាយបំផុតក្នុងតំបន់អាស៊ី និង៧).ការគាំទ្រជាហេដ្ឋារចនាសម្ព័ន្ធផលិតកម្ម ប្រព័ន្ធស្រោចស្រពតាមកសិដ្ឋាននិងផ្លូវសហគមន៍ និងការរៀបចំពិធីសារចរចាបើកទីផ្សារសម្រាប់នាំចេញផលិតផលកសិកម្ម ព្រមទាំងភ្ជាប់បណ្តាញទីផ្សាររវាងភាគីផលិត ប្រមូលទិញ កែច្នៃ និងនាំចេញ។

## ៦. បញ្ហាប្រឈម

ទោះបីជាវិស័យកសិកម្មសម្រេចបានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្តី ក៏វិស័យនេះនៅតែជួបប្រទះបញ្ហាប្រឈមមួយចំនួន ជាអាទិ៍ ហេដ្ឋារចនាសម្ព័ន្ធគាំទ្រផលិតកម្ម (ប្រព័ន្ធស្រោចស្រពក្នុងកសិដ្ឋានដោយសន្សំសំចៃទឹក ផ្ទះសំណាញ់ ប្រព័ន្ធស្តុកទុក ឃ្លាំងសម្ងួត ឃ្លាំងត្រជាក់) ការប្រែប្រួលអាកាសធាតុ ជំងឺឆ្លងរាតត្បាត ប្រព័ន្ធផលិតកម្មគ្រាប់ពូជសុទ្ធ និងការប្រើប្រាស់ពូជដំណាំដែលមានគុណភាពល្អនៅមិនទាន់បានទូលំទូលាយ ទំហំផលិតផលសមត្ថភាពក្នុងកែច្នៃនៅមានកម្រិត និងការប្រកួតប្រជែងទីផ្សារក៏ដូចជាស្វែងរកទីផ្សារក្នុងស្រុក និងបរទេស នៅតែជាប្រធានបទដែលត្រូវយកចិត្តទុកដាក់ និងបន្តដោះស្រាយ។

ផលិតកម្មសត្វមានថ្លៃដើមផលិតកម្មខ្ពស់ (ថ្លៃចំណីសត្វ ពូជសត្វ ថ្នាំការពារ និងព្យាបាល) និងគុណភាពផលិតផលសត្វមិនទាន់ស្របតាមទីផ្សារតម្រូវ។ ការធ្វើផែនការផលិតកម្មសត្វ ដើម្បីផ្គត់ផ្គង់ក្នុងស្រុក និងនាំចេញនៅមិនទាន់បានល្អប្រសើរនៅឡើយ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តនៅមិនទាន់គ្រប់ជ្រុងជ្រោយដើម្បីសម្រួលពាណិជ្ជកម្មសត្វ និងប្រព័ន្ធគ្រប់គ្រងអនាម័យ និងភូតគាមអនាម័យនៅមានកម្រិត ហើយការនាំចូលសត្វ និងផលិតសត្វខុសច្បាប់នៅតែបន្តកើតមាន។

ការគ្រប់គ្រងធនធានជលផលនៅមានបញ្ហាប្រឈមមួយចំនួន ដូចជា ការទន្ទ្រានដីព្រៃលិចទឹក ព្រៃកោងកាង និងការប្រើឧបករណ៍នេសាទខុសច្បាប់នៅតែមាន។ ដោយឡែកចំពោះការធ្វើវារីវប្បកម្មតម្លៃផលិតមានការចំណាយខ្ពស់ ដែលជាការលំបាកក្នុងការប្រកួតប្រជែងទីផ្សារនិងខ្វះហេដ្ឋារចនាសម្ព័ន្ធខ្សែច្រវាក់ផ្គត់ផ្គង់និងប្រព័ន្ធត្រជាក់សម្រាប់គាំទ្រដល់ការអភិវឌ្ឍខ្សែច្រវាក់តម្លៃ និងការអនុវត្តអនាម័យល្អ។

ការរីកលូតលាស់ផ្នែកសេដ្ឋកិច្ចកសិកម្ម និងកំណើននៃតម្រូវការដីសម្រាប់ធ្វើកសិកម្ម គឺជាហេតុផលចម្បងដែលនាំឱ្យមានការថយចុះនូវផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ។ ទន្ទឹមនេះ គោលនយោបាយលើកទឹកចិត្តដល់វិស័យឯកជនចូលរួមក្នុងការអភិវឌ្ឍ និងវិនិយោគនៅក្នុងអនុវិស័យព្រៃឈើ ដើម្បីឆ្លើយតបបរិបទនាពេលបច្ចុប្បន្ន។

## ៧. ទិសដៅអនុវត្ត

ក្រសួងបានផ្តល់ការណែនាំដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់គិតគូរ និងផ្តោតការចាប់អារម្មណ៍ខ្ពស់ពីការផ្តល់សេវាសាធារណៈក្នុងវិស័យកសិកម្ម ដោយយល់ពីគោលដៅនៃការផ្តល់សេវាល្អជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។ ជាមួយគ្នានេះ ក្រសួងបាននិងកំពុងតម្រង់ទិសការបន្សុំគ្នារវាងគម្រោងដៃគូអភិវឌ្ឍន៍ជាមួយនឹងថវិកាកម្មវិធីឱ្យស្របតាមគោលនយោបាយ ដើម្បីប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានមនុស្ស និងលទ្ធផលសមិទ្ធកម្ម។

ក្នុងឆ្នាំ២០២៦នេះ ក្រសួងបានកំណត់ទិសដៅការងារសម្រាប់អនុវត្តតាមអនុវិស័យនីមួយៗដូចខាងក្រោម៖

## ៧.១ ផែនការជំរុញផលិតកម្មដំណាំស្រូវ ដំណាំសៀវរួមផ្សំ និងដំណាំទ្រទ្រង់សេដ្ឋកិច្ច

ក្រសួងមានគោលដៅសម្រេចឱ្យបាននូវតម្លៃសេដ្ឋកិច្ចផលិតផលដំណាំនៅកសិដ្ឋានចំនួន ១០ ៣៦៤លានដុល្លារអាម៉េរិក ផលិតផលដំណាំកសិកម្មនាំចេញចំនួន ៥ ៤២៦លានដុល្លារអាម៉េរិក និងអភិវឌ្ឍសហគមន៍កសិកម្មទំនើបចំនួន ៥សហគមន៍។ ដើម្បីសម្រេចគោលដៅនេះ ក្រសួងបានកំណត់ផែនការសកម្មភាពដូចខាងក្រោម៖

- បន្តពង្រឹងនិងពង្រីកសហគមន៍កសិកម្មទំនើប ដោយបន្តផ្សព្វផ្សាយនូវទស្សនទានស្តីពីការអភិវឌ្ឍសហគមន៍កសិកម្មទំនើប ការពង្រឹងសមត្ថភាពគ្រប់គ្រង ការរៀបចំផែនការអាជីវកម្ម និងកៀរគរធនធានគាំទ្រទាំងបច្ចេកទេសនិងហិរញ្ញប្បទាន
- បន្តជំរុញនិងផ្តល់ការគាំទ្របច្ចេកទេសផលិតកម្មដំណាំដល់មន្ត្រីកសិកម្មឃុំ/សង្កាត់ សហគមន៍កសិកម្មទំនើប កសិករ និងអ្នកពាក់ព័ន្ធ
- បន្តជំរុញការអភិវឌ្ឍខ្សែច្រវាក់ផលិតកម្មដំណាំដែលមានសក្តានុពលសម្រាប់ការនាំចេញ ដោយបង្កើនការសិក្សាវាយតម្លៃប្រភេទពូជដំណាំ និងការអភិវឌ្ឍបច្ចេកទេសដាំដុះ ដើម្បីលើកកម្ពស់ផលិតភាពដំណាំប្រកបដោយផលិតភាពសេដ្ឋកិច្ច
- បន្តលើកកម្ពស់គុណភាព សុវត្ថិភាព និងការសម្រួលពាណិជ្ជកម្មកសិផល ដោយជំរុញការគាំទ្របច្ចេកទេសផលិតកម្មតាមស្តង់ដានិងការផ្តល់វិញ្ញាបនបត្របញ្ជាក់ ការអន្តរាគមកម្ចាត់សមាសភាពចង្រៃ ការពង្រឹងការគ្រប់គ្រង និងអនុវត្តវិធានភូតគាមអនាម័យ និងការវិភាគគុណភាពនិងសុវត្ថិភាពធាតុចូលកសិកម្ម និងកសិផល
- បន្តជំរុញការគ្រប់គ្រងធាតុចូលកសិកម្ម ដោយពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត និងការធ្វើអធិការកិច្ច និងត្រួតពិនិត្យជីកសិកម្ម ថ្នាំកសិកម្ម និងពូជដំណាំ ដែលធ្វើពាណិជ្ជកម្មនៅកម្ពុជា
- បន្តជំរុញការគ្រប់គ្រងធនធានដីកសិកម្មប្រកបដោយចីរភាព ដោយសិក្សាវាយតម្លៃកំណត់គុណភាពដីជាតិដី ការធ្វើផែនទីកំណត់តំបន់ដាំដុះដំណាំសំខាន់ៗ និងការជំរុញអនុវត្តកសិកម្មអភិរក្ស ដើម្បីថែរក្សាសុខភាពដី និងការរៀបចំម៉ាកសម្គាល់កសិផលកម្ពុជាដែលមានគុណភាព និងឧត្តមភាពប្រកួតប្រជែងលើទីផ្សារអន្តរជាតិ។

## ៧.២ ផែនការបង្កើនផលិតកម្មដំណាំកៅស៊ូ

ក្រសួងមានគោលដៅសម្រេចឱ្យបានកំណើនផ្ទៃដីចៀរជ័រក្នុងរង្វង់ ១% (ក្នុងរង្វង់ ៣៥០ពាន់ហិកតា) ទិន្នផលកៅស៊ូក្នុងរង្វង់ ២% (ក្នុងរង្វង់ ១ ២៥២គីឡូក្រាម/ហិកតា) ផលិតផលកៅស៊ូក្នុងរង្វង់ ៣% (ក្នុងរង្វង់ ៤៣៨ពាន់តោន) ការប្រើប្រាស់ជ័រកៅស៊ូក្នុងស្រុកក្នុងរង្វង់៨% (ក្នុងរង្វង់ ១៣៤ពាន់តោន) និងតម្លៃសេដ្ឋកិច្ចនៃផលិតផលកៅស៊ូចំនួន ៨៦៣,៣លានដុល្លារអាម៉េរិក។

ដើម្បីសម្រេចគោលដៅនេះ ក្រសួងបានកំណត់ផែនការសកម្មភាពដូចខាងក្រោម៖

- ជំរុញការអភិវឌ្ឍសហគមន៍កសិកម្មកៅស៊ូគ្រួសារ ឱ្យក្លាយទៅជាសហគមន៍កសិកម្មកៅស៊ូគ្រួសារទំនើប
- បន្តសម្របសម្រួលឱ្យមានវេទិកាជំនួបរវាងអ្នកផលិត និងអ្នកប្រើប្រាស់ផលិតផលកៅស៊ូធម្មជាតិ និងពង្រឹងគុណភាពជ័រកៅស៊ូ ឱ្យឆ្លើយតបនឹងតម្រូវការផលិតសំបកកង់យានយន្ត
- ជំរុញនិងកែលម្អគុណភាពផលិតផលកៅស៊ូ តម្រូវតាមទីផ្សារ និងការប្រើប្រាស់កៅស៊ូក្នុងស្រុក
- ចុះពិនិត្យ និងផ្តល់ប្រឹក្សានៅចម្ការកៅស៊ូផ្ទាល់ ជាមួយកសិករកៅស៊ូគ្រួសារ
- ជំរុញការប្រើប្រាស់ក្លូនកៅស៊ូដែលមានសក្តានុពល
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយ ដៃគូអភិវឌ្ឍន៍ ទីភ្នាក់ងារ និងអង្គការជាតិនិងអន្តរជាតិនានា ដើម្បីគាំទ្រការអភិវឌ្ឍឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជា។

### ៧.៣ ផែនការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ

ក្រសួងមានគោលដៅសម្រេចឱ្យបាននូវតម្លៃសេដ្ឋកិច្ចនៃសត្វ និងផលិតផលសត្វក្នុងឆ្នាំ២០២៦ ចំនួន ១ ៧៩១ លានដុល្លារអាម៉េរិក និងកាត់បន្ថយអត្រាជំងឺឆ្លងសត្វឱ្យនៅក្រោម ៥%។

ដើម្បីសម្រេចគោលដៅនេះ ក្រសួងបានកំណត់ផែនការសកម្មភាពដូចខាងក្រោម៖

- បន្តផ្តល់សេវាបសុព្យាបាល និងបង្កើនសមត្ថភាពបច្ចេកទេសដល់កសិករចិញ្ចឹមសត្វ ជាពិសេសជំរុញការផ្លាស់ប្តូរពីការចិញ្ចឹមជាលក្ខណៈគ្រួសារទៅជាការចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្ម
- បន្តពង្រឹងការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ ពង្រឹងអនុវត្តច្បាប់ ពង្រឹងសមត្ថភាពមន្រ្តី និងបណ្តុះបណ្តាលពីបច្ចេកទេសពិឃាតសត្វប្រកបដោយមនុស្សធម៌ដល់ម្ចាស់សត្តឃាតដ្ឋាន និងអាជីវករពិឃាតសត្វ
- ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំនានា ពង្រឹងសមត្ថភាពមន្ត្រីនិងផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ បង្កើនការត្រួតពិនិត្យនិងធ្វើអធិការកិច្ចលើអាជីវកម្មនាំចូល នាំចេញ និងនាំឆ្លងកាត់សត្វនិងផលិតផលសត្វ សត្តឃាតដ្ឋាន កសិដ្ឋានចិញ្ចឹមសត្វនិងបង្កាត់ពូជសត្វ កន្លែងផលិតលាយផ្សំ ឬវេចខ្ចប់ជាថ្មី កន្លែងផ្គត់ផ្គង់ចែកចាយ ឃ្លាំងសន្និធិចំណីសត្វ វត្ថុធាតុដើម សារធាតុបន្ថែម បសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម សមាសធាតុគ្រប់ប្រភេទ
- បង្កើនសមត្ថភាពមន្ត្រីគ្រប់កម្រិត ដើម្បីផ្ទេរចំណេះដឹងលើជំនាញសុខភាពសត្វ និងផលិតកម្មសត្វដូចជាការចិញ្ចឹម ការបង្កាត់ពូជសត្វ សុវត្ថិភាពចំណីអាហារ បសុឱសថ ជីវសុវត្ថិភាព ការបង្ការជំងឺឆ្លងរាលដាលសត្វ ខ្សែច្រវាក់ផលិតកម្មសត្វ ការធ្វើពាណិជ្ជកម្មសត្វដល់វិស័យឯកជន អង្គការដៃគូអភិវឌ្ឍន៍ សហគមន៍ សមាគម កសិករចិញ្ចឹមសត្វ ដើម្បីបង្កើនផលិតភាពសត្វ
- បន្តពង្រឹងការសិក្សាស្រាវជ្រាវ ការអង្កេតតាមដានជំងឺឆ្លងសត្វ សំដៅរកឱ្យឃើញប្រភពជំងឺ និងឆ្លើយតបទាន់ពេលវេលា ព្រមទាំងពង្រឹងការស្រាវជ្រាវចំណីសត្វ បសុឱសថ ពូជសត្វដែលមានលក្ខណៈបន្សាំនឹងការប្រែប្រួលអាកាសធាតុ ធន់នឹងជំងឺ លូតលាស់លឿន និងស្របនឹងតម្រូវការទីផ្សារ និងការបង្កាត់ពូជសិប្បនិម្មិត រួមជាមួយនឹងការបង្កើនសមត្ថភាពមន្ទីរពិសោធន៍
- ចែករំលែកព័ត៌មាន ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការទាំងកម្រិតថ្នាក់ជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន អង្គការជាតិ អង្គការអន្តរជាតិនានាពាក់ព័ន្ធអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ
- ជំរុញលើកទឹកចិត្តសហគមន៍ចិញ្ចឹមសត្វ កសិករចិញ្ចឹមសត្វតាមកិច្ចសន្យា ដើម្បីលើកកម្ពស់ផលិតកម្មសត្វធានាបាននូវបរិមាណផ្គត់ផ្គង់
- លើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន
- លើកទឹកចិត្ត គាំទ្រ និងជួយសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធ ប្រទេសបញ្ជាទិញ ដើម្បីអន្តរាគមន៍បានចូលទីផ្សារក្នុងការប្រកួតប្រជែងផលិតផលដែលផលិតបាន

### ៧.៤ ផែនការពង្រឹងការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម

ក្រសួងមានគោលដៅសម្រេចឱ្យបានផលនេសាទទឹកសាបចំនួន ៤៧០ ០០០តោន ផលនេសាទសមុទ្រចំនួន ១៣០ ០០០តោន ផលវារីវប្បកម្មចំនួន ៣៤០ ០០០តោន កូនត្រីពូជចំនួន ២៩០លានកូន ក្រពើចំនួន ៣០០ ០០០ក្បាល ការកែច្នៃផល ផលិតផលជលផលចំនួន ៥៥ ០០០តោន ទឹកត្រីចំនួន ៥៨ ០០០តោន និងការនាំចេញផលផលិតផលជលផលចំនួន ៨ ០០០តោន។ ដើម្បីសម្រេចគោលដៅនេះ ក្រសួងបានកំណត់ផែនការសកម្មភាពដូចខាងក្រោម៖

- បន្តការអនុវត្តច្បាប់ដោយម៉ឺងម៉ាត់ ដោយសហការទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលគ្រប់ប្រភេទ
- បន្តការការពារកន្លែងអភិរក្សជលផល និងប្រភេទត្រីកំពុងរងគ្រោះថ្នាក់ក្នុងដែនទឹកធម្មជាតិ
- បន្តលែងកូនត្រី និងពូជត្រីប្រភេទផ្សេងៗទៀតចូលតំបន់ទឹកធម្មជាតិ
- ជំរុញការអភិវឌ្ឍវារីវប្បកម្មតាមគ្រប់រូបភាព ដោយសិក្សាពីតម្រូវការទីផ្សារ និងធ្វើផែនការផលិតកម្មច្បាស់លាស់ ព្រមទាំងលើកទឹកចិត្តផ្ដល់បច្ចេកទេសក្នុងការអនុវត្តវារីវប្បកម្មល្អ
- ពង្រឹងការគ្រប់គ្រងវារីជាតិ ការធ្វើនេសាទ ការធ្វើអាជីវកម្មផល ផលិតផលជលផល និងការការពារព្រៃលិចទឹក និងព្រៃកោងកាងឱ្យមានប្រសិទ្ធភាព
- ជំរុញការអភិវឌ្ឍខ្សែច្រវាក់តម្លៃជលផល និងពង្រឹងការត្រួតពិនិត្យគុណភាព សុវត្ថិភាពផល ផលិតផលជលផល
- បន្តសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍអនុវិស័យជលផល
- បន្តពង្រឹងការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព។

## ៧.៥ ផែនការពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃ

សម្រាប់អនុវិស័យនេះ ក្រសួងមានគោលដៅសម្រេចឱ្យបានការថែរក្សានិងព្យាបាលសត្វព្រៃចំនួន ៣ ០០០ក្បាល និងកំណត់ព្រំប្រទល់ដីព្រៃឈើ ដើម្បីចុះបញ្ជីនិងគ្រប់គ្រង (ដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ សម្បទានដីសេដ្ឋកិច្ច សហគមន៍ព្រៃឈើ ព្រៃបម្រុងទុកអចិន្ត្រៃយ៍។ល។) ចំនួន ២០ ០០០ហ.ត។

ដើម្បីសម្រេចគោលដៅនេះ ក្រសួងបានកំណត់ផែនការសកម្មភាពដូចខាងក្រោម៖

- ជំរុញ និងពង្រឹងការរៀបចំថវិកាសមិទ្ធកម្ម ឱ្យឆ្លើយតបទៅនឹងសូចនាករគោលដៅ ដោយយកបទពិសោធន៍ការអនុវត្តក្នុងឆ្នាំ២០២៥ ដើម្បីតម្រង់ទិសការអនុវត្តឆ្នាំ២០២៦
- ធ្វើបច្ចុប្បន្នភាពសហគមន៍ព្រៃឈើដោយអនុម័តផែនការគ្រប់គ្រងឲ្យបានចំនួន ៥០សហគមន៍ត្រឹមឆ្នាំ២០២៨
- ជំរុញការចុះបញ្ជីដីរដ្ឋ (ដីស្ថានីយស្រាវជ្រាវព្រៃឈើ ដីចម្ការឈើដាំ ស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើ សហគមន៍ព្រៃឈើ និងដីក្នុងបញ្ជីទ្រព្យរដ្ឋ) ដោយប្រែក្លាយពីទ្រព្យអសកម្ម ឱ្យទៅជាទ្រព្យសកម្ម
- ត្រួតពិនិត្យតាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្ម កែច្នៃ និងអាជីវកម្មឈើឱ្យកាន់តែមានប្រសិទ្ធភាព
- ជំរុញការគ្រប់គ្រង និងផ្សព្វផ្សាយព្រៃលំហែកម្សាន្ត និងឧទ្យានសួនសត្វ ព្រៃការពារ និងសួនរុក្ខជាតិ "ភ្នំតាម៉ៅ" ឱ្យក្លាយជាតំបន់ទាក់ទាញទេសចរណ៍ធម្មជាតិ ដើម្បីទាក់ទាញភ្ញៀវជាតិ
- ជំរុញការបណ្តុះកូនឈើទាំងឈើប្រណិត និងឈើក្រៅស្រុកធ្វើយ៉ាងណាឱ្យការផ្គត់ផ្គង់កូនឈើមានជាប្រចាំ
- រៀបចំនីតិវិធីដើម្បីជំរុញការចិញ្ចឹមសត្វព្រៃ ការធ្វើពាណិជ្ជកម្ម និងការប្រមាញ់សត្វព្រៃ
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការ និងដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ និងបណ្ដាប្រទេសផ្តល់ជំនួយ វិស័យឯកជននានា។

## ៧.៦ ផែនការពង្រឹងការគ្រប់គ្រងស្ថាប័ន និងអភិវឌ្ឍន៍ធនធានមនុស្ស

ក្រសួងមានគោលដៅសម្រេចឱ្យបានអនុបាតនៃការអនុវត្តថវិកាកម្មវិធី ៩៥% និងចំនួននិស្សិតដែលបានបញ្ចប់ការសិក្សាចំនួន ១ ០៨០នាក់ ព្រមទាំងអនុវត្តសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៧-២០២៩ ផែនការថវិកាកម្មវិធីឆ្នាំ២០២៧ ផែនការវិនិយោគសាធារណៈបីឆ្នាំរំកិលឆ្នាំ២០២៧-២០២៩ និងកិច្ចព្រមព្រៀងសមិទ្ធកម្មទាំងបីកម្រិតឆ្នាំ២០២៧

- បន្តតាមដាន និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ និងគោលនយោបាយ ថវិកាកម្មវិធីឆ្នាំ២០២៦ ពង្រឹងប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច
- បន្តពង្រឹងប្រព័ន្ធស្ថិតិ ព័ត៌មានទីផ្សារកសិកម្ម ប្រព័ន្ធព័ត៌មានវិទ្យា និងផ្សព្វផ្សាយកសិកម្ម
- ពង្រឹងការប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- បន្តអនុវត្តគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្សរបស់ក្រសួង និងពង្រឹងការគ្រប់គ្រងមន្ត្រីរាជការ
- បន្តអនុវត្តផែនការបណ្តុះបណ្តាលនិស្សិតរបស់គ្រឹះស្ថានអប់រំកសិកម្មទាំងបី
- បន្តពង្រឹងសមត្ថភាពមន្ត្រីកសិកម្មឃុំ-សង្កាត់ទូទាំងប្រទេស
- បន្តរៀបចំ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្ត ឱ្យស្របតាមស្ថានភាពនៃការវិវឌ្ឍរបស់វិស័យកសិកម្ម
- បន្តរៀបចំសេចក្តីព្រាងសេចក្តីណែនាំអនុវត្តមុខងារក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលផ្ទេរទៅឱ្យរដ្ឋបាលក្រុងស្រុក ខណ្ឌ
- បន្តចុះគាំទ្របច្ចេកទេស និងត្រួតពិនិត្យការអនុវត្តមុខងារក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ នៅតាមខេត្តគោលដៅ។

## ៨. សេចក្តីសន្និដ្ឋាន

ផ្អែកលើសមិទ្ធផលដែលសម្រេចបានក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ វិស័យកសិកម្មនៅតែរក្សាបាននូវកំណើនវិជ្ជមានក្នុងរង្វង់១,០៨%។ ក្នុងឆ្នាំ២០២៥ កំណើននៃតម្លៃបន្ថែមសរុបឡើងដល់ ៣៣ ១៤៩ពាន់លានរៀល ឬស្មើនឹង ៥,៩៣% ធៀបនឹងឆ្នាំមុន ទោះបីជាវិស័យនេះបានទទួលរងផលប៉ះពាល់ពីគ្រោះធម្មជាតិក៏ដោយ។

ផលិតផលដំណាំ ជាពិសេសដំណាំស្រូវ ដំណាំរួមផ្សំ និងទ្រទ្រង់សេដ្ឋកិច្ច ធានាបានការផ្គត់ផ្គង់ស្បៀងអាហារក្នុងស្រុក តម្រូវការកែច្នៃ និងសល់សម្រាប់នាំចេញ។ ជាចំណុចគួរឱ្យកត់សម្គាល់មួយទៀត ប្រជាកសិករយើងបានខិតខំផលិតដំណាំកសិកម្មសល់ពីការប្រើប្រាស់ក្នុងស្រុកនិងបាននាំចេញជាផ្លូវការសរុបប្រមាណជាង ១៥លានតោន ដោយមានការជួយគាំទ្រទាំងការងារបច្ចេកទេស និងការស្វែងរកទីផ្សារពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងស្ថាប័នពាក់ព័ន្ធ។ ទន្ទឹមនឹងនេះ ក្រសួងបានជួយអន្តរាគមន៍តម្លៃស្រូវជូនប្រជាកសិករមានតម្លៃសមរម្យនិងមិនទុកឲ្យស្រូវខូចខាត ព្រមទាំងបន្តជួយស្វែងរកទីផ្សារថ្មីៗទៀតសម្រាប់ជំរុញការនាំចេញនិងបង្កើនប្រសិទ្ធភាពសេដ្ឋកិច្ចជាតិ។

ចំពោះផលិតកម្មសត្វធានាបាននូវការផ្គត់ផ្គង់រហូតដល់ ៩៨% នៃតម្រូវការសាច់សត្វក្នុងស្រុក។ ជាមួយគ្នានេះ ការវិនិយោគឯកជនលើកសិដ្ឋានចិញ្ចឹមសត្វ រោងចក្រផលិតចំណីសត្វ និងសត្តឃាតដ្ឋានទំនើប បានចូលរួមបង្កើនផលិតកម្មសត្វ និងលើកកម្ពស់អនាម័យ និងសុវត្ថិភាពដល់អ្នកបរិភោគ។ ការអនុវត្តវិធានការច្បាប់ និងវិធានការបច្ចេកទេសចិញ្ចឹមសមស្រប ជាពិសេសការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ត្រូវបានលើកកម្ពស់ជាបន្តបន្ទាប់។

ការគ្រប់គ្រងធនធានជលផលទទួលបានលទ្ធផលជាវិជ្ជមាន ដោយផលនេសាទទឹកសាប មានការកើនឡើងប្រមាណ១០%។ ការអនុវត្តវារីវប្បកម្មកំពុងត្រូវបានជំរុញបន្ថែម ដោយមានកិច្ចសហការពីដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនដើម្បីបង្កើនផលវារីវប្បកម្ម និងការលើកស្ទួយផលិតកម្មកសិកម្ម រក្សាបាននូវស្ថិរភាពថ្លៃផល ផលិតផលជលផល ដោយថ្លឹងថ្លែងរវាងការផ្គត់ផ្គង់និងតម្រូវការនៃការនាំចូល។ ទន្ទឹមនេះ ក្រសួងបានបន្តការបង្វែរមុខរបរប្រជានេសាទឱ្យចាប់យកមុខរបរផ្សេង ដើម្បីកាត់បន្ថយសម្ពាធលើធនធានជលផលធម្មជាតិ ការអភិរក្សធនធានជលផល និងការពង្រឹងការទប់ស្កាត់និងការបង្ក្រាបបទល្មើសនេសាទឱ្យមានប្រសិទ្ធភាពខ្ពស់តាមរយៈកិច្ចសហការល្អរវាងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ព្រមទាំងការចូលរួមពីសហគមន៍នេសាទផងដែរ។

ការខិតខំប្រឹងប្រែងបំពេញភារកិច្ចខ្លាំងក្លាពីសំណាក់ថ្នាក់ដឹកនាំ មន្ត្រីរដ្ឋបាលព្រៃឈើគ្រប់ជាន់ថ្នាក់ និងកិច្ចសហការយ៉ាងល្អ រឹងមាំជាមួយគ្រប់សមត្ថកិច្ចពាក់ព័ន្ធ ស្ថាប័នតុលាការ បានទប់ស្កាត់ បង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងការកាប់រានដីព្រៃឈើ ព្រមទាំងការកំណត់ព្រំប្រទល់ដីព្រៃឈើ។ ក្រសួងបាននិងកំពុងជំរុញបណ្តុះកូនឈើនិងដាំឈើជាចម្ការថ្មីដោយមានការចូលរួមពីវិស័យឯកជន និងមានទិសដៅសម្រួលការនាំចូលផលិតផលឈើ ដើម្បីកាត់បន្ថយសម្ពាធនៃតម្រូវការឈើប្រើប្រាស់មកលើធនធានព្រៃឈើ។

ក្រសួងបាននិងកំពុងចូលរួមយ៉ាងសកម្មជាមួយនឹងការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ប្រកបដោយភាពប្រាកដនិយម និងជវភាពនៃប្រព័ន្ធតួអង្គតែមួយ តាមរយៈការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធ ដើម្បីផ្តល់ការគាំទ្រឱ្យកាន់តែរឹងមាំថែមទៀតដល់ការបំពេញបេសកកម្ម និងតួនាទីភារកិច្ចរបស់ក្រសួងប្រកបដោយប្រសិទ្ធភាពខ្ពស់។ លើសពីនេះទៀត សេវាគាំទ្រផ្សេងៗ រួមទាំងមន្ត្រីកសិកម្មឃុំ-សង្កាត់ ក៏បានសម្រេចលទ្ធផលការងារតាមផ្នែកនីមួយៗល្អប្រសើរ ស្របតាមគោលការណ៍ និងទិសដៅរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះ អង្គភាពជំនាញនីមួយៗដែលជាសេនាធិការរបស់ក្រសួងនឹងបន្តអនុវត្តតាមទិសដៅគោលនយោបាយ និងផែនការយុទ្ធសាស្ត្រដែលបានដាក់ចេញសម្រាប់ឆ្នាំ២០២៥ ដោយស្មារតីទទួលខុសត្រូវខ្ពស់។

សរុបសេចក្តីមក វិស័យកសិកម្មបានរួមចំណែកយ៉ាងសកម្មក្នុងការធានាសន្តិសុខស្បៀង ការបង្កើតការងារ បង្កើនប្រាក់ចំណូលប្រជាកសិករ និងការចូលរួមទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងបន្តខិតខំប្រឹងប្រែងអនុវត្តការងារដោយបុរេសកម្ម និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ស្របតាមបរិបទនៃការអភិវឌ្ឍសេដ្ឋកិច្ច នយោបាយ និងសង្គមឪជីថល ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្មសំដៅចូលរួមសម្រេចបាននូវយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ជាពិសេសកម្មវិធីគោលនយោបាយអាទិភាពទី៥ និងទី៦ សម្រាប់វិស័យកសិកម្ម ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងម៉ឺងម៉ាត់បំផុតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។**

ថ្ងៃ ចន្ទ ៥កើត ខែ ចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០២៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ឌិត ទីណា**

# ឧបសម្ព័ន្ធ

# ស្ថិតិផ្ទៃដីភ្ជួររាស់ និងផ្ទៃដីដាំដុះដំណាំស្រូវរដូវវស្សាឆ្នាំ ២០២៥

ឧបសម្ព័ន្ធទី ១

| ល.រ | រាជធានី-ខេត្ត | ព្យាករ (ហត) | ផ្ទៃដីភ្ជួររាស់ (ហ.ត) | | | | | ផ្ទៃដីសាប (ហត) | ផ្ទៃដីព្រោះស្ទូង និងបុកដាំ (ហត) | | | | | | | សរុបស្ទូងនិងព្រោះបុកដាំ (ហត) | ភាគរយ (%) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប | គោ-ក្របី | | គ្រឿងយន្ត | | | ស្រូវស្រាល | | កណ្ដាល | | ធ្ងន់ | ចំការ | ឡើងទឹក | | |
| | | | | ហ.ត | % | ហ.ត | % | | សរុប | បង្កើនរដូវ | សរុប | បង្កើនរដូវ | | | | | |
| 01 | បន្ទាយមានជ័យ | 271,485 | 289,686 | - | - | 289,686 | 100.00 | 2 | 112,595 | - | 121,356 | - | 39,334 | - | 16,198 | 289,483 | 106.63 |
| 02 | បាត់ដំបង | 450,000 | 484,999 | - | - | 484,999 | 100.00 | - | 340,796 | 116,625 | 103,422 | - | 38,960 | 155 | 1,666 | 484,999 | 107.78 |
| 03 | កំពង់ចាម | 105,800 | 116,769 | 4,680 | 4.01 | 112,089 | 95.99 | 37 | 70,773 | 13,301 | 24,736 | - | 20,210 | - | 1,050 | 116,769 | 110.37 |
| 04 | កំពង់ឆ្នាំង | 145,000 | 145,266 | - | - | 145,266 | 100.00 | 37 | 38,534 | 10,530 | 57,087 | - | 49,645 | - | - | 145,266 | 100.18 |
| 05 | កំពង់ស្ពឺ | 119,038 | 120,527 | 245 | 0.20 | 120,282 | 99.80 | 895 | 17,418 | 1,916 | 56,372 | - | 46,737 | - | - | 120,527 | 101.25 |
| 06 | កំពង់ធំ | 220,000 | 239,552 | - | - | 239,552 | 100.00 | 362 | 86,814 | 56,445 | 110,757 | - | 39,791 | 298 | 1,874 | 239,534 | 108.88 |
| 07 | កំពត | 128,393 | 130,696 | - | - | 130,696 | 100.00 | - | 14,230 | - | 74,121 | 14,185 | 42,345 | - | - | 130,696 | 101.79 |
| 08 | កណ្ដាល | 32,500 | 40,599 | - | - | 40,599 | 100.00 | 7 | 32,316 | 2,310 | 6,629 | - | 1,654 | - | - | 40,599 | 124.92 |
| 09 | កោះកុង | 10,220 | 9,636 | - | - | 9,636 | 100.00 | 166 | - | - | 9,308 | - | 328 | 584 | - | 10,220 | 100.00 |
| 10 | ក្រចេះ | 61,570 | 61,704 | - | - | 61,704 | 100.00 | - | 19,339 | 3,697 | 40,224 | - | 2,103 | 35 | - | 61,701 | 100.21 |
| 11 | មណ្ឌលគិរី | 30,500 | 33,144 | - | - | 33,144 | 100.00 | 1,045 | 15,959 | - | 14,945 | - | 1,195 | 1,014 | - | 33,113 | 108.57 |
| 12 | ភ្នំពេញ | 4,200 | 4,320 | - | - | 4,320 | 100.00 | 21 | 3,410 | - | 506 | - | 404 | - | - | 4,320 | 102.86 |
| 13 | ព្រះវិហារ | 105,648 | 105,830 | - | - | 105,830 | 100.00 | 185 | 9,301 | - | 61,782 | - | 33,023 | 1,912 | - | 106,018 | 100.35 |
| 14 | ព្រៃវែង | 300,000 | 309,478 | - | - | 309,478 | 100.00 | - | 166,842 | 48,539 | 125,623 | - | 17,013 | - | - | 309,478 | 103.16 |
| 15 | ពោធិសាត់ | 136,000 | 167,047 | - | - | 167,047 | 100.00 | - | 119,123 | 18,630 | 36,442 | - | 10,387 | 1,095 | - | 167,047 | 122.83 |
| 16 | រតនគិរី | 37,500 | 26,038 | - | - | 26,038 | 100.00 | 424 | 5,229 | - | 16,997 | - | 3,812 | 12,236 | - | 38,274 | 102.06 |
| 17 | សៀមរាប | 189,830 | 194,230 | - | - | 194,230 | 100.00 | 0 | 39,520 | 300 | 115,685 | | 33,979 | 435 | 1,765 | 191,384 | 100.82 |
| 18 | ព្រះសីហនុ | 13,300 | 11,771 | - | - | 11,771 | 100.00 | - | - | - | 5,141 | - | 6,630 | - | - | 11,771 | 88.50 |
| 19 | ស្ទឹងត្រែង | 28,170 | 28,930 | - | - | 28,930 | 100.00 | 510 | 3,316 | - | 25,287 | - | 70 | 230 | - | 28,903 | 102.60 |
| 20 | ស្វាយរៀង | 167,500 | 175,935 | - | - | 175,935 | 100.00 | - | 47,383 | 8,887 | 126,124 | - | 1,275 | - | - | 174,782 | 104.35 |
| 21 | តាកែវ | 210,000 | 238,081 | - | - | 238,081 | 100.00 | - | 110,648 | 77,450 | 122,367 | - | 5,066 | - | - | 238,081 | 113.37 |
| 22 | ឧត្តរមានជ័យ | 138,713 | 143,812 | - | - | 143,812 | 100.00 | 0 | 10,553 | - | 123,528 | - | 9,693 | - | - | 143,774 | 103.65 |
| 23 | កែប | 3,520 | 3,618 | - | - | 3,618 | 100.00 | - | 1,245 | 571 | 1,097 | - | 1,276 | - | - | 3,618 | 102.78 |
| 24 | ប៉ៃលិន | 7,500 | 8,184 | - | - | 8,184 | 100.00 | - | 5,139 | - | 2,455 | - | | 590 | - | 8,184 | 109.12 |
| 25 | ត្បូងឃ្មុំ | 78,170 | 77,770 | - | - | 77,770 | 100.00 | 75 | 17,340 | 5,650 | 26,460 | - | 33,970 | - | - | 77,770 | 99.49 |
| សរុប | | **2,994,557** | **3,167,622** | **4,925** | **0.16** | **3,162,697** | **99.84** | **3,766** | **1,287,823** | **364,851** | **1,408,451** | **14,185** | **438,900** | **18,584** | **22,553** | **3,176,311** | **106.07%** |
| តួលេខឆ្នាំមុន | | **2,670,000** | **3,010,296** | **2,433** | **0.08** | **3,007,863** | **99.92** | **5,257** | **1,212,537** | **234,760** | **1,326,753** | **12,431** | **430,733** | **19,101** | **27,014** | **3,016,138** | **112.96%** |
| ប្រៀបធៀប | | **324,557** | **157,326** | **2,492** | **0.07** | **154,834** | **-0.07** | **-1,491** | **75,286** | **130,091** | **81,698** | **1,754** | **8,167** | **-517** | **-4,461** | **160,173** | **5.31%** |

# ផ្ទៃដីប៉ះពាល់ និងខូចខាតលើដំណាំស្រូវរដូវវស្សាឆ្នាំ ២០២៥

ឧបសម្ព័ន្ធទី ២

| ល.រ | រាជធានី-ខេត្ត | បញ្ចប់ផ្ទៃដីអនុវត្តបាន | ប៉ះពាល់និងខូចខាតដោយប្រការផ្សេងៗ | | | | | | | | ផ្ទៃដីស្តារឡើងវិញ (ហ.ត) | ខូចខាតទាំងស្រុង (ហ.ត) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ប៉ះពាល់ (ហ.ត) | | | | ខូចខាត (ហ.ត) | | | | | |
| | | | រាំងស្ងួត | សត្វបំផ្លាញ | ទឹកជំនន់ | សរុប | រាំងស្ងួត | សត្វល្អិត | ទឹកជំនន់ | សរុប | | |
| 01 | បន្ទាយមានជ័យ | 289,483 | | | 8,196 | **8,196** | | | 3,432 | **3,432** | 152 | 3,280 |
| 02 | បាត់ដំបង | 484,999 | | | 14,953 | **14,953** | | | 7,010 | **7,010** | | 7,010 |
| 03 | កំពង់ចាម | 116,769 | | | 8,956 | **8,956** | | | 5,268 | **5,268** | 5,097 | 171 |
| 04 | កំពង់ឆ្នាំង | 145,266 | | | 1,496 | **1,496** | | | 1,252 | **1,252** | | 1,252 |
| 05 | កំពង់ស្ពឺ | 120,527 | | | | **-** | | | | **-** | | - |
| 06 | កំពង់ធំ | 239,534 | | | 7,383 | **7,383** | | | 3,693 | **3,693** | | 3,693 |
| 07 | កំពត | 130,696 | | | | **-** | | | | **-** | | - |
| 08 | កណ្តាល | 40,599 | 1,221 | - | 1,978 | **3,199** | | | 1,303 | **1,303** | | 1,303 |
| 09 | កោះកុង | 10,220 | | 108 | | **108** | | | | **-** | | - |
| 10 | ក្រចេះ | 61,701 | | | 9,277 | **9,277** | | | 6,972 | **6,972** | 5,823 | 1,149 |
| 11 | មណ្ឌលគិរី | 33,113 | | | 1,180 | **1,180** | | | 349 | **349** | 348 | 1 |
| 12 | ភ្នំពេញ | 4,320 | 294 | | | **294** | | | | **-** | | - |
| 13 | ព្រះវិហារ | 106,018 | | | 1,369 | **1,369** | | | 78 | **78** | | 78 |
| 14 | ព្រៃវែង | 309,478 | | | 9,203 | **9,203** | | | 6,555 | **6,555** | 6,555 | - |
| 15 | ពោធិសាត់ | 167,047 | | | 9,187 | **9,187** | | | 4,896 | **4,896** | 374 | 4,522 |
| 16 | រតនគិរី | 38,274 | | | 3,492 | **3,492** | | | 1,085 | **1,085** | | 1,085 |
| 17 | សៀមរាប | 191,384 | | | 20,445 | **20,445** | | | 5,452 | **5,452** | | 5,452 |
| 18 | ព្រះសីហនុ | 11,771 | | | | **-** | | | | **-** | | - |
| 19 | ស្ទឹងត្រែង | 28,903 | | | 2,628 | **2,628** | | | 408 | **408** | | 408 |
| 20 | ស្វាយរៀង | 174,782 | | 573 | 2,142 | **2,715** | | | | **-** | | - |
| 21 | តាកែវ | 238,081 | 208 | | 5,712 | **5,920** | 208 | - | 2,339 | **2,547** | | 2,547 |
| 22 | ឧត្តរមានជ័យ | 143,774 | | | | **-** | | | | **-** | | - |
| 23 | កែប | 3,618 | | | | **-** | | | | **-** | | - |
| 24 | ប៉ៃលិន | 8,184 | - | | | **-** | | | | **-** | | - |
| 25 | ត្បូងឃ្មុំ | 77,770 | | | 3,127 | **3,127** | | | 2,435 | **2,435** | | 2,435 |
| សរុប | | **3,176,311** | **1,723** | **681** | **110,724** | **113,128** | **208** | **-** | **52,527** | **52,735** | **18,349** | **34,386** |
| តួលេខឆ្នាំមុន | | **3,016,138** | **56,164** | **83,039** | **54,709** | **193,912** | **15,912** | **13,191** | **27,623** | **56,726** | **29,288** | **27,438** |
| ប្រៀបធៀប | | **160,173** | **-54,441** | **-82,358** | **56,015** | **-80,784** | **-15,704** | **-13,191** | **24,904** | **-3,991** | **-10,939** | **6,948** |

# បរិមាណផល និងទិន្នផលដំណាំស្រូវរដូវវស្សាតាមប្រភេទឆ្នាំ ២០២៥

ឧបសម្ព័ន្ធទី ៣ក

| ល.រ | រាជធានី-ខេត្ត | ស្រូវស្រាល | | | | ស្រូវកណ្តាល | | | | ស្រូវធ្ងន់ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផ្ទៃ.ដាំដុះ (ហត) | ផ្ទៃ.ប្រ.ផល (ហត) | ទិន្នផល (ត/ហត) | បរិ.ផល (តោន) | ផ្ទៃ.ដាំដុះ (ហត) | ផ្ទៃ.ប្រ.ផល (ហត) | ទិន្នផល (ត/ហត) | បរិ.ផល (តោន) | ផ្ទៃ.ដាំដុះ (ហត) | ផ្ទៃ.ប្រ.ផល (ហត) | ទិន្នផល (ត/ហត) | បរិ.ផល (តោន) |
| 01 | បន្ទាយមានជ័យ | 112,595 | 111,478 | 4.927 | 549,257 | 121,356 | 120,693 | 2.942 | 355,127 | 39,334 | 37,846 | 2.658 | 100,591 |
| 02 | បាត់ដំបង | 340,796 | 335,126 | 4.253 | 1,425,231 | 103,422 | 103,336 | 2.633 | 272,053 | 38,960 | 37,706 | 2.812 | 106,029 |
| 03 | កំពង់ចាម | 70,773 | 70,728 | 3.905 | 276,177 | 24,736 | 24,610 | 2.915 | 71,739 | 20,210 | 20,210 | 3.023 | 61,101 |
| 04 | កំពង់ឆ្នាំង | 38,534 | 37,282 | 4.453 | 166,019 | 57,087 | 57,087 | 3.436 | 196,157 | 49,645 | 49,645 | 3.661 | 181,756 |
| 05 | កំពង់ស្ពឺ | 17,418 | 17,418 | 3.314 | 57,725 | 56,372 | 56,372 | 3.306 | 186,351 | 46,737 | 46,737 | 3.441 | 160,803 |
| 06 | កំពង់ធំ | 86,814 | 84,220 | 3.780 | 318,312 | 110,757 | 109,897 | 2.456 | 269,861 | 39,791 | 39,552 | 2.578 | 101,962 |
| 07 | កំពត | 14,230 | 14,230 | 3.923 | 55,821 | 74,121 | 74,121 | 3.131 | 232,052 | 42,345 | 42,345 | 3.184 | 134,839 |
| 08 | កណ្តាល | 32,316 | 31,096 | 4.131 | 128,444 | 6,629 | 6,628 | 2.929 | 19,416 | 1,654 | 1,572 | 2.969 | 4,667 |
| 09 | កោះកុង | - | | - | | 9,308 | 9,308 | 2.836 | 26,395 | 328 | 328 | 2.759 | 905 |
| 10 | ក្រចេះ | 19,339 | 19,339 | 2.927 | 56,609 | 40,224 | 39,769 | 2.898 | 115,261 | 2,103 | 1,409 | 2.695 | 3,797 |
| 11 | មណ្ឌលគិរី | 15,959 | 15,958 | 3.592 | 57,320 | 14,945 | 14,945 | 3.324 | 49,681 | 1,195 | 1,195 | 2.981 | 3,562 |
| 12 | ភ្នំពេញ | 3,410 | 3,410 | 2.894 | 9,869 | 506 | 506 | 2.988 | 1,512 | 404 | 404 | 3.163 | 1,278 |
| 13 | ព្រះវិហារ | 9,301 | 9,301 | 2.926 | 27,211 | 61,782 | 61,704 | 2.964 | 182,877 | 33,023 | 32,893 | - | 97,207 |
| 14 | ព្រៃវែង | 166,842 | 166,842 | 4.595 | 766,699 | 125,623 | 125,623 | 2.902 | 364,578 | 17,013 | 17,013 | 2.942 | 50,057 |
| 15 | ពោធិសាត់ | 119,123 | 116,888 | 4.420 | 516,673 | 36,442 | 35,791 | 3.514 | 125,775 | 10,387 | 8,751 | 3.012 | 26,362 |
| 16 | រតនគិរី | 5,229 | 4,788 | 2.646 | 12,669 | 16,997 | 16,432 | 2.581 | 42,406 | 3,812 | 3,812 | 2.597 | 9,901 |
| 17 | សៀមរាប | 39,520 | 38,118 | 2.832 | 107,932 | 115,685 | 111,635 | 2.881 | 321,606 | 33,979 | 33,979 | 2.950 | 100,224 |
| 18 | ព្រះសីហនុ | - | | - | | 5,141 | 5,141 | 3.295 | 16,940 | 6,630 | 6,630 | 3.295 | 21,846 |
| 19 | ស្ទឹងត្រែង | 3,316 | 3,211 | 3.287 | 10,555 | 25,287 | 24,984 | 2.487 | 62,134 | 70 | 70 | 2.257 | 158 |
| 20 | ស្វាយរៀង | 47,383 | 47,383 | 4.084 | 193,505 | 126,124 | 126,124 | 2.689 | 339,197 | 1,275 | 1,275 | 2.593 | 3,306 |
| 21 | តាកែវ | 110,648 | 109,133 | 3.721 | 406,063 | 122,367 | 121,335 | 3.380 | 410,163 | 5,066 | 5,066 | 3.384 | 17,145 |
| 22 | ឧត្តរមានជ័យ | 10,553 | 10,553 | 3.500 | 36,936 | 123,528 | 123,528 | 3.002 | 370,802 | 9,693 | 9,693 | 3.324 | 32,216 |
| 23 | កែប | 1,245 | 1,245 | 3.528 | 4,392 | 1,097 | 1,097 | 3.120 | 3,423 | 1,276 | 1,276 | 3.217 | 4,105 |
| 24 | ប៉ៃលិន | 5,139 | 5,139 | 4.075 | 20,940 | 2,455 | 2,455 | 3.263 | 8,011 | | | - | |
| 25 | ត្បូងឃ្មុំ | 17,340 | 14,905 | 4.462 | 66,506 | 26,460 | 26,460 | 3.380 | 89,426 | 33,970 | 33,970 | 3.451 | 117,238 |
| សរុប | | **1,287,823** | **1,267,791** | **4.158** | **5,270,865** | **1,408,451** | **1,399,581** | **2.953** | **4,132,943** | **438,900** | **433,377** | **3.094** | **1,341,055** |
| តួលេខឆ្នាំមុន | | **1,212,537** | **1,201,305** | **3.951** | **4,746,441** | **1,326,753** | **1,312,170** | **2.930** | **3,845,212** | **430,733** | **429,110** | **3.153** | **1,352,906** |
| ប្រៀបធៀប | | **75,286** | **66,486** | **0.206** | **524,424** | **81,698** | **87,411** | **0.023** | **287,731** | **8,167** | **4,267** | **0.091** | **-11,851** |

# បរិមាណផល និងទិន្នផលដំណាំស្រូវរដូវវស្សាតាមប្រភេទឆ្នាំ ២០២៥

ឧបសម្ព័ន្ធទី ៣ខ

| ល.រ | រាជធានី-ខេត្ត | ស្រូវចំការ | | | | ស្រូវឡើងទឹក | | | | សរុប | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផ្ទៃ.ដាំដុះ | ផ្ទៃ.ប្រ.ផល | ទិន្នផល | បរិ.ផល | ផ្ទៃ.ដាំដុះ | ផ្ទៃ.ប្រ.ផល | ទិន្នផល | បរិ.ផល | ផ្ទៃ.ដាំដុះ | ផ្ទៃ.ប្រ.ផល | ទិន្នផល | បរិ.ផល |
| | | (ហត) | (ហត) | (ត/ហត) | (តោន) | (ហត) | (ហត) | (ត/ហត) | (តោន) | (ហត) | (ហត) | (ត/ហត) | (តោន) |
| 01 | បន្ទាយមានជ័យ | - | | - | | 16,198 | 16,186 | 2.549 | 41,258 | 289,483 | 286,203 | 3.656 | 1,046,233 |
| 02 | បាត់ដំបង | 155 | 155 | 1.865 | 289 | 1,666 | 1,666 | 2.630 | 4,381 | 484,999 | 477,989 | 3.782 | 1,807,983 |
| 03 | កំពង់ចាម | - | | - | | 1,050 | 1,050 | 2.700 | 2,835 | 116,769 | 116,598 | 3.532 | 411,852 |
| 04 | កំពង់ឆ្នាំង | - | | - | | | | - | | 145,266 | 144,014 | 3.777 | 543,932 |
| 05 | កំពង់ស្ពឺ | - | | - | | | | - | | 120,527 | 120,527 | 3.359 | 404,879 |
| 06 | កំពង់ធំ | 298 | 298 | 1.600 | 477 | 1,874 | 1,874 | 2.132 | 3,995 | 239,534 | 235,841 | 2.945 | 694,607 |
| 07 | កំពត | - | | - | | | | - | | 130,696 | 130,696 | 3.234 | 422,712 |
| 08 | កណ្ដាល | - | | - | | | | - | | 40,599 | 39,296 | 3.881 | 152,527 |
| 09 | កោះកុង | 584 | 584 | 2.599 | 1,518 | | | - | | 10,220 | 10,220 | 2.820 | 28,818 |
| 10 | ក្រចេះ | 35 | 35 | 2.057 | 72 | | | - | | 61,701 | 60,552 | 2.902 | 175,739 |
| 11 | មណ្ឌលគិរី | 1,014 | 1,014 | 1.068 | 1,083 | | | - | | 33,113 | 33,112 | 3.372 | 111,646 |
| 12 | ភ្នំពេញ | - | | - | | | | - | | 4,320 | 4,320 | 2.930 | 12,659 |
| 13 | ព្រះវិហារ | 1,912 | 2,042 | 2.874 | 5,868 | | | - | | 106,018 | 105,940 | 2.956 | 313,163 |
| 14 | ព្រៃវែង | - | | - | | | | - | | 309,478 | 309,478 | 3.817 | 1,181,334 |
| 15 | ពោធិសាត់ | 1,095 | 1,095 | 2.953 | 3,233 | - | | - | | 167,047 | 162,525 | 4.135 | 672,043 |
| 16 | រតនគិរី | 12,236 | 12,157 | 1.577 | 19,171 | - | | - | | 38,274 | 37,189 | 2.263 | 84,147 |
| 17 | សៀមរាប | 435 | 435 | 2.313 | 1,006 | 1,765 | 1,765 | 2.637 | 4,655 | 191,384 | 185,932 | 2.880 | 535,423 |
| 18 | ព្រះសីហនុ | - | | - | | | | - | | 11,771 | 11,771 | 3.295 | 38,786 |
| 19 | ស្ទឹងត្រែង | 230 | 230 | 1.322 | 304 | | | - | | 28,903 | 28,495 | 2.567 | 73,151 |
| 20 | ស្វាយរៀង | - | | - | | | | - | | 174,782 | 174,782 | 3.067 | 536,008 |
| 21 | តាកែវ | - | | - | | | | - | | 238,081 | 235,534 | 3.538 | 833,371 |
| 22 | ឧត្តរមានជ័យ | - | | - | | | | - | | 143,774 | 143,774 | 3.060 | 439,954 |
| 23 | កែប | - | | - | | | | - | | 3,618 | 3,618 | 3.295 | 11,920 |
| 24 | ប៉ៃលិន | 590 | 590 | 3.22 | 1,900 | | | - | | 8,184 | 8,184 | 3.770 | 30,851 |
| 25 | ត្បូងឃ្មុំ | - | | - | | | | - | | 77,770 | 75,335 | 3.626 | 273,170 |
| សរុប | | **18,584** | **18,635** | **1.874** | **34,921** | **22,553** | **22,541** | **2.534** | **57,124** | **3,176,311** | **3,141,925** | **3.449** | **10,836,908** |
| តួលេខឆ្នាំមុន | | **19,101** | **19,101** | **1.992** | **38,053** | **27,014** | **27,014** | **2.608** | **70,442** | **3,016,138** | **2,988,700** | **3.364** | **10,053,054** |
| ប្រៀបធៀប | | **-517** | **-466** | **-0.118** | **-3,132** | **-4,461** | **-4,473** | **-0.073** | **-13,318** | **160,173** | **153,225** | **0.085** | **783,854** |

# ផ្ទៃដីភ្ជួររាស់ និងដាំដុះដំណាំស្រូវរដូវប្រាំងឆ្នាំ ២០២៥

ឧបសម្ព័ន្ធទី ៤

| ល.រ | ឈ្មោះស្រុក | ព្យាករ (ហ.ត) | ផ្ទៃដីភ្ជួររាស់ | | | | | ផ្ទៃដីសាប (ហ.ត) | ផ្ទៃដីស្ទូង និងព្រោះ (ហត) | | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប (ហ.ត) | គោ-ក្របី | | គ្រឿងយន្ត | | | សន្ទូង | ពង្រោះ | សរុប | |
| | | | | ហ.ត | % | ហ.ត | % | | | | | |
| 01 | បន្ទាយមានជ័យ | 25,000 | 80,534 | | - | 80,534 | 100.00 | | | 80,534 | 80,534 | 322.14 |
| 02 | បាត់ដំបង | 25,000 | 93,713 | | - | 93,713 | 100.00 | | | 93,713 | 93,713 | 374.85 |
| 03 | កំពង់ចាម | 42,730 | 64,696 | 188 | 0.29 | 64,508 | 99.71 | | | 64,596 | 64,596 | 151.17 |
| 04 | កំពង់ឆ្នាំង | 37,700 | 59,810 | | - | 59,810 | 100.00 | | | 59,810 | 59,810 | 158.65 |
| 05 | កំពង់ស្ពឺ | 500 | 646 | 2 | 0.31 | 644 | 99.69 | | | 646 | 646 | 129.20 |
| 06 | កំពង់ធំ | 82,000 | 108,500 | | - | 108,500 | 100.00 | | | 108,500 | 108,500 | 132.32 |
| 07 | កំពត | 10,100 | 12,545 | | - | 12,545 | 100.00 | | | 12,545 | 12,545 | 124.21 |
| 08 | កណ្ដាល | 50,200 | 60,799 | | - | 60,799 | 100.00 | | | 60,799 | 60,799 | 121.11 |
| 09 | កោះកុង | | - | | | - | | | | - | - | - |
| 10 | ក្រចេះ | 16,430 | 16,469 | | - | 16,469 | 100.00 | | | 16,436 | 16,436 | 100.04 |
| 11 | មណ្ឌលគិរី | 220 | 237 | | - | 237 | 107.00 | | | 221 | 221 | 100.45 |
| 12 | ភ្នំពេញ | 280 | 340 | | - | 340 | 100.00 | | | 340 | 340 | 121.43 |
| 13 | ព្រះវិហារ | | - | | | - | | | | - | - | - |
| 14 | ព្រៃវែង | 75,000 | 157,691 | | - | 157,691 | 100.00 | | | 157,691 | 157,691 | 210.25 |
| 15 | ពោធិសាត់ | 20,000 | 62,905 | | - | 62,905 | 100.00 | | | 62,905 | 62,905 | 314.53 |
| 16 | រតនគិរី | 50 | 50 | | | 50 | | | | 50 | 50 | 100.00 |
| 17 | សៀមរាប | 31,630 | 29,033 | | - | 29,033 | 100.00 | | | 29,033 | 29,033 | 91.79 |
| 18 | ព្រះសីហនុ | | - | | | - | | | | - | - | - |
| 19 | ស្ទឹងត្រែង | 30 | 17 | | | 17 | | | | 17 | 17 | 56.67 |
| 20 | ស្វាយរៀង | 20,500 | 28,137 | | - | 28,137 | 100.00 | | | 28,137 | 28,137 | 137.25 |
| 21 | តាកែវ | 80,000 | 111,503 | | - | 111,503 | 100.00 | | | 111,503 | 111,503 | 139.38 |
| 22 | ឧត្តរមានជ័យ | 200 | 1,933 | | - | 1,933 | 100.00 | | | 1,933 | 1,933 | 966.50 |
| 23 | កែប | 60 | 62 | | - | 62 | 100.00 | | | 62 | 62 | 103.33 |
| 24 | ប៉ៃលិន | 500 | 1,720 | | - | 1,720 | 100.00 | | | 1,718 | 1,718 | 343.60 |
| 25 | ត្បូងឃ្មុំ | 15,470 | 16,700 | | - | 16,700 | 100.00 | 10 | 50 | 16,650 | 16,700 | 107.95 |
| **សរុប** | | **533,600** | **908,040** | **190** | **0.02** | **907,850** | **99.98** | **10** | **50** | **907,839** | **907,889** | **170.14** |
| **តួលេខឆ្នាំមុន** | | **498,858** | **840,420** | **191** | **0.02** | **840,229** | **99.98** | **5** | **45** | **840,143** | **840,188** | **168.42** |
| **ប្រៀបធៀប** | | **34,742** | **67,620** | **-1** | **0** | **67,621** | **0** | **5** | **5** | **67,696** | **67,701** | **8.06** |

# ផ្ទៃដីប៉ះពាល់ និងខូចខាតលើដំណាំស្រូវរដូវប្រាំងឆ្នាំ២០២៥

ឧបសម្ព័ន្ធទី ៥

| ល.រ | រាជធានី-ខេត្ត | បញ្ចប់ផ្ទៃដីអនុវត្តបាន | ប៉ះពាល់និងខូចខាតដោយប្រការផ្សេងៗ | | | | | | | | ផ្ទៃដីស្តារឡើងវិញ (ហ.ត) | ខូចខាតទាំងស្រុង (ហ.ត) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ប៉ះពាល់ (ហ.ត) | | | | ខូចខាត (ហ.ត) | | | | | |
| | | | ខ្វះទឹក | សត្វល្អិត | ទឹកជំនន់ដើមរដូវ | សរុប | ខ្វះទឹក | សត្វល្អិត | ទឹកជំនន់ដើមរដូវ | សរុប | | |
| 01 | បន្ទាយមានជ័យ | 80,534 | 18,412 | | | **18,412** | 2,636 | | | **2,636** | | 2,636 |
| 02 | បាត់ដំបង | 93,713 | 8,933 | | | **8,933** | 4,194 | | | **4,194** | | 4,194 |
| 03 | កំពង់ចាម | 64,596 | 397 | | | **397** | 3 | | | **3** | | 3 |
| 04 | កំពង់ឆ្នាំង | 59,810 | - | | | **-** | | | | **-** | | - |
| 05 | កំពង់ស្ពឺ | 646 | - | | | **-** | | | | **-** | | - |
| 06 | កំពង់ធំ | 108,500 | 5,156 | 612 | | **5,768** | 746 | 40 | | **786** | | 786 |
| 07 | កំពត | 12,545 | 2,777 | | | **2,777** | | | | **-** | | - |
| 08 | កណ្តាល | 60,799 | 8,461 | | | **8,461** | | | | **-** | | - |
| 09 | កោះកុង | - | - | | | **-** | | | | **-** | | - |
| 10 | ក្រចេះ | 16,436 | 1,523 | | | **1,523** | | | | **-** | | - |
| 11 | មណ្ឌលគិរី | 221 | - | | | **-** | | | | **-** | | - |
| 12 | ភ្នំពេញ | 340 | 40 | | | **40** | | | | **-** | | - |
| 13 | ព្រះវិហារ | - | - | | | **-** | | | | **-** | | - |
| 14 | ព្រៃវែង | 157,691 | 32,942 | | | **32,942** | | | | **-** | | - |
| 15 | ពោធិសាត់ | 62,905 | 2,446 | | | **2,446** | 1,018 | | | **1,018** | | 1,018 |
| 16 | រតនគិរី | 50 | - | | | **-** | | | | **-** | | - |
| 17 | សៀមរាប | 29,033 | 1,265 | | | **1,265** | 50 | | | **50** | | 50 |
| 18 | ព្រះសីហនុ | - | - | | | **-** | | | | **-** | | - |
| 19 | ស្ទឹងត្រែង | 17 | - | | | **-** | | | | **-** | | - |
| 20 | ស្វាយរៀង | 28,137 | 6,923 | | | **6,923** | | | | **-** | | - |
| 21 | តាកែវ | 111,503 | 9,929 | | | **9,929** | 135 | | | **135** | | 135 |
| 22 | ឧត្តរមានជ័យ | 1,933 | - | | | **-** | | | | **-** | | - |
| 23 | កែប | 62 | - | | | **-** | | | | **-** | | - |
| 24 | ប៉ៃលិន | 1,718 | 953 | | | **953** | 20 | | | **20** | | 20 |
| 25 | ត្បូងឃ្មុំ | 16,700 | 1,196 | | | **1,196** | 144 | | | **144** | | 144 |
| សរុប | | **907,889** | **101,353** | **612** | **-** | **101,965** | **8,946** | **40** | **-** | **8,986** | **-** | **8,986** |
| តួលេខឆ្នាំមុន | | **840,188** | **48,890** | **-** | **416** | **49,306** | **15,431** | **-** | **416** | **15,847** | **1,292** | **14,555** |
| ប្រៀបធៀប | | **67,701** | **52,463** | **612** | **-416** | **52,659** | **-6,485** | **40** | **-416** | **-6,861** | **-1,292** | **-5,569** |

# ផលិតកម្មដំណាំស្រូវប្រចាំឆ្នាំ ២០២៥

ឧបសម្ព័ន្ធទី ៦

| ល.រ | រាជធានី-ខេត្ត | រដូវប្រាំង | | | | រដូវវស្សា | | | | សរុបប្រចាំឆ្នាំ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផ្ទៃដីអនុវត្ត (ហ.ត) | ផ្ទៃដីប្រមូលផល (ហ.ត) | ទិន្នផល (ត /ហ.ត) | បរិមាណផល (តោន) | ផ្ទៃដីអនុវត្ត (ហ.ត) | ផ្ទៃដីប្រមូលផល (ហ.ត) | ទិន្នផល (ត /ហ.ត) | បរិមាណផល (តោន) | ផ្ទៃដីអនុវត្ត (ហ.ត) | ផ្ទៃដីប្រមូលផល (ហ.ត) | ទិន្នផល (ត /ហ.ត) | បរិមាណផល (តោន) |
| 01 | បន្ទាយមានជ័យ | 80,534 | 77,898 | 5.054 | 393,690 | 289,483 | 286,203 | 3.656 | 1,046,233 | 370,017 | 364,101 | 3.955 | 1,439,923 |
| 02 | បាត់ដំបង | 93,713 | 89,519 | 4.544 | 406,813 | 484,999 | 477,989 | 3.782 | 1,807,983 | 578,712 | 567,508 | 3.903 | 2,214,796 |
| 03 | កំពង់ចាម | 64,596 | 64,593 | 4.200 | 271,280 | 116,769 | 116,598 | 3.532 | 411,852 | 181,365 | 181,191 | 3.770 | 683,132 |
| 04 | កំពង់ឆ្នាំង | 59,810 | 59,810 | 4.816 | 288,052 | 145,266 | 144,014 | 3.777 | 543,932 | 205,076 | 203,824 | 4.082 | 831,984 |
| 05 | កំពង់ស្ពឺ | 646 | 646 | 3.793 | 2,450 | 120,527 | 120,527 | 3.359 | 404,879 | 121,173 | 121,173 | 3.362 | 407,329 |
| 06 | កំពង់ធំ | 108,500 | 107,714 | 4.812 | 518,350 | 239,534 | 235,841 | 2.945 | 694,607 | 348,034 | 343,555 | 3.531 | 1,212,957 |
| 07 | កំពត | 12,545 | 12,545 | 4.605 | 57,769 | 130,696 | 130,696 | 3.234 | 422,712 | 143,241 | 143,241 | 3.354 | 480,481 |
| 08 | កណ្ដាល | 60,799 | 60,799 | 4.397 | 267,318 | 40,599 | 39,296 | 3.881 | 152,527 | 101,398 | 100,095 | 4.194 | 419,845 |
| 09 | កោះកុង | - | - | - | - | 10,220 | 10,220 | 2.820 | 28,818 | 10,220 | 10,220 | 2.820 | 28,818 |
| 10 | ក្រចេះ | 16,436 | 16,436 | 4.379 | 71,969 | 61,701 | 60,552 | 2.902 | 175,739 | 78,137 | 76,988 | 3.217 | 247,708 |
| 11 | មណ្ឌលគិរី | 221 | 221 | 4.226 | 934 | 33,113 | 33,112 | 3.372 | 111,646 | 33,334 | 33,333 | 3.377 | 112,580 |
| 12 | ភ្នំពេញ | 340 | 340 | 3.868 | 1,315 | 4,320 | 4,320 | 2.930 | 12,659 | 4,660 | 4,660 | 2.999 | 13,974 |
| 13 | ព្រះវិហារ | - | - | - | - | 106,018 | 105,940 | 2.956 | 313,163 | 106,018 | 105,940 | - | 313,163 |
| 14 | ព្រៃវែង | 157,691 | 157,691 | 4.848 | 764,525 | 309,478 | 309,478 | 3.817 | 1,181,334 | 467,169 | 467,169 | 4.165 | 1,945,859 |
| 15 | ពោធិ៍សាត់ | 62,905 | 61,887 | 4.635 | 286,845 | 167,047 | 162,525 | 4.135 | 672,043 | 229,952 | 224,412 | 4.273 | 958,888 |
| 16 | រតនគិរី | 50 | 50 | 3.820 | 191 | 38,274 | 37,189 | 2.263 | 84,147 | 38,324 | 37,239 | 2.265 | 84,338 |
| 17 | សៀមរាប | 29,033 | 28,983 | 4.293 | 124,423 | 191,384 | 185,932 | 2.880 | 535,423 | 220,417 | 214,915 | 3.070 | 659,846 |
| 18 | ព្រះសីហនុ | - | - | - | - | 11,771 | 11,771 | 3.295 | 38,786 | 11,771 | 11,771 | 3.295 | 38,786 |
| 19 | ស្ទឹងត្រែង | 17 | 17 | 3.176 | 54 | 28,903 | 28,495 | 2.567 | 73,151 | 28,920 | 28,512 | 2.568 | 73,205 |
| 20 | ស្វាយរៀង | 28,137 | 28,137 | 4.359 | 122,654 | 174,782 | 174,782 | 3.067 | 536,008 | 202,919 | 202,919 | 3.246 | 658,662 |
| 21 | តាកែវ | 111,503 | 111,368 | 5.235 | 582,980 | 238,081 | 235,534 | 3.538 | 833,371 | 349,584 | 346,902 | 4.083 | 1,416,351 |
| 22 | ឧត្ដរមានជ័យ | 1,933 | 1,933 | 4.000 | 7,732 | 143,774 | 143,774 | 3.060 | 439,954 | 145,707 | 145,707 | 3.073 | 447,686 |
| 23 | កែប | 62 | 62 | 3.758 | 233 | 3,618 | 3,618 | 3.295 | 11,920 | 3,680 | 3,680 | 3.302 | 12,153 |
| 24 | ប៉ៃលិន | 1,718 | 1,698 | 4.574 | 7,766 | 8,184 | 8,184 | 3.770 | 30,851 | 9,902 | 9,882 | 3.908 | 38,617 |
| 25 | ត្បូងឃ្មុំ | 16,700 | 16,556 | 4.661 | 77,165 | 77,770 | 75,335 | 3.626 | 273,170 | 94,470 | 91,891 | 3.813 | 350,335 |
| | **សរុប** | **907,889** | **898,903** | **4.733** | **4,254,508** | **3,176,311** | **3,141,925** | **3.449** | **10,836,908** | **4,084,200** | **4,040,828** | **3.735** | **15,091,416** |
| | **តួលេខឆ្នាំមុន** | **840,188** | **825,633** | **4.647** | **3,836,508** | **3,016,138** | **2,988,700** | **3.364** | **10,053,054** | **3,856,326** | **3,814,333** | **3.641** | **13,889,562** |
| | **ប្រៀបធៀប** | **67,701** | **73,270** | **0.086** | **418,000** | **160,173** | **153,225** | **0.085** | **783,854** | **227,874** | **226,495** | **0.093** | **1,201,854** |

# តុល្យភាពស្បៀងតាមបណ្តារាជធានី-ខេត្តឆ្នាំ ២០២៦

ឧបសម្ព័ន្ធទី ៧

| ល.រ | រាជធានី-ខេត្ត | ចំនួនប្រជាជន (នាក់) | បរិមាណផល តោន | ទុកពូជ និងបាត់បង់ពេលប្រមូលផល១៣% តោន | ស្រូវចំណីនៅសល់ (កាត់ចេញ១៣%) តោន | គិតជាអង្ករ ៦៤% តោន | តម្រូវការស្បៀងជាអង្ករ តោន | តុល្យភាពស្បៀង (អង្ករ) តោន | តុល្យភាពស្បៀង (ស្រូវ) តោន |
|---|---|---|---|---|---|---|---|---|---|
| 01 | បន្ទាយមានជ័យ | 988,725 | 1,439,923 | 187,190 | 1,252,733 | 801,749 | 141,388 | **660,361** | **1,031,814** |
| 02 | បាត់ដំបង | 1,148,298 | 2,214,796 | 287,923 | 1,926,873 | 1,233,199 | 164,207 | **1,068,992** | **1,670,300** |
| 03 | កំពង់ចាម | 1,014,837 | 683,132 | 88,807 | 594,325 | 380,368 | 145,122 | **235,246** | **367,572** |
| 04 | កំពង់ឆ្នាំង | 599,969 | 831,984 | 108,158 | 723,826 | 463,249 | 85,796 | **377,453** | **589,770** |
| 05 | កំពង់ស្ពឺ | 1,013,341 | 407,329 | 52,953 | 354,376 | 226,801 | 144,908 | **81,893** | **127,958** |
| 06 | កំពង់ធំ | 780,608 | 1,212,957 | 157,684 | 1,055,273 | 675,375 | 111,627 | **563,748** | **880,856** |
| 07 | កំពត | 669,979 | 480,481 | 62,463 | 418,018 | 267,532 | 95,807 | **171,725** | **268,320** |
| 08 | កណ្តាល | 1,370,809 | 419,845 | 54,580 | 365,265 | 233,770 | 196,026 | **37,744** | **58,975** |
| 09 | កោះកុង | 137,462 | 28,818 | 3,746 | 25,072 | 16,046 | 19,657 | **-3,611** | **-5,642** |
| 10 | ក្រចេះ | 436,002 | 247,708 | 32,202 | 215,506 | 137,924 | 62,348 | **75,576** | **118,088** |
| 11 | មណ្ឌលគិរី | 93,364 | 112,580 | 14,635 | 97,945 | 62,685 | 13,351 | **49,334** | **77,084** |
| 12 | ភ្នំពេញ | 2,622,843 | 13,974 | 1,817 | 12,157 | 7,780 | 375,067 | **-367,287** | **-573,886** |
| 13 | ព្រះវិហារ | 301,297 | 313,163 | 40,711 | 272,452 | 174,369 | 43,085 | **131,284** | **205,131** |
| 14 | ព្រៃវែង | 1,182,530 | 1,945,859 | 252,962 | 1,692,897 | 1,083,454 | 169,102 | **914,352** | **1,428,675** |
| 15 | ពោធិសាត់ | 486,942 | 958,888 | 124,655 | 834,233 | 533,909 | 69,633 | **464,276** | **725,431** |
| 16 | រតនគិរី | 260,021 | 84,338 | 10,964 | 73,374 | 46,959 | 37,183 | **9,776** | **15,275** |
| 17 | សៀមរាប | 1,183,145 | 659,846 | 85,780 | 574,066 | 367,402 | 169,190 | **198,212** | **309,706** |
| 18 | ព្រះសីហនុ | 378,036 | 38,786 | 5,042 | 33,744 | 21,596 | 54,059 | **-32,463** | **-50,723** |
| 19 | ស្ទឹងត្រែង | 196,193 | 73,205 | 9,517 | 63,688 | 40,760 | 28,056 | **12,704** | **19,850** |
| 20 | ស្វាយរៀង | 593,018 | 658,662 | 85,626 | 573,036 | 366,743 | 84,802 | **281,941** | **440,533** |
| 21 | តាកែវ | 1,017,496 | 1,416,351 | 184,126 | 1,232,225 | 788,624 | 145,502 | **643,122** | **1,004,878** |
| 22 | ឧត្តរមានជ័យ | 323,041 | 447,686 | 58,199 | 389,487 | 249,272 | 46,195 | **203,077** | **317,308** |
| 23 | កែប | 49,284 | 12,153 | 1,580 | 10,573 | 6,767 | 7,048 | **-281** | **-439** |
| 24 | ប៉ៃលិន | 87,107 | 38,617 | 5,020 | 33,597 | 21,502 | 12,456 | **9,046** | **14,134** |
| 25 | ត្បូងឃ្មុំ | 881,355 | 350,335 | 45,544 | 304,791 | 195,066 | 126,034 | **69,032** | **107,863** |
| សរុប | | **17,815,702** | **15,091,416** | **1,961,884** | **13,129,532** | **8,402,901** | **2,547,649** | **5,855,252** | **9,148,831** |
| តួលេខឆ្នាំមុន | | **17,577,759** | **13,889,562** | **1,805,643** | **12,083,919** | **7,733,708** | **2,513,620** | **5,220,088** | **8,156,388** |
| ប្រៀបធៀប | | **237,943** | **1,201,854** | **156,241** | **1,045,613** | **669,193** | **34,029** | **635,164** | **992,444** |

***កំណត់សម្គាល់*** **៖** ចំណោលឆ្នាំ២០១៩-២០៣០ របស់ក្រសួងផែនការ

# ផលិតផលស្រូវឆ្នាំ ២០២៥ និងតុល្យភាពស្បៀងឆ្នាំ ២០២៦

ឧបសម្ព័ន្ធទី ៨

| កំរិតកំណត់ | ឯកត្តា | រដូវប្រាំង | រដូវវស្សា | សរុប |
|---|---|---|---|---|
| ផែនការដាំដុះ | ហ.ត | 533,600 | 2,994,557 | **3,528,157** |
| ផ្ទៃដីអនុវត្ត | ហ.ត | 907,889 | 3,176,311 | **4,084,200** |
| ផ្ទៃដីខូចខាត | ហ.ត | 8,986 | 34,386 | **43,372** |
| ផ្ទៃដីប្រមូលផល | ហ.ត | 898,903 | 3,141,925 | **4,040,828** |
| ទិន្នផលមធ្យម | ត/ហ.ត | 4.733 | 3.449 | **3.735** |
| បរិមាណផល | តោន | 4,254,508 | 10,836,908 | **15,091,416** |

**<u>កំណត់សម្គាល់</u>**

| | | |
|---|---|---|
| - កាត់ចេញ ១៣ភាគរយ លើបរិមាណសរុបសំរាប់ទុកពូជ ចំណីសត្វ និងបាត់បង់ពេលប្រមូលផល | 1,961,884 | តោន |
| - ស្រូវចំណីនៅសល់ ក្រោយពីកាត់ចេញ (១៣%) | 13,129,532 | តោន |
| - សរុបស្បៀងដែលមាន គិតជាអង្ករ | 8,402,901 | តោន |
| - តម្រូវការស្បៀងមួយឆ្នាំ | 2,547,649 | តោន |
| - បរិមាណអង្ករលើស | **5,855,252** | តោន |
| - គិតជាស្រូវលើស | **9,148,831** | តោន |

ឧបសម្ព័ន្ធទី ៩

# ផលិតកម្មដំណាំស្រូវរយៈពេល ១០ ឆ្នាំ ២០១៦-២០២៥

| ឆ្នាំ-កំរិតកំណត់ | ឯកតា | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 | 2024 | 2025 | មធ្យមភាគ ១០ឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ផ្ទៃដីដាំដុះប្រចាំឆ្នាំ | ហត | 3,118,160 | 3,206,523 | 3,335,929 | 3,328,846 | 3,404,131 | 3,552,738 | 3,403,164 | 3,549,353 | 3,856,326 | 4,084,200 | 3,483,937 |
| - ប្រាំង | ហត | 518,574 | 548,755 | 596,483 | 597,508 | 597,508 | 649,552 | 639,124 | 682,104 | 840,188 | 907,889 | 657,769 |
| - វស្សា | ហត | 2,599,586 | 2,657,768 | 2,739,446 | 2,731,338 | 2,806,623 | 2,903,186 | 2,764,040 | 2,867,249 | 3,016,138 | 3,176,311 | 2,826,169 |
| ផ្ទៃដីប្រមូលផលប្រចាំឆ្នាំ | ហត | 3,099,769 | 3,189,485 | 3,248,061 | 3,263,774 | 3,268,968 | 3,497,682 | 3,302,676 | 3,512,918 | 3,814,333 | 4,040,828 | 3,423,849 |
| - ប្រាំង | ហត | 518,514 | 547,848 | 593,747 | 592,128 | 592,128 | 645,985 | 638,241 | 677,374 | 825,633 | 898,903 | 653,050 |
| - វស្សា | ហត | 2,581,255 | 2,641,637 | 2,654,314 | 2,671,646 | 2,676,840 | 2,851,697 | 2,664,435 | 2,835,544 | 2,988,700 | 3,141,925 | 2,770,799 |
| ទិន្នផលប្រចាំឆ្នាំ | ត/ហត | 3.211 | 3.298 | 3.353 | 3.335 | 3.345 | 3.490 | 3.520 | 3.558 | 3.641 | 3.735 | 3.449 |
| - ប្រាំង | ត/ហត | 4.465 | 4.508 | 4.512 | 4.418 | 4.418 | 4.534 | 4.567 | 4.640 | 4.647 | 4.733 | 4.544 |
| - វស្សា | ត/ហត | 2.959 | 3.047 | 3.094 | 3.095 | 3.108 | 3.254 | 3.269 | 3.299 | 3.364 | 3.449 | 3.194 |
| បរិមាណផលប្រចាំឆ្នាំ | តោន | 9,952,270 | 10,518,339 | 10,891,735 | 10,885,733 | 10,935,619 | 12,206,988 | 11,623,872 | 12,497,232 | 13,889,562 | 15,091,416 | 11,620,732 |
| - ប្រាំង | តោន | 2,315,364 | 2,469,542 | 2,678,842 | 2,616,253 | 2,616,253 | 2,928,672 | 2,915,062 | 3,142,847 | 3,836,508 | 4,254,508 | 2,977,385 |
| - វស្សា | តោន | 7,636,906 | 8,048,797 | 8,212,893 | 8,269,480 | 8,319,366 | 9,278,316 | 8,708,810 | 9,354,385 | 10,053,054 | 10,836,908 | 8,871,891 |
| ត្រូវការស្បៀងក្នុង១ឆ្នាំ | តោន | 2,266,335 | 2,298,001 | 2,329,364 | 2,375,097 | 2,298,786 | 2,349,355 | 2,444,079 | 2,479,092 | 2,513,619 | 2,547,649 | 2,390,138 |
| ស្បៀងសល់ ឬខ្វះ (អង្ករ) | តោន | 3,275,089 | 3,558,612 | 3,735,153 | 3,686,077 | 3,790,167 | 4,447,494 | 4,028,093 | 4,479,371 | 5,220,090 | 5,855,252 | 4,207,540 |
| ស្បៀងសល់ ឬខ្វះ (ស្រូវ) | តោន | 5,117,327 | 5,560,331 | 5,836,177 | 5,759,495 | 5,922,136 | 6,949,209 | 6,293,895 | 6,999,017 | 8,156,391 | 9,148,831 | 6,574,281 |

# ស្ថិតិផ្ទៃដីប្រមូលផល និង បរិមាណផល ដំណាំស្បៀងរួមផ្សំ និងដំណាំទ្រទ្រង់សេដ្ឋកិច្ចរដូវប្រាំងឆ្នាំ ២០២៥

ឧបសម្ព័ន្ធទី ១០ក

| ល.រ | រាជធានី-ខេត្ត | ពោតស | | | ដំឡូងជ្វា | | | បន្លែគ្រប់មុខ | | | ម្ទេស | | | ឪឡឹក | | | ដំណាំផ្សេងៗ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | អនុវត្ត (ហ.ត) | ប្រមូលផល (ហ.ត) | បរិមាណផល (ត) | អនុវត្ត (ហ.ត) | ប្រមូលផល (ហ.ត) | បរិមាណផល (ត) | អនុវត្ត (ហ.ត) | ប្រមូលផល (ហ.ត) | បរិមាណផល (ត) | អនុវត្ត (ហ.ត) | ប្រមូលផល (ហ.ត) | បរិមាផល (ត) | អនុវត្ត (ហ.ត) | ប្រមូលផល (ហ.ត) | បរិមាផល (ត) | អនុវត្ត (ហ.ត) | ប្រមូលផល (ហ.ត) | បរិមាផល (ត) |
| 01 | បន្ទាយមានជ័យ | 380 | 380 | 5,317 | 51 | 51 | 677 | 822 | 822 | 15,779 | 15 | 15 | 268 | 446 | 446 | 10,295 | 23 | 23 | 374 |
| 02 | បាត់ដំបង | 69 | 69 | 322 | 12 | 12 | 81 | 663 | 663 | 8,809 | 16 | 16 | 252 | 9 | 9 | 245 | - | - | - |
| 03 | កំពង់ចាម | 686 | 686 | 2,542 | 161 | 161 | 913 | 5,420 | 5,420 | 63,135 | | | - | | | - | - | - | - |
| 04 | កំពង់ឆ្នាំង | 941 | 941 | 1,755 | 122 | 122 | 684 | 4,179 | 4,179 | 64,874 | 133 | 133 | 815 | 254 | 254 | 5,601 | - | - | - |
| 05 | កំពង់ស្ពឺ | 38 | 38 | 136 | 19 | 19 | 129 | 800 | 800 | 8,538 | - | - | - | 145 | 145 | 2,598 | 10 | 10 | 65 |
| 06 | កំពង់ធំ | 122 | 122 | 381 | 170 | 170 | 986 | 312 | 312 | 2,006 | | | | 1,592 | 1,592 | 42,651 | - | - | - |
| 07 | កំពត | 329 | 329 | 1,704 | 219 | 219 | 1,366 | 2,185 | 2,185 | 8,740 | 19 | 19 | 86 | 85 | 85 | 1,278 | 25 | 23 | 414 |
| 08 | កណ្ដាល | 1,212 | 1,212 | 6,060 | 45 | 45 | 990 | 5,260 | 5,260 | 86,459 | 281 | 281 | 2,529 | - | - | - | 491 | 491 | 1,696 |
| 09 | កោះកុង | 25 | 25 | 145 | 5 | 5 | 14 | 123 | 123 | 1,462 | | | | 25 | 25 | 453 | 7 | 7 | 98 |
| 10 | ក្រចេះ | 205 | 205 | 559 | 108 | 108 | 840 | 584 | 584 | 4,672 | | | | 31 | 31 | 340 | 32 | 32 | 384 |
| 11 | មណ្ឌលគិរី | | | - | | | | 181 | 181 | 1,978 | | | | | | | - | - | - |
| 12 | ភ្នំពេញ | 13 | 13 | 137 | - | - | - | 87 | 87 | 609 | 20 | 20 | 176 | 23 | 23 | 299 | | | |
| 13 | ព្រះវិហារ | 14 | 14 | 42 | 62 | 62 | 650 | 461 | 461 | 5,993 | | - | | 20 | 20 | 360 | - | - | - |
| 14 | ព្រៃវែង | 209 | 209 | 1,254 | | | | 1,047 | 1,047 | 19,172 | 19 | 19 | 171 | 356 | 356 | 8,900 | - | - | - |
| 15 | ពោធិសាត់ | 191 | 191 | 1,038 | 38 | 38 | 209 | 558 | 558 | 7,892 | 16 | 16 | 95 | 195 | 195 | 2,925 | 39 | 39 | 1,080 |
| 16 | រតនគិរី | 20 | 20 | 257 | | | - | 40 | 40 | 497 | | | | | | | - | - | - |
| 17 | សៀមរាប | 812 | 812 | 2,983 | 175 | 175 | 1,400 | 2,088 | 2,088 | 23,396 | 92 | 92 | 471 | 430 | 430 | 5,718 | 134 | 134 | 2,244 |
| 18 | ព្រះសីហនុ | 18 | 18 | 109 | 13 | 13 | 93 | 475 | 475 | 5,150 | | | | | | | 7 | 7 | 72 |
| 19 | ស្ទឹងត្រែង | 76 | 76 | 97 | 9 | 9 | 90 | 305 | 305 | 3,178 | 26 | 26 | 182 | 19 | 19 | 380 | 9 | 9 | 250 |
| 20 | ស្វាយរៀង | - | - | - | 59 | 59 | 502 | 1,527 | 1,527 | 24,977 | | | | | | - | - | - | - |
| 21 | តាកែវ | 156 | 156 | 453 | 59 | 59 | 495 | 660 | 660 | 11,880 | - | - | - | 102 | 102 | 2,040 | - | - | - |
| 22 | ឧត្តរមានជ័យ | 18 | 18 | 162 | 7 | 7 | 196 | 116 | 115 | 2,369 | 5 | 5 | 90 | 60 | 60 | 1,680 | 63 | 63 | 1,182 |
| 23 | កែប | 143 | 143 | 631 | 332 | 332 | 2,047 | 298 | 298 | 3,243 | 26 | 26 | 106 | 29 | 29 | 434 | - | - | - |
| 24 | ប៉ៃលិន | 6 | 6 | 30 | 24 | 24 | 480 | 170 | 152 | 4,143 | 37 | 29 | 241 | 4 | 4 | 87 | 12 | 10 | 243 |
| 25 | ត្បូងឃ្មុំ | 265 | 265 | 1,825 | 170 | 170 | 2,550 | 1,085 | 1,085 | 19,155 | 20 | 20 | 100 | 50 | 50 | 1,000 | - | - | - |
| **សរុប** | | **5,948** | **5,948** | **27,939** | **1,860** | **1,860** | **15,392** | **29,446** | **29,427** | **398,106** | **725** | **717** | **5,582** | **3,875** | **3,875** | **87,284** | **852** | **848** | **8,102** |
| **តួលេខឆ្នាំមុន** | | **6,726** | **6,725** | **33,133** | **1,841** | **1,841** | **14,111** | **30,492** | **29,407** | **402,743** | **693** | **693** | **6,010** | **3,885** | **3,884** | **92,692** | **1,351** | **1,351** | **12,195** |
| **ប្រៀបធៀប** | | **-778** | **-777** | **-5,194** | **19** | **19** | **1,281** | **-1,046** | **20** | **-4,636** | **32** | **24** | **-427** | **-10** | **-9** | **-5,408** | **-499** | **-503** | **-4,093** |

# ស្ថិតិផ្ទៃដីប្រមូលផល និង បរិមាណផល ដំណាំស្បៀងរួមផ្សំ និងដំណាំទ្រទ្រង់សេដ្ឋកិច្ចរដូវប្រាំងឆ្នាំ ២០២៥

